


# ប្រទេសកម្ពុជាសព្វថ្ងៃ

$២.00

# ប្រវត្តិសាស្ត្រប្រទេសខ្មែរ

## សំរាប់កូនជាតិខ្មែរជំនាន់ក្រោយ



សរសេរចងក្រងដោយៈ តាំង ស្វយ (ឪពុក)

សហអ្នកនិពន្ធៈ តាំង រស្មី (ម្តាយ)

សំរាប់កូនប្រុស តាំង រក្សា, កូនស្រី តាំង មូនីកា, និង តាំង មីលីស្សា

ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៣

# អារម្ភកថា

**យើង**ត្រូវតែសិក្សាប្រវត្តិសាស្ត្រដោយសារយោបល់ជាច្រើនប្រការ។ ថ្វីបើអ្នកខ្លះគិតផ្ទុយទៅវិញការសិក្សាប្រវត្តិសាស្ត្រធ្វើឲ្យយើងមើលជក់។ ប្រវត្តិសាស្ត្រផ្តល់នូវការលាតត្រដាងអំពី សង្គម១ៗ អំពីដំណើរជីវិតដែលគេបង្កើតឡើង។ ប្រវត្តិសាស្ត្រក៏ បានបង្រៀនយើងអំពីដំណើរការល្អ និង អាក្រក់អំពីសង្គម និមួយៗ។ ប្រការម៉្យាងដែលយើងរៀនពីអតីតកាល គឺកុំឲ្យយើង ប្រព្រឹត្តអំពើគ្រោះថ្នាក់កាចសាហាវសារដើមឡើងវិញដល់អនាគត។ បើយើងប្រព្រឹត្តអំពើកាចសាហាវដដែល អារ្យធម៌របស់មនុស្ស លោកនិងវិនាសបាត់បង់។ ការសិក្សាប្រវត្តិសាស្ត្រមានសារៈ សំខាន់ឲ្យយើងដឹងថាយ៉ាងម៉ិចបានជាប្រវត្តិកាលសម័យឥឡូវ វាកើតឡើងយ៉ាងដូច្នេះ។

ក្នុងខណៈកូនទាំងអស់ ការសិក្សាប្រវត្តិសាស្ត្រប្រទេសខ្មែរគឺកុំឲ្យកូនភ្លេចកំណើតស្រុកដែលជាដំណារតពីឪពុក-ម្តាយ។

ដូច្នេះនេះជាស្នាដៃសរសេរចងក្រងអំពីឪពុក-ម្តាយសំរាប់កូនមើលនៅថ្ងៃណាមួយ តើយើងមានដើមកំណើតពីប្រទេសណា? តើឯណាទៅប្រទេសខ្មែរក្នុងពិភពលោក កើតពីឆ្នាំណា មានប្រវត្តិយ៉ាងណា? តទៅនេះគឺជាដំណើររឿង..........

# ទំព័រមាតិកា


ជំពូកទី១......អំពីអ្នកនិពន្ធ..........................................ទំព័រទី៤

ជំពូកទី២......បុព្វកថា....................................................ទំព័រទី៧

ជំពូកទី៣......ប្រទេសអាស៊ីអាគ្នេយ៍ពីសតវត្សទី១ ដល់ពេលសម័យឥឡូវ.....................................................ទំព័រទី៩

ជំពូកទី៤......ការធ្លាក់ដុនដាបនៃអាណាចក្រខ្មែរ...........ទំព័រទី២៣

ជំពូកទី៥......ប្រទេសខ្មែរ ១៩៥៣-៧០ (រាជាណាចក្រ)..ទំព័រទី៣៣

ជំពូកទី៦......ប្រទេសខ្មែរ ១៩៧០-៧៥ (សាធារណរដ្ឋ)..ទំព័រទី៦៣

ជំពូកទី៧......ប្រទេសខ្មែរ ១៩៧៥-៧៩ (ខ្មែរក្រហម).....ទំព័រទី៧៨

ជំពូកទី៨......ប្រទេសខ្មែរ ១៩៧៩-សម័យឥឡូវ (ហ៊ុន សែន គណៈបក្សប្រជាជនខ្មែរ-រដ្ឋាភិបាលតុក្កតារបស់ប្រទេសយួន)..............................................................ទំព័រទី១០៥

ជំពូកទី៩......សេចក្តីសង្ខេប.....................................ទំព័រទី១២១

ជំពូកទី១០......ឯកសារយោង.................................ទំព័រទី១២៨

# ជំពូក ទី១
# អំពីអ្នកនិពន្ធ

**តាំង ស្វយ** មានដើមកំណើតនៅ ភូមិផ្សារលើ, ស្រុកបាកាន, ខែត្រពោធិសាត់, ប្រទេសកម្ពុជា។ លោកបានរស់នៅៗប្រទេសសហរដ្ឋអាមេរិកអស់រយៈ៣៨ឆ្នាំហើយ។ លោកបានរ៉ឺត្រែតអំពីមុខវិជ្ជាអាជីវៈជាវិស្វករ អេឡិកត្រូនិក អគ្គិសនីយ នៅឆ្នាំ ២០០៩ ក្រោយពីធ្វើការឲ្យក្រុមហ៊ុន៣អស់រយៈ ពេល ៣០ឆ្នាំ។ លោកបានរៀនសិក្សានៅដូចតទៅៈ

-វត្តិវាលសាលាបថមសិក្សាពី ១៩៥៥-១៩៥៨
-សាលាបថមសិក្សាកណ្តាលលលកសពី ១៩៥៩-១៩៦១
-សាលាវិទ្យាល័យពោធិសាត់ពី ១៩៦២-១៩៦៧
-សាលាវិទ្យាល័យព្រះស៊ីសូវត្ថភ្នំពេញពី ១៩៦៨-១៩៦៩
-សាលាមហាវិទ្យាល័យវិទ្យាសាស្រ្តភ្នំពេញ ១៩៧០
-សាលាវិទ្យាស្ថានកងទ័ពខ្មែរនាយទាហានពី ១៩៧០-១៩៧២
-ហាត់រៀនជាមួយកងទ័ពសហរដ្ឋម្នកបែតងវៀតណាម ១៩៧២
-សាលាវិទ្យាស្ថានកងទ័ពខ្មែរនាយទាហាននយោបាយ ១៩៧៤
-សាលាវិទ្យាស្ថានកងទ័ពខ្មែរភាសាអង់គ្លេស ១៩៧៥
-សាលាបច្ចេកទេសទ័ពសហរដ្ឋ អាបើឌីនរដ្ឋមារីលែន ១៩៧៥
-សាលាមហាវិទ្យាល័យវិស្វករសហរដ្ឋផិនស៊ីលវ៉េនីយ៉ា ១៩៧៥-៧៩
-សាលាមហាវិទ្យាល័យម៉ាស្ទើរវិស្វករសហរដ្ឋម៉ាស្សាឈូសិត្ត១៩៨៦
-សាលាមហាវិទ្យាល័យសហរដ្ឋវិស្វករប្រូក្រាមមើរ នធីស្ទើន ១៩៩៨

លោកបានទទួលរង្វាន់ដូចតទៅ:

**-Who Among Who in America Junior Colleges 1977**
**-Outstanding Engineering Student 1976-1977**
**-President List 1978**
**-President List 1979**

លោកបានធ្វើការនៅ:

**-1st Lieutenant at the National of Defense, Cambodia 1970-1975**
**-Electrical Engineer Hardware and Test: Sperry Univac 1979-1982**
**-Sr. Electrical Engineer Hardware: Raytheon Company 1982-2000**
**-Sr. Electrical Engineer Hardware: Intel Corporation 2000-2001**
**-Sr. ASIC Design Engineer: NEC Electronics Corporation 2001-2009**

សេចក្តីសង្ខេបរបស់ម្តាយ មានដូចតទៅ:

**តាំងចាន់រស្មី** មានកំណើតឈ្មោះជា ចាន់រស្មី កើតនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ អ្នកស្រីបានរស់នៅអស់រយៈ៣២ឆ្នាំ នៅសហរដ្ឋអាមេរិក (ពេលវេលានេះរៀបការណឹទៅឪពុកទាំងស្រុង)។ អ្នកស្រីបានរៀនសូត្រនៅ:

**-Petite Lycee, French School in Phnom Penh 1969-1974**
**-Lycee Dalat, French Boarding School, S. Vietnam 1975**
**-Lycee Ecole Catholique, France 1975**
**-Ecole Polyvalente, Montreal, Canada 1975-1980**
**-Montgomery Community College, Pa USA 1981**
**-Worcester States College, Ma USA 1982**
**-Saint Vincent School of Nursing (RN), Ma USA 1983-86**
**-Assumption College (BSN), Ma USA 1987-1988**
**-Assumption College (pre-Medical), Ma USA 1989**
**-Umass Medical School (NP), Ma USA 2011-Present**

អ្នកស្រីបានទទួលរង្វាន់ដូចតទៅ:

-Miss Disco 1980
-Miss Elegance 1980
-Nursing Honor Society - Sigma Theta Tau 1988

អ្នកស្រីបានធ្វើការនៅ:

**-Bloomingdales in Pennsylvania, USA 1981**
**-Bloomingdales in Massachusetts, USA 1982**
**-Marlborough Hospital (RN), Ma 1986-1988**
**-Saint Vincent Hospital (BSN), Ma 1992-1994**
**-Umass Memorial, Worcester Ma, 1994-Present (2013)**

សៀវភៅដែលកូនអាននេះជាសៀវភៅទី៩ដែលសរសេរដោយឪពុក។ សៀវភៅឯទៀតដែលពុកបានបកប្រែពីភាសាអង់គ្លេសទៅជាខ្មែរមាន: បញ្ជូនពាក្យតាមទូរស័ព្ទខ្មែរអង់គ្លេស(២ក្បាល), ដើមកំណើតមនុស្សប្រជៀវ, មនុស្សពីងពាង, ក្រុមហ៊ុនមេធាវី, ប្រវត្តិរឿងអំពីឪពុក-ម្តាយសំរាប់កូនជាតិខ្មែរ-អាមេរិកាំងជំនាន់ទី១ (១ក្បាលជាភាសាខ្មែរ, ១ក្បាលជាភាសាអង់គ្លេស), និងសៀវភៅនៅដៃកូននេះ ប្រវត្តិសាស្ត្រប្រទេសខ្មែរសំរាប់កូនជាតិខ្មែរជំនាន់ក្រោយ (១ក្បាលជាភាសាខ្មែរ, ១ក្បាលជាភាសាអង់គ្លេស)។

អ្នកនិពន្ធ ឪពុក សូមថ្លែងអំណរអរគុណដល់ភរិយា រស្មី (អ្នកជំនិតបំផុតក្នុងជីវិត) កូន ទាំង៣ រក្សា មូនីកា និង ម៉ីស្សា ដែលលើកទឹកចិត្តក្នុងការសរសេរ និងជួយកែរពាក្យភាសាអង់គ្លេសខ្លះ។

# ជំពូក ទី២
# ឫព្រកថា

**ឳពុក**មានកំណើតកើតឡើងជាកូនទីពក្នុងគ្រួសារដែល មានកូន៦នាក់។ ជីតារបស់កូនឈ្មោះ តាំងឃុន (តាមទំនាម ទំលាប់ខ្មែរ ឈ្មោះជីតាដាក់មុនឈ្មោះខ្លួនគាត់)។ ម្តាយរបស់ពុក កើតនៅភូមិផ្សារលើ, ស្រុកបាកាន, ខែត្រពោធិសាត់។ ជីដូនជីតា មានកូន ៦នាក់។ គាត់ទាំង២ បានស្លាប់ ក្នុងសង្គ្រាមខ្មែរ ក្រហម ប៉ុលពត រវាងឆ្នាំ ១៩៧៥-១៩៧៩។ បងប្រុស-ស្រី និង ប្អូនប្រុសពីរ នាក់របស់ពុកក៏ត្រូវស្លាប់ក្នុងសង្គ្រាម ប៉ុល ពត ដែរ។ ឳពុកមាន សំណាងណាស់ ដែលបានរៀនប្រឡងជាប់ ត្រូវកងទ័ព ប្រទេសខ្មែរ បញ្ជូនឲ្យមករៀននៅសហរដ្ឋ ឆ្លងផុតការសម្លាប់ រង្គៀល របស់ ប៉ុល ពត រវាងឆ្នាំ១៩៧៥-១៩៧៩។ ឳពុកបាន ធានាយកប្អូនស្រីពៅដែលនៅរស់ តែម្នាក់គត់មករស់នៅសហរដ្ឋ នៅខែ កក្កដា ឆ្នាំ ២០១០។

នៅពេលរៀនសិក្សាតាំងពីតូចៗដល់ធំ អំពីថ្នាក់ បថមសិក្សា នៅសាលាវត្តិវាល បថមសិក្សាកណ្តាល នៅលលកស និង វិទ្យាល័យ ពោធិសាត់ និង ចុងបញ្ចប់ វិទ្យាល័យ ព្រះស៊ីសូវត្ថិ នៅភ្នំពេញ ឳពុកបាន រៀន សាវតារប្រវត្តិសាស្ត្រប្រទេសខ្មែរ អំពីលោកគ្រូដ៏ឆ្នើមៗ។ ក្រោយមក នៅ សាលាវិជ្ជាស្ថាននាយទាហ៊ានសំរាប់កងទ័ព និង សាលាវិជ្ជាស្ថាន នាយទាហ៊ាននយោបាយ ឳពុកបានរៀនបន្ថែម អំពីសាវតារ ស្ថានការណ៏ នយោបាយ និង សេដ្ឋកិច្ច របស់ ប្រវត្តិសាស្ត្រ ប្រទេសខ្មែរ និង ប្រទេសជិតខាង អាស៊ីអាគ្នេយ៏ (ដែលមាន ប្រទេសកម្ពុជា, វៀតណាម,

លាវ, និងថៃ) តាំងអំពីសតវត្សទី១ ដល់ សម័យបច្ចុប្បន្ន។ ដោយមាន ចំណេះដែលបានរៀនទាំងនេះ នៅក្នុងវិញ្ញាណខួរក្បាល ឪពុកចង់ និយាយប្រាប់ កូន ឲ្យដឹងអំពីសាវតារ ដើមកំណើតប្រទេសយើង។ ក្នុងពេលបច្ចុប្បន្នឥឡូវ ដែលមាន បច្ចេកវិទ្យា ទំនើបៗ ដូច ជា អាយផតថច់ អាយហ្វូន ថាប្លែត កុមព្យូទ័រ អិនធើរណិត និង គ្គូគ្គុលស្រាវជ្រាវ ឪពុកអាចចងក្រង ប្រវត្តិរឿងពិតៗ ជាសៀវភៅឲ្យកូន មើល ទៅថ្ងៃក្រោយ។

ឯកសារយោងទាំងប៉ុន្មានមានបង្ហាញនៅ ជំពូក ទី១០ ទំព័រ ១២៨។

ពុកបានបែងចែកទំព័រទៅតាម ព្រឹត្តិការណ៏ សេដ្ឋកិច្ច សង្គមកិច្ច និង នយោបាយ ធំៗដែលមានកើតឡើងនៅប្រទេសខ្មែរ។ កូននិងឃើញ ឈ្មោះប្រទេសខ្មែរ ដូរ តាំងពី ហ្វូណាន ទៅ ខ្មែរ និង កម្ពុជា។ ចាប់ផ្តើម សម្គាល់បន្តិចៗទៅ ក្រោយមក កូនឃើញ ឈ្មោះ គណៈបក្សដែលបាន បង្កើត ឡើង ឈ្មោះ និងពាក្យសរសេរកាត់ និងធ្វើឲ្យកូន ធុញថប់និង ចំណាំបាន។

# ជំពូក ទី៣
# ប្រទេសអាស៊ីអាគ្នេយ៍ពីសតវត្សទី១ដល់ទី៣

**សូម**ក្រឡេកមើលផ្ទាំងផែនទីប្រទេស អាស៊ីអាគ្នេយ៍ អំពីសតវត្សទី១ ដល់ ទីសតវត្សទី៣:

<ប្រទេស ឥណ្ឌា>   ប្រទេស ភូមា   <ប្រទេស ចិន>




ប្រទេស ម៉ាឡាយូ   សមុទ្រប្រទេសចិន

ប្រទេសខ្មែរ ពេលនោះមានឈ្មោះ ហ្វូណន (ក្រោយ មកហៅ ខ្មែរ, រួចហើយ កម្ពុជា) មានព្រំប្រទល់ខាងលិចជាប់និង សមុទ្រ អាដាម៉ាន (ឥណ្ឌា), ខាងត្បូង-ខាងលិច (នារតី) ជាប់ សមុទ្រប្រទេសចិន, ខាងកើត ប្រទេស ចំប៉ា (ហៅ ចាម), ខាងជើង ប្រទេស ភូមា, ខាងជើង-ខាងលិច (ពាយព្យ) ប្រទេស ឥណ្ឌា, និង ខាងជើង-ខាងកើត (ឥសាន្ត) ប្រទេសចិន។ កូនចំណាំក្នុងរយៈពេល នេះគ្មាន ប្រទេសថៃ ប្រទេសលាវ និង ប្រទេសវៀតណាមទេ។

ប្រជាជនកុលសម្ព័ន្ធ ថៃ (សៀម) ពេលនោះជាប្រជាជនភាគតិច របស់ប្រទេស ភូមា (មន) ក្រោយមកបានកើតកើនឡើងជាលំដាប់ បណ្តាច់ ខ្លួនចេញពី ភូមាខាងត្បូង លេបទឹកដីប្រទេសខ្មែរខាងលិច បង្កើតឡើងជាប្រទេសថៃ សព្វថ្ងៃ។ ក្នុងពេលសង្គ្រាមប្រទេស ភូមា នេះដែរ ប្រទេស១ទៀតចាប់កំណើតឡើង គឺប្រទេសលាវ បែកចេញ ពី ប្រទេសភូមាដែរ យកទឹកដីភូមាខាងត្បូង។ នៅទិសខាងកើតពី ហ្វូណន ប្រជាជនកុលសម្ព័ន្ធ វៀត (យួន) ពេលនោះជាប្រជាជនភាគតិច របស់ប្រទេស ចំប៉ា (ចាម) ក្រោយមកបានកើតកើនឡើងជាលំដាប់ វាយរំលំប្រទេស ចាម លេបទឹកដីប្រទេសខ្មែរខាងកើត បង្កើតឡើង ជាប្រទេសវៀតណាម សព្វថ្ងៃ។ ប្រជាជន ចាម មក ដល់សព្វថ្ងៃ រស់នៅ ជា កុលសម្ព័ន្ធ របស់ ប្រទេសខ្មែរ និង វៀតណាម។

## ”ពាក្យឯកស្រេចចេញអំពីសំដីអ្នកប្រវត្តិសាស្ត្រផ្ទាល់:

ព្រះរាជាណាចក្រ ហ្វូណាន មានកំណើតកើតឡើងរវាងសតវត្សទី១ គឺជារាជាណាចក្ររាជាវង្ស ទី១របស់ប្រទេសខ្មែរ។ រាជាណាចក្រនេះ មានឥទ្ធិពល វប្បធម៌ សិល្បៈ នយោបាយ មកអំពីប្រទេសឥណ្ឌា។ មាន អក្សរសាស្ត្រ សាសនា សិល្បៈសំណង់ កើតឆ្លងអំពីប្រទេស ឥណ្ឌា ប៉ុន្តែមិនដូចអក្សរសាស្ត្រឥណ្ឌាឡើយ (អក្សរសាស្ត្រខ្មែរ តាម សៀវភៅមហាសង្គ្រានជើងឯកខាងឯកសារពិភពលោក (*World Almanac)* មានព្យញ្ជនៈ ច្រើនជាជាងគ្រប់ប្រទេសក្នុងពិភពលោក ៣៣តួ មានស្រៈ ២៣តួ និង ស្រៈពិសេស ១២តួ ទៀត។) ប្រទេស ហ្វូណាន មាន បុរាណវត្ថុ ជាភស្តុតាងថាព្រះរាជាណាចក្រ មានបានរុងរឿង ជាច្រើន នៅតាមដីសណ្តនៃទន្លេមេកុង រវាង សតវត្សទី១ និង សតវត្សទី៦។

ត្រឡប់មក ពីបរទេសវិញ ព្រះបាទ ជ័យៈវរ្ម័នទី២ ប្រកាសខ្លួន ជាព្រះរាជា ដឹកនាំ រាជាណាចក្រ ហ្វូណាន ក្នុងសតវត្សទី៩។ ព្រះរាជាណាចក្រចាប់ផ្តើម រុងរឿង រហូត។ ព្រះរាជាចាប់ គោរពបូជា វប្បធម៌ ព្រះហ្សីវ៉ា, គឺព្រះធំបំផុត១ក្នុងសាសនា ហ៊ីនឌូ។ ព្រះបាទអង្គ នេះមានឥទ្ធិពលក្លាំងក្លា ចាប់ផ្តើមកសាង ទំនប់បង្ហូរទឹក ជុំវិញ ប្រាសាទ។ ក្រោយៗមកមាន ប្រាសាទ ជាច្រើនបានសង់ឡើង ជុំវិញការបង្ហូរទឹកនេះ។ ប្រាសាទអង្គរវត្ត ជាដើម ដែលសង់ឡើងនៅសតវត្សទី១២ ដោយព្រះបាទ សូរីយាវរ្ម័នទី២។ មានព្រះរាជា ស្នងសម្បត្តិ ២៦ ដំណារ រហូត ដល់សតវត្សទី១៥ ដែលបានសង់ ប្រាសាទបន្ថែមជាច្រើន និង ឆ្លាក់អក្សរចារឹក ជាង ១ពាន់ កន្លែង មានចម្លាក់លើជញ្ជាំងប្រាសាទ ជិតៗខាងទាំងឡាយ ជាភស្តុតាង។

## ប្រជាជនដំបូងនៅប្រទេសអាស៊ីអាគ្នេយ៍ គឺ ចាម, ខ្មែរ, និង មន តាំងអំពីសតវត្សទី១:

នៅផ្ដើមសតវត្សនេះមានការរាតត្បាតឥទ្ធិពលអំពីប្រទេសឥណ្ឌា សាសនា ហ៊ិនឌូ និង ព្រះពុទ្ធសាសនា មកលើប្រទេសទាំងបី។ ប្រទេសចាមនៅ ខាងកើតប្រទេសខ្មែរ (ប្រទេសឃ្មួនសព្វថ្ងៃ) មាន កាន់សាសនាហ៊ិនឌូ ក្រោយមក ដូរទៅអ៊ីស្លាម។ ខាងលិចប្រទេសចាម ប្រទេសខ្មែរ កាន់សាសនាហ៊ិនឌូ។ ខាងលិចទៅទៀត ជនជាតិមន (ប្រទេសថៃសព្វថ្ងៃ) កាន់ព្រះពុទ្ធសាសនា និងទឹកដីប្រទេស ភូមា ខាងត្បូង។ មកដល់ សតវត្សទី១១ ប្រជាជនមនត្រូវ ប្រទេសភូមា និង ការរីកកើតឡើង ថ្មីៗនៃប្រទេសថៃ រំលាយបាត់អស់។ ប្រជាជន ភូមា និង ថៃ រីកដាលឡើង មកពីការ ធ្វើដំណើរចុះមកខាងត្បូង នៃ កុលសម្ព័ន្ធ ដំបន់ ទីបេ។

## ឥទ្ធិពលអំពី ប្រទេសឥណ្ឌា និង ប្រទេសចិន : ចន្លោះសតវត្សទី១ និង សតវត្សទី៨

ឥទ្ធិពលវប្បធម៏ទៅលើប្រទេស អាស៊ីអាគ្នេយ៏ បានមកពី ប្រទេស ឥណ្ឌា ឬ ប្រទេស ចិន។ នៅសតវត្សទី១ ឈ្មួញអ្នកជំនួញ មកអំពីប្រទេស ឥណ្ឌា ចូលមកដល់ប្រទេស ភូមា។ ទៅខាងកើតបន្តិច ប្រទេសចាម ជនជាតិ កុលសម្ព័ន្ធវៀតណាម ដើមកំណើតនៅប្រទេសចិន ចាប់ចុះដំណើរទៅ ខាងត្បូងរវាង សតវត្សទី១មកដល់សតវត្សទី៣។

លើកលែងតែប្រទេសទាំង៣ ខ្មែរ, មន, និង ចាម ប្រទេសថៃ, លាវ, និង វៀតណាម ចាប់ផ្តើមកើតឡើងនៅ យុគ្គសម័យក្រោយៗ។

## នៅខាងកើតប្រទេសខ្មែរ៖ រាជាណាចក្រ ណាម-វៀត ចាប់កំណើតហើយក្លាយទីបំផុតរំលំប្រទេសចំប៉ា (ចាម)បាន

ទឹកដីចន្លោះទន្លេមេកុង និងតាមឆ្នេរសមុទ្រប្រទេសចិន មានសេដ្ឋកិច្ច លូតលាស់ឥតប្រដូច រវាងការដាំស្រូវជាកសិកម្ម និងមានការងាយ ចេញចូលដល់កប៉ាល់ចុះឡើងតាមផ្លូវសមុទ្រ ក្នុងរវាង ពីរបីសតវត្ស ខាងមុននេះ ធ្វើឲ្យមានការចាប់អារម្មណ៍ ដល់របបមាន អំណាចខាងជើងនៃប្រទេសចាម, គឺរាជាណាចក្រប្រទេសចិន។ ក្នុងរយៈពេលឆ្នាំ ២០៧ (សតវត្សទី១) រាជាធិរាជប្រទេសចិន បញ្ជូនអ្នក ដំណាងប្រតិភូទៅ កាន់ដំបន់ ហាណូយ សព្វថ្ងៃ។ អ្នកដំណាងប្រតិភូលើកដំកើង ខ្លួនជាស្តេច ចាប់បង្កើតរាជាណាចក្រជា ណាម-វៀត។ ១សតវត្សក្រោយ មក ក្រោមសន្តតិវង្ស ហាន រាជាធិរាជប្រទេសចិន ចាប់បញ្ចូល ណាម-វៀត ទៅជាខែត្ររបស់ ប្រទេសចិន នៅឆ្នាំ ១១១។

នៅសតវត្សទី១២ ប្រទេសចាមធ្វើសង្គ្រាមជាមួយប្រទេសខ្មែរ នៅទិសខាងលិច។ ឆ្នាំ ១១៧៧ ចាម និង អ្នករនុកក្នុងៗប្រទេសខ្មែរ ពីទន្លេសាប វាយផ្លាយប្រទេសខ្មែរ។ ប៉ុន្តែនៅឆ្នាំ ១១៨១ ព្រះរាជាខ្មែរ ព្រះបាទជ័យវរ្ម័នទី៧ វាយបណ្តេញចាមចេញបាន។

នៅចន្លោះ ការជឿនលឿនលូតលាស់របស់រាជាណាចក្រប្រទេសខ្មែរ រវាងឆ្នាំ ៨០០ និង ការរីកចំនួននៃរាជាណាចក្រ ណាម-វៀត

ប្រទេសចាមចាប់ថយអំណាច។ នៅឆ្នាំ ១៤៧១ ជនជាតិ ណាម-វៀត វាយលុកលុយ ប្រទេសចាមបាន ពេលនោះប្រជាជនចាម ១២០,០០០ នាក់ត្រូវ យួន សម្លាប់ហើយអាណាចក្រចាមត្រូវរំលាយទៅ ទុកនៅសល់តែដីតូច១ ជិត ញ៉ាត្រាង។ ចន្លោះឆ្នាំ ១៦០៧ និង ១៦៧៦ ស្តេចចាមបាន ប្តូរសាសនាទៅជា អ៊ីស្លាម ដែលមានសៃសសល់រហូតមកដល់ឥឡូវចំណោមអណិកជនជាតិចាមដែលរស់នៅៗប្រទេសយួន និង ខ្មែរសព្វថ្ងៃ។

## ប្រទេសខ្មែរ - រាជាណាចក្រកម្ពុជា ឡាំង្គែន, ការធ្លាក់ចុះរាសី អង្គរ ក្នុងរវាង សតវត្សទី១០ ដល់ សតវត្សទី១៥:

នៅក្នុងប្រទេសខ្មែរ ព្រះរាជាណាចក្រចាប់ពីសតវត្សទី៩ គ្រប់រាជាវង្ស ធ្វើព្រះរាជធានី នៅ អង្គរ (ស្ថិតនៅក្នុងខេត្រសៀមរាបជាប់ទល់ដែនប្រទេសថៃ)។ រហូតដល់ សតវត្សទី១២ ព្រះរាជាវង្សបន្តបន្ទាប់គ្នាបានកសាងប្រាសាទ ហ៊ីនឌូ ជាច្រើន រាប់ទាំង ប្រាសាទអង្គរវត្តនិងប្រាសាទឯទៀតៗជាច្រើននៅជុំវិញអង្គរវត្ត។ "វត្ត" មានសេចក្តី ជាភាសាខ្មែរថា "ប្រាសាទ"។ ព្រះរាជាធានី នៅប្រាសាទអង្គរ ត្រូវលះបោះបង់ចោលទុកឲ្យព្រៃដុះលេបលប់ ក្រោយពីការវាយលុក នៃប្រទេសចាមមកពីខាងកើត (ក្នុងឆ្នាំ ១១៧៧) រួចហើយការវាយលុកអំពីប្រទេសថៃពីខាងលិច (ក្នុងឆ្នាំ ១៤៣១)។ ការកើនឡើងជាលំដាប់ របស់ប្រទេស ចាម (ក្រោយមកវៀតណាម) ខាងកើត និង ប្រទេសថៃ (ថៃឡង់ ឬ សៀម) ខាងលិច ធ្វើឲ្យប្រទេសខ្មែរបាត់បង់ ទឹកដី និង ប្រជាជនដែលត្រូវគេកែនទៅជាមួយទឹកដី យ៉ាងសម្បើម។ មកដល់សព្វថ្ងៃមានប្រជាជនដែលមានដើមកំណើតជាខ្មែរ រស់នៅរាប់លាននាក់នៅប្រទេសយួន និង រាប់លាននាក់រស់នៅប្រទេសថៃ។ នៅក្នុងសតវត្សទី១៥ ព្រះរាជាខ្មែរ ដូរ

រាជធានី ទៅទិសខាងកើត ភ្នំពេញ ដែលមាននៅមកដល់សព្វថ្ងៃ។ (តាមប្រវត្តិសាស្ត្រជាក់ស្តែង ព្រះរាជធានី អង្គរ ត្រូវប្រទេសសៀមវាតត្បាតកំឡុងសតវត្សទី១៥ ព្រះរាជាខ្មែរដូររាជាធានីទៅ ភ្នំពេញ ពេលនោះ ហៅថា ក្រុងចតុមុខសេរីមង្គល ក្នុងឆ្នាំ ១៤៣៤ (ឬ១៤៤៦) ស្ថិតនៅទីនោះអស់រយៈរាប់ទសវត្ស (១០ឆ្នាំម្តង) រួចហើយដូរទៅ បាសាន, បន្ទាប់មកទៅលង្វែក និង ឧដុង។ ព្រះរាជាខ្មែរមិនត្រឡប់ទៅ រាជធានី ភ្នំពេញវិញលុះត្រា សតវត្ស ទី១៩។ សាវតារមិនបានបង្ហាញឲ្យច្បាស់នូវសំណល់កត់ត្រា អំពីរាជធានីមុនៗភ្នំពេញឲ្យច្បាស់។ នៅឆ្នាំ ១៨១៣ ព្រះបាទ អង្គចាន់ សង់ បន្ទាយកែវមរកដ ជិតព្រះបរមរាជវាំង សព្វថ្ងៃ។ ព្រះបាទ អង្គចាន់ (១៧៩៦-១៨៣៤) គង់នៅ ភ្នំពេញ អស់ពេលបន្តិចមុនដូរ រាជធានី ទៅ ឧដុង។ បន្ទាយកែវមរកដ ត្រូវ កងទ័ពសៀមវាយបាក់ខ្ទេចខ្ទីដុតចោល ពេលកងទ័ពសៀមដកថយចេញពី ភ្នំពេញក្នុងឆ្នាំ ១៨៣៤។ ព្រះរាជធានីមិនប្តូរពីឧដុងទៅភ្នំពេញវិញលុះត្រា ឆ្នាំ១៨៦៣ ពេលដែលប្រទេសកម្ពុជាត្រូវ ស៊ីញ៉េ ជាមួយ មហាអំណាចប្រទេសបារាំងឲ្យត្រួតត្រាការពារ ហើយពេលនោះព្រះបរមរាជវាំង សព្វថ្ងៃក៏ចាប់សង់ឡើង។



អង្គរវត្ត ត្រូវបាន គាស់កកាយរកឃើញឡើងវិញក្នុងរវាង ឆ្នាំ ១៨៦០ ឡើង។ អង្គរវត្ត ដូចពិភពសព្វថ្ងៃស្គាល់ គឺជា មហាសំណង់កោតក្រែង១ក្នុងមហាសំណង់មហាស្ចារ្យឯទៀតៗក្នុងសកលលោក (*one of the wonders of the world)*។ តាមមហាសង្រ្គានឯកនៃពិភពលោក *(World Almanac)* អង្គរ ជាប្រាសាទដែលធំជាងគេ ក្នុងពិភពលោកដែលសង់ឡើងសំរាប់សាសនា។ អង្គរវត្ត សង់ឡើងនៅលើដីរាងទ្រវែងបួនជ្រុង ទំហំ ២០៨ ហិកតា (**500 acres**) ។ សញ្ញាដែលបង្ហាញអំពីប្រាសាទ គឺស្រះទឹកភ្លោះជីកជុំវិញ មានទទឹង ២០០ម និង បរិវេណ ៥.៥ គ.ម។ ស្ពានដើរចូល ទទឹង ១២ ម៉ែត្រ បណ្តោយ ២៥០ ម៉ែត្រ ធ្វើអំពីផ្ទាំងថ្ម។

## សិល្បកសាងប្រាសាទ អង្គរវត្ត:

ផ្ទាំងថ្ម រលោងដូចគេខាត់ ប្រៀបបានថ្មកែវ ដាក់ភ្ជាប់គ្នាដោយគ្មានស៊ីម៉ង់បន្សីគ្នា ហើយសឹងគ្មានឃើញសំណាមតទៅទៀត របៀបនេះពិបាក

និងរកឃើញណាស់ ក្នុងលោក។ ផ្ទាំងថ្ម១ដុំៗតភ្ជាប់គ្នាដោយប្រហោង ដំណាប់ ដែលបានតភ្ជាប់ គ្នាដោយអណ្តាតពន្លួញឈើ ផ្ទាំងខ្លះដាក់បន្សីគ្នា ដូចឈើដែលជ្រៀក ហើយៗប្រើទម្ងន់គពីលើគ្នាមិនឲ្យរង្គើរបាន។ ផ្ទាំងថ្មទាំងនេះ បានសន្មតថានិងលើកដាក់ដោយប្រើរួមគ្នា ពីសត្វដំរី ប្រើខ្សែពួរវិញ ប្រើប្រដាប់ស្នូចយោងឡើង ប្រើរានរន្ទាធ្វើពីដើមឫស្សីជាដើម។ លោកអ្នក សង្កេតការ ហិនរី មូហាត កត់សំគាល់ថា ផ្ទាំងថ្មទាំងនេះមាន ប្រហោងខ្លួង ទំហំ ២.៥ស.ម និង ជំរៅ ៣ស.ម ហើយផ្ទាំងថ្មណាដែលធំៗជាងមាន ប្រហោងច្រើនទៅទៀត។ អ្នកសិក្សាបច្ចេកទេស ឲ្យយោបល់ថា ប្រហោងទាំងនេះសំរាប់ដាក់ចំរឹងដែកឲ្យផ្ទាំងថ្មតជាប់គ្នា អ្នកឯទៀតថា សំរាប់ដាក់រនុកជួយលើកសែងដាក់ឲ្យត្រូវកន្លែង។ ប្រាសាទទាំងមូល សង់ឡើង អំពីថ្មដាហៅថ្មខ្សាច់ ប្រៀបប្រដូចទៅ ខាប្រាំពីរ៉ាមីត ប្រទេស អេហ្សិប (ច្រើនជាង ៥លានតោន)។ ថ្មខ្សាច់ ទាំងនេះត្រូវតែយកមកអំពី ភ្នំគូលែន ចម្ងាយ ៤០គ.ម ទិសឥសាន្ត។ ថ្មដាថ្មខ្សាច់នេះត្រូវតែដឹកនាំតាម ក្បូនលើទឹក តាមដងស្ទឹងសៀមរាប។ ការដឹកនាំនេះត្រូវតែប្រយ័ត្នណាស់ ពីព្រោះថ្មដាមានទម្ងន់មហិមា ធ្វើមិនឲ្យក្បូនលិចទឹក។ មានអ្នកទំនើប វិស្វករម្នាក់វាយស្មានថា ប្រាសាទអង្គរត្រូវតែធ្វើហើយក្នុងរយៈ ៣០០ឆ្នាំ ក្នុង សម័យបច្ចុប្បន្ននេះ។ ប៉ុន្តែព្រះបាទ សូរីយ៉ាវរ្ម័ន ចាប់សង់ពេល ព្រះអង្គឡើងសោយរាជ្យ ហើយសង់ចប់មុនព្រះអង្គសុគត់ មិនលើសពី រយៈ ៤០ឆ្នាំ ឡើយ។

ដោយជាក់ស្តែង ផ្ទៃកំរាល សរសរ ធ្នឹម សូម្បីតែដំបូល ក៏ត្រូវឆ្លាក់ចារជាចម្លាក់។ បើរាប់ជាបណ្តោយប្រវែង រាប់គីឡូម៉ែត្រ ដែលមានចម្លាក់ជារូបភាពលំអជាទស្សនីយភាពបង្ហាញតាមអក្សរសាស្ត្រឥណ្ឌា សេះដែលមានស្នែងតែ១ សត្វសឹង្ហ សត្វនាគមានស្លាបអូសរទេះចម្បាំង រូបចម្លាក់អ្នក

ចំបាំងដើរតាម អ្នកដឹកនាំលើខ្នងដំរី នាងទេវតារាំរែកលើអាកាស។ ជញ្ជាំងវិចិត្រសាល មានលំអដោយចម្លាក់គ្របដណ្តប់ប្រហែល ១០០០ ម៉ែត្រការ៉េ។ ប្រហោងតាមជញ្ជាំងបញ្ជាក់ថាមាន ស្នាដៃចម្លាក់ធ្វើអំពីសំរិទ្ធ ពីពេលបូរាណដែលមានតម្លៃខ្ពស់បំផុត ហើយត្រូវខ្ទេះល្អួចនៅរយៈចុង ក្រោយៗមក។

នៅពេលប្រវត្តិសាស្ត្រជីករុករក លោក អាឡិក អេវ៉ាន់ អ្នកឆ្លើម ជាងថ្ម និង ជាងចម្លាក់ បានសាកបង្កើតឡើងវិញ រូបចម្លាក់លើថ្ម ទំហំ ១.២ម ធ្វើចប់ ក្រោយពីរយៈ៦០ថ្ងៃ។ លោក រជឿរ ហាបគិន និង ម៉ាក ឡេហ្គើរ ក៏ធ្វើការសាកល្បងជីកគាស់ផ្ទាំងថ្ម ដែលមានអ្នកជីកគាស់ ១២នាក់ គាស់ថ្មប្រហែល ៤០០តោន អស់រយៈពេល ២២ថ្ងៃ។ ពលកម្ម សង់ប្រាសាទមុខតែប្រើ មនុស្សរាប់ពាន់ រាប់ទាំង ជាងសូនរូប សិប្បករ ជាងហត្ថករ ដ៏ឆ្លើមៗជាច្រើននាក់។ ភាពជំនាញការខាងសិល្បៈចម្លាក់ បាន ដុសដាលរាប់រយឆ្នាំពីមុនមក ដោយមានវត្ថុបូរាណជាភស្តុតាងចាប់តាំងពី សតវត្សទី៧។



អង្គរវត្ត មើលពីមុខឆ្លងស្រះជីកជុំវិញ

មើលទៅខាងលិចប្រទេសខ្មែរ អាណាចក្រភូមាមាន រាជធានីនៅ ប៉ាគ្មែន ជ្រោះ អ៊ីរ៉ាវ៉ាឌី ក្នុងសតវត្សទី១១។ មកដល់សព្វថ្ងៃ មានមន្ទីរធ្វើសការៈបូជា បូជនីយដ្ឋានព្រះពុទ្ធសាសនា រាប់ពាន់ ហើយបូជនីយដ្ឋានខ្លះទៀតបង្ហាញ ការប្រកាន់សាសនា ហ៊ិនឌូ របស់ប្រទេសភូមា។

ការចំបាំងសង្គ្រាម រវាង រាជាណាចក្រ នៅប្រទេសអាស៊ីអាគ្នេយ៍ មានបន្តគ្នាមិនដាច់ រាជាណាចក្រ១រីកឡើង ១ទៀតចុះដុនដាប។ ឧទាហរណ៍ ការរួញបង្រួមរាជាណាចក្រប្រទេសខ្មែរនៅសតវត្សទី១៥ ការរត់ចោលអង្គរ ទៅរាជធានី ភ្នំពេញ គឺមកអំពី ការលូតលាស់ជឿនលឿន របស់ប្រទេសថៃខាងលិច។

## ការបង្ហាញខ្លួនជនជាតិ អ៊ឺរ៉ុបៈ សតវត្សទី១៦ ដល់ សតវត្សទី២០ៈ

គឺជាសំណាងអាក្រក់១របស់ប្រទេសអាស៊ីភាគអាគ្នេយ៍ គឺអ្នកជំនួញជន ជាតិអ៊ឺរ៉ុប ដើមសតវត្សទី១៥ ដើររុករកគ្រឿងទេស នៅកោះ មូលីកាស្ស (អាស៊ីខាងត្បូង ជិតកោះ ឥណ្ឌូនេស៊ី) មកដល់ប្រទេសអាស៊ីអាគ្នេយ៍ ឃើញការលូតលាស់ដាំដុសនៃកសិកម្ម ក៏មិនឈានជើងចេញ។ ក្រោយ ពីជនជាតិ ព័រទុយគ្គេ ធ្វើដំណើរតាមសមុទ្រទៅទិសខាងកើត ឆ្នាំ១៤៩៨ រកឃើញ ដំបន់អាស៊ីអាគ្នេយ៍ៗក៏ឡើងទៅជា ការប្រគួតប្រជែង យ៉ាងសាហាវ សំរាប់ជនជាតិអ៊ឺរ៉ុប មកលើដំបន់នេះ។

ជនជាតិ ព័រទុយគ្គេ ចាប់តាំង មូលដ្ឋាន នៅកោះម៉ាលីកា ឆ្នាំ ១៥១១ ចាត់ទុកដំបន់អាស៊ីជារបស់ខ្លួនតែម្នាក់ឯង។ ប៉ុន្តែនៅសតវត្សទី១៦ ប្រទេស អង់គ្លេស និង ហូឡង់ វាយដេញ ជនជាតិ ព័រទុយគ្គេ បាន។ ក្រោយមក ហូឡង់ កាន់កាប់ប្រទេស អាស៊ីអាគ្នេយ៍តែម្នាក់ឯង រហូតដល់

ឆ្នាំ១៧៩៩ មហាអំណាចប្រទេសបារាំងបានមកដល់ ហើយចាប់កាន់កាប់ដំបន់នេះ។

## មកដល់នេះគឺចប់ ការដកស្រង់ សំដីអ្នកប្រវត្តិសាស្រ្ត"

ដូចកូនឃើញស្រាប់សូម្បីអ្នកប្រវត្តិសាស្រ្ត ក៏បានបញ្ជាក់ថា ប្រជាជនកុលសម្ព័ន្ធ ថៃ (សៀម) ជាជនភាគតិចរបស់ប្រទេសភូមា (ជនជាតិ មន) ដែលបានកើនចំនួនច្រើនឡើងជាអតិបរិមា បណ្តាច់ខ្លួនចេញពីប្រទេសភូមាយកទឹកដីខាងត្បូង និងលេបទឹកដីប្រទេសខ្មែរខាងលិច បង្កើតជាប្រទេស ថៃ សព្វថ្ងៃនេះ។ នៅពេលដែលប្រទេស ភូមាមានសង្គ្រាមបាក់បែក ប្រទេស១ទៀត គឺប្រទេស លាវ ក៏កើតឡើងដែរ ចាប់យកដីប្រទេសភូមាខាងត្បូង។ មកដល់សព្វថ្ងៃ សមុទ្រប្រទេសចិនខាងត្បូងប្រទេសខ្មែរ មានឈ្មោះជា ឈូងសមុទ្រថៃ។ ទៅទិស ខាងកើតនៃប្រទេសខ្មែរ (ហ្វូណន) ប្រជាជនកុលសម្ព័ន្ធ ណាម-វៀត (យួន) ជាជនភាគតិចរបស់ប្រទេសចំប៉ា (ជនជាតិ ចាម) ដែលបានកើនចំនួនច្រើនឡើងជាអតិបរិមាដែរ វាយបំបែកប្រទេសចាមយកទឹកដីខាងត្បូង និងលេបទឹកដីខ្មែរខាងកើត (ខ្មែរក្រោម) បង្កើតជាប្រទេស វៀតណាមសព្វថ្ងៃ រហូតដល់សមុទ្រប្រទេសចិនខាងត្បូង។ អាណិកជនជាតិចាមសព្វថ្ងៃមានរស់នៅក្នុងប្រទេសខ្មែរ និង វៀតណាមមកដល់សម័យឥឡូវនេះ។

ប្រទេសវៀតណាម រួចហើយបំបែកទៅជាប្រទេស២ ប្រទេស វៀតណាមខាងជើង និង ប្រទេសវៀតណាមខាងត្បូង ដែលទើបនិង

**ចូលគ្នាវិញនៅឆ្នាំ១៩៧៦នេះ។ ប្រវត្តិសាស្ត្រមានដូចតទៅនេះ ប្រទេសវៀតណាមខាងជើង ជាប្រទេសកុម្មុយនីស្តចាប់ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧៦។** ពេលសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ប្រទេសយួនជារដ្ឋចំណុះក្រោមអាណានិគមប្រទេសបារាំង ត្រូវប្រទេស ជប៉ុន កាន់កាប់។ ក្រោយពីប្រទេស ជប៉ុន ចុះចាញ់នៅឆ្នាំ១៩៤៥ អ្នកដឹកនាំកុម្មុយនីស្តយួន ហូជីមិញ ទាមទារយកទឹកដីយួនខាងជើង ពេលដែលអតីតរាជាធិរាជ បៅដាយ ទាមទារកាន់កាប់ទឹកដីយួនខាងត្បូង។ ឆ្នាំ១៩៤៦ ប្រទេសបារាំងយកបាន យួនខាងជើងមកវិញ ហូជីមិញ រត់ចូលព្រៃបង្កើត សង្គ្រាមបារាំង-ឥណ្ឌូចិនលើកទី១។ ប្រទេសបារាំងបង្កើតរដ្ឋាភិបាលតុក្កតានៅយួនខាងត្បូងក្រោមអំណាច រាជាធិរាជបៅដាយ។ តាមសេចក្ដីប្រកាសសន្តិសុខ ហ្សឺណែវ ឆ្នាំ១៩៥៤ ប្រទេសបារាំងដកថយអាណានិគមអំពីប្រទេសឥណ្ឌូចិនទាំងមូល រាប់ទាំងប្រទេសយួនទាំង២ ប្រទេសខ្មែរ និង ប្រទេសលាវ។ ប្រទេសយួនទាំង២ត្រូវបែងចែកតាមខ្សែស្របពិភពលោកលេខទី១៧។ ចំណែកខាងជើង ហូជីមិញ ឡើងកាន់កាប់បង្កើតឡើងវិញប្រទេសយួនកុម្មុយនីស្តខាងជើង។ ចំណែកខាងត្បូង រដ្ឋាភិបាលតុក្កតារបស់បារាំង ព្រះចៅអធិរាជបៅដាយ ត្រូវរលំក្រោយពីការបោះឆ្នោតឆ្នាំ១៩៥៦ ក៏បង្កើតឡើងសាធារណរដ្ឋយួនខាងត្បូង ហើយចាប់ធ្វើសង្គ្រាមជាមួយយួនខាងជើង ពីឆ្នាំ១៩៥៩ រហូតដល់ឆ្នាំ១៩៧៥។ ឆ្នាំ១៩៦១ សហរដ្ឋអាមេរិកស៊ីញ៉េសន្ធិសញ្ញាការពារផ្នែកយោធា និង សេដ្ឋកិច្ច ដល់សាធារណៈវៀតណាមខាងត្បូង។ ពេល១ មានកងទ័ព សហរដ្ឋ ដល់ទៅ ៦០០,០០០ នាក់នៅយួនខាងត្បូង។ នៅឆ្នាំ១៩៧៥ សហរដ្ឋអាមេរិក ដកថយអំពីប្រទេស យួន-ខ្មែរ។ ប្រទេសវៀតណាមខាងជើងឈ្នះសង្គ្រាម ហើយចាប់បង្រួម ប្រទេសវៀតណាមទាំងមូលនៅឆ្នាំ១៩៧៦។

ពួកកូនត្រូវចាំថា មានភស្តុតាងធំណាស់មកដល់សម័យបច្ចុប្បន្នកាល ដែលបង្ហាញថាប្រទេសខ្មែរជាប្រទេសលើកដំបូងក្នុងដំបន់ប្រទេសអាស៊ីភាគអាគ្នេយ៏។ មានការរុងរឿងនៅជំនាន់អតីតកាលពីព្រោះ មាន ប្រាសាទ អង្គរវត្ត ល្បីល្បាញក្នុងលោក ដែលសង់ឡើងដោយព្រះរាជាធិរាជនៃរាជាណាចក្រប្រទេសខ្មែរ ជាភស្តុតាងមកដល់សព្វថ្ងៃស្រាប់ ពេលដែលប្រទេសឯទៀតៗជិតខាងគ្មានភស្តុតាងសំណង់អ្វីសោះជាធំដុំ។

<u>រូបផែនទីខាងក្រោមនេះ គឺ ជាផែនទីសម័យឥឡូវ</u>
<u>របស់ប្រទេសអាស៊ីភាគអាគ្នេយ៏ៈ</u>



# ជំពូក ទី៤
# ការធ្លាក់ដុនដាបនៃ រាជាណាចក្រខ្មែរ

**មក**ដល់សតវត្សទី១២, ប្រទេសខ្មែរ ប្រជាជនខ្មែរ ទឹកដីខ្មែរ ចាប់ធ្លាក់ទៅក្នុងកណ្តាប់ដៃប្រទេសឯទៀតៗដូចជា ប្រទេសថៃ ប្រទេសលាវ ភូមា និង ម៉ាឡាយូ (ទឹកដីលយចូលទៅសមុទ្រខាងក្រោម)។ តាមពិតមាន ប្រជាជនដើមកំណើតខ្មែររស់នៅៗទីទាំងនោះមកដល់សព្វថ្ងៃ។ សតវត្ស ទី១៣ និង ទី១៤ ជាសតវត្សមិនមានជោគជ័យសោះរបស់ប្រទេសខ្មែរ អ្នកខ្លះឲ្យយោបល់ថាដោយសារថាមពលលូតលាស់និងចំបាំងញឹកញាប់ ជាមួយប្រទេសថៃ ដែលពីដើមធ្លាប់នៅក្រោមបង្គាប់ប្រទេសខ្មែរអង្គរ។ អ្នកឯទៀតគិតថាដោយសារការទើបចាប់ផ្តើមបញ្ចូលព្រះពុទ្ធសាសនាទៅរាជាណាចក្រដែលខុសពីប្រពៃណីពីមុន (ហ៊ីនឌូ) បានជាធ្វើឲ្យប្រទេសចុះដុនដាប។ ពេលក្រោយៗអំពីសតវត្សនេះ ពង្សាវតាមិនមានការកត់ត្រា ច្បាស់លាស់អំពីប្រទេសខ្មែរ ប្រដូចទៅជាយុគងងឹត១សំរាប់ ប្រវត្តិសាស្ត្ររបស់ប្រទេសខ្មែរទៅមុខ។

មានការកត់សម្គាល់តូច១ទៅលើការបដិវត្តន៏នេះ ប្រទេសអាស៊ីភាគអាគ្នេយ៏ ស្ថិតនៅចន្លោះប្រទេសឥណ្ឌា និង ប្រទេសចិនដែលជាមហាអំណាច និងមានប្រជាជនច្រើនមហិមា។ មហាជនអំពីប្រទេសទាំង២ ចាប់ធ្វើ ដំណើរចុះទៅខាងត្បូង រុករកកន្លែងល្អសំរាប់ជីវិតរស់នៅ មកដល់ ប្រទេសថៃ ពិសេសទៅទៀតផ្នែកខាងកើតចុះពីប្រទេសចិនមកដល់ ប្រទេសវៀតណាម។ ប្រជាជនប្រទេសទាំង២កើនឡើងជាលំដាប់ ពេល ជាមួយគ្នានេះប្រជាជនប្រទេស

រាជាណាចក្រខ្មែរថយចុះជានិច្ចដោយសារ ចំបាំងជាមួយនិងប្រទេសទាំង២នេះមិនឈប់ឈរ។

មានការកត់សំគាល់១ទៀត ប្រដូចទៅនិងភាគឯទៀតក្នុងវត្តិសាស្រ្តពិភពលោកដែរ ប្រទេសជិតខាងលេបយកប្រទេស១ទៀត ដោយទឹកដីស្រេកឃ្លាន ឬ ដោយផលប្រយោជន៏សេដ្ឋកិច្ចលូតលាស់ជឿនលឿន។ ប្រទេសខ្លាំងលេបយកប្រទេសខ្សោយ។ ប្រវត្តិសាស្រ្តមានកើតឡើង នៅស្រុកកំណើតកូនសព្វថ្ងៃ ដូចកូនបានរៀនសូត្រក្នុងសាលាដូចជាៈ

ឧទាហរណ៏ការធ្លាក់ចុះនៃរាជាណាចក្រប្រទេស អេស្ប៉ាញៈ សង្គ្រាមអាមេរិកាំង-អេស្ប៉ាញ ពីខែមេសា ទៅខែសីហា ឆ្នាំ១៨៩៨។ សង្គ្រាមចប់ដោយប្រទេសអាមេរិកឈ្នះសង្គ្រាម។ សង្គ្រាមស៊ីពេលតែ ១១៣ថ្ងៃ សិន្ទិសញ្ញានៅប៉ារីសបញ្ចប់ការជម្លោះ ផ្ទេរឲ្យអ្នកឈ្នះប្រទេសសហរដ្ឋអាមេរិក នូវទឹកដីអាណានិគមដូចជា ប្រទេសព័រតូរីកូ ប្រទេសហ្វីលីពីន និង គ្វាម ក្នុងពេលជាមួយនេះដែរឲ្យឯករាជ្យទៅប្រទេស គុយបា ដែលធ្វើចប់គ្រប់នៅឆ្នាំ ១៩០២។
ឧទាហរណ៏១ទៀតៈ សង្គ្រាមម៉ិចស៊ីកាំង-អាមេរិកាំង (សង្គ្រាម ១៨៤៦-១៨៤៨) ដោយការបញ្ចូលជាឧប្បសម្ព័ន្ធរដ្ឋតិចសាស ទៅសហរដ្ឋអាមេរិក។ ប្រទេសម៉ិចស៊ីកាំង មិនទទួលស្គាល់ការប្រកាសការផ្តាច់ខ្លួនរដ្ឋនេះនៅឆ្នាំ១៨៣៦ ធ្វើចំបាំងដើម្បីទាមទាររដ្ឋនេះវិញ។ សហអាមេរិកឈ្នះនៅរក្សា រដ្ឋតិចសាសមកដល់សព្វថ្ងៃ។
ឧទាហរណ៏១ទៀតដែរ ការចុះធ្លាក់នៃរាជាណាចក្របារាំងទល់មុខប្រទេសអង់គ្លេសនៅទ្វីប អាមេរិកខាងជើងៈ សង្គ្រាមរវាងប្រទេសបារាំងនិងអង់គ្លេសដែលមានឈ្មោះថា សង្គ្រាមមហាក្សត្រីយានីអាន ឆ្នាំ១៧០២ ដែលមានលទ្ធផលប្រទេសអង់គ្លេសយកបានផែរ-យ៉ាល់ ឆ្នាំ១៧១០។

សន្ធិសញ្ញា អ៊ូត្រិច្ត ឆ្នាំ ១៧១៣ តម្រូវឲ្យបារាំងចុះចាញ់ប្រគល់ឲ្យអង់គ្លេស ទឹកដីឈ្វូងសមុទ្រ ហាដសុន, នូវហ្វោនលែន និង អាកេឌីយ៉ា ទុកឲ្យបារាំង កោះ ខេបប្រេីតុង និង អាណានិគមក្នុងទឹកដី។

ក្រោយពីនេះបន្តិច បារាំងចាប់សង់បន្ទាយពង្រឹងជំហរ ល្វីសបេីគ្ក យ៉ាងធំ លើកោះ ខេបប្រេីតុង។ បន្ទាយនេះចាប់លួតលាស់ក្នុងរយៈ ២៥ឆ្នាំបន្ត ត្រួតត្រាផ្ទៃទឹកអាមេរិកខាងជើងសឹងតែទាំងអស់។

ក្នុងឆ្នាំ១៧៤៥ កងទ័ពជើងគោកអង់គ្លេស ដឹកនាំដោយលោក វីលីយាំ ផិបពើរ៉េល តម្លើងកប៉ាល់៩០ និង ទាហ៊ាន ៤០០០នាក់ ឡើងវាយបន្ទាយ ល្វីសបេីគ្ក បារាំងបាក់បែក។ សន្ធិសញ្ញា អ៊ិកឡាឆាប៉ែល ឆ្នាំ១៧៤៨ ប្រគល់ ល្វីសបេីគ្កទៅបារាំងវិញ។

ដេីម្បីទប់ទល់បារាំងទៅថ្ងៃមុខប្រទេសអង់គ្លេសបញ្ជូន មនុស្ស ២៥០០ នាក់ ឆ្នាំ១៧៤៩ មក តាំងលំនៅថ្មីនៅ ហាលីហ្វាក់។

បែរមកមើលប្រទេសកម្ពុជាវិញៈ រាជាធិរាជអាណាចក្រប្រទេសខ្មែរ មិនខុសគ្នាពី មហាអំណាចអាមេរិក, អង់គ្លេស, និងបារាំងទេ។ សង្គ្រាម ដែលរាតត្បាតបំផ្លិចបំផ្លាញប្រទេសខ្មែរតាំងពីសតវត្សទី១២ មកដល់ សតវត្សទី១៩ដោយខ្សែរាជវង្ស សៀម (ដូរឈ្មោះទៅថៃនៅឆ្នាំ១៩៣៩) និង យួន បន្តបន្ទាប់គ្នា និងសង្គ្រាមថ្មីៗ ពីឆ្នាំ ១៨៣០ឡើង សឹងតែបំបាត់ទឹកដី ខ្មែរពីសកកលលោក។

ការតស៊ូប្រយុទ្ធរវាងខ្មែរនិងសៀមទិសខាងលិចនៅមានមិនដាច់ៈ ខេត្របាត់ដំបង សៀមរាប និង ស៊ីសូផុន ធ្លាប់ធ្លាក់ទៅក្នុងដៃសៀម ក្នុងឆ្នាំ១៧៩៥ និង ១៩៤១។ ដំបន់នេះថិតនៅក្រោមប្រទេសសៀមរហូត ដល់ឆ្នាំ១៩៤៦។

ពេលដំបូងដែលសៀមវាយលុកលុយលួចប្លន់អង្គររវាងឆ្នាំ១៣៥២ រួចហើយ ឆ្នាំ១៤៣០ឡើង។ ពេលនោះសៀមមានរាជធានីនៅ អាយុទ្ធយ៉ា កន្លែងដើមរបស់ វប្បធម៏ស្រីទ្វារាវាទី រាជាណាចក្រ មន (ភូមា)។ ខែត្រឯទៀតដែលសៀមយកនៅឆ្នាំ១៧៩៥ មាន បាត់ដំបង សៀមរាប/អង្គរ បុង្គលបូរី ស្រីសុផុន សៀមប៉ាង។ នៅឆ្នាំ១៨១៤ មានខែត្រឯទៀតក្រោម ការត្រួតពិនិត្យសៀម មានខែត្រ ម្លូព្រៃ ទន្លេពៅ និង ស្ទឹងត្រែង។ ទើបតែ ឆ្នាំ១៩០៧ដែលមានខែត្រខ្លះទាំងនេះបានមកខ្មែរវិញ។ ផ្ទុយទៅវិញ ខែត្រ នគរាជបូរី (កូរាត សព្វថ្ងៃ), បុរីរម្យ (បូរិរាម), សុរិន្ទ (សូរិន), គរខាន់, ស៊ីសាកេត, បាសិមបូរី (ប្រាជិនបូរី), ចាន់តាបូរី (ចាន់តាបូរី), ចំប៉ាសាក់ និង ខែត្រ ត្រាត ត្រូវសៀមយកអស់រហូតដល់សព្វថ្ងៃ។
តាមសន្ធិសញ្ញា សៀម-បារាំង ឆ្នាំ១៩០៧ សៀមសងមកខ្មែរវិញតែខែត្រ ណាដែលសៀមយកក្រោយឆ្នាំ១៧៩០។ ក្នុងរឿងនេះសៀមអរគុណបារាំង មិនតិចទេពីព្រោះសៀមមិនដែលនៅក្រោមអាណានិគមបារាំង នៅជាមិត្ត របស់អង់គ្លេសទៅវិញ។

ការតស៊ូប្រយុទ្ធរវាងខ្មែរនិងយួនទិសខាងកើតក៏នៅមានមិនដាច់: ដំបន់ដែលមានពណ៌បៃតង ហៅថា ប្រទេសកម្ពុជាខាងក្រោម ឬ ខ្មែរក្រោម ជាភាសាខ្មែរ។



ប្រជាជនខ្មែរក្រោមបានរស់នៅក្នុងដីលយទឹកសមុទ្រ ខាងត្បូង-ខាងកើត (អាគ្នេយ៏)នៃឥណ្ឌូចិន តាំងពី២០០០ឆ្នាំ មុន គ.ស។ រាជាធិរាជខ្មែរដែលបានឡើងល្បី លេចជ្រងោនៅសតវត្សទី៩ ចាប់ចុះវិញនៅសតវត្សទី១៣។ យ៉ាងណាក៏ដោយ តាំងពីឆ្នាំ១៦០០ឡើង ខ្មែរមានកាពិបាកតស៊ូជាមួយអ្នកជិតខាងៗកើត គឺ យួន ដែលតាំងពីឆ្នាំ១៩៤៩ ចាប់ត្រួតត្រាយកដីកម្ពុជាក្រោម។ ប្រជាជនខ្មែរក្រោមត្រូវយួនហាមមិនឲ្យប្រព្រឹត្តសាសនា ហាមមិនឲ្យបន្តទំនាមទំលាប់វប្បធម៍ ហើយជាទូរទៅចាត់ទុកជាពលរដ្ឋធុនទី២ ជាន់ក្រោមគេ។

ប្រទេសបារាំងបានមកដល់ប្រទេសអាស៊ីអាគ្នេយ៏ឆ្នាំ១៧៩៩ ហៅដំបន់នេះ "ឥណ្ឌូ-ចិន" មានសេចក្ដីថា ប្រទេសដែលស្ថិតនៅចន្លោះប្រទេសឥណ្ឌា និង ប្រទេសចិន។ ព្រះរាជាខ្មែរ នរោត្ដម ស៊ីញ៉ៅ សន្ធិសញ្ញាជាមួយបារាំង ឲ្យប្រទេសបារាំងការពារទឹកដីខ្មែរ ដូច្នេះបញ្ឈប់ការលុកលុយលួចដីប្រទេសខ្មែរ អំពី យួន-សៀម តទៅទៀត។ រយៈពេល ៩០ឆ្នាំ បន្ទាប់មកប្រទេសខ្មែរនៅក្រោមអាណានិគមប្រទេសបារាំង។ ថ្វីបើតាមសន្ធិសញ្ញា ប្រទេសបារាំង ត្រូវជាអ្នកចាត់ចែងជួយឲ្យយោបល់ តាមការពិតប្រទេសបារាំង សម្រេចចិត្តទៅលើអ្វីៗគ្រប់ប្រភេទ។ ថ្វីបើបារាំងបានសង់ផ្លូវសង្កាត់ ពង្រីកចរាចរ ពង្រីកសេដ្ឋកិច្ច តែបារាំងបំភ្លេចរឿងសាលាអប់រំដែលមាននៅខ្សោយ គ្មានប្រសិទ្ធិភាពមកដល់បច្ចុប្បន្នកាលសព្វថ្ងៃ។

នៅឆ្នាំ១៦០០ឡើង ទឹកដីដែលយើងស្គាល់ជាប្រទេសវៀតណាមសព្វថ្ងៃមានការបែកបាក់សង្គ្រាមគ្នាឯងរវាង រាជាធិរាជ ទ្រិញ ផ្នែកខាងជើង និង រាជាធិរាជ ង្វៀង ផ្នែកកណ្ដាល (ខាងត្បូងគឺខ្មែរកម្ពុជាក្រោម)។ រាជាធិរាជ ង្វៀង លើកកូនក្រមុំថ្វាយស្ដេចខ្មែរកម្ពុជា ជាសំណាងសុំសិទ្ធិឲ្យប្រជាជន

យួនរស់នៅលើទឹកដីខ្មែរក្រោម។ រាជាធិរាជយួន ចាប់ផ្តើមធ្វើការពង្រីកជំហ៊រ ការឃោសនាពង្រីកទឹកដី ជាភាសាយួនហៅថា "ណាំទាន" ឬ "ការឈានជំហ៊ានទៅទិសខាងត្បូង"។ នៅឆ្នាំ១៦៩៨ ក្រោយពីព្រះរាជាខ្មែរត្រូវសុវណ្ណគតទៅ ប្រជាជនយួន ៩០,០០០ នាក់ ចូលមករស់នៅៗលើដីកម្ពុជាក្រោម ប្រជាជនខ្មែរកម្ពុជាក្រោមត្រូវធ្លាក់ទៅប្រជាជនភាគតិចវិញពីពេលនោះមកនៅលើទឹកដីរបស់ខ្លួនផ្ទាល់។ ប្រជាជនយួនចាប់តាំងរដ្ឋាភិបាលត្រួតត្រារបស់ខ្លួន បង្ខំជនជាតិខ្មែរឲ្យចូលជាតិយួន ចេញប័ណ្ណដូរឈ្មោះអ្នកដើមកំណើតឈ្មោះខ្មែរ ទៅជាភាសាយួន ដើម្បីស្រួលចំណាំទៅថ្ងៃក្រោយ។ នៅចន្លោះឆ្នាំ ១៨១៣ និង ១៨២០ ជាតិយួនបង្ខំឲ្យជីកព្រែកឲ្យឈ្មោះថាព្រែក វៀតតេ បាំងកាត់កម្ពុជាលើ និង កម្ពុជាក្រោមឲ្យដាច់។ មានប្រជាជនខ្មែរក្រោមរាប់ពាន់អ្នកបង្ខំឲ្យជីកព្រែក មានចែកជាក្រុមៗ ២០-៩០នាក់ ត្រូវទុកឲ្យលិចទឹកស្លាប់ពេលដែលព្រែកបង្ហូរទឹកឲ្យចូល នៅចុងបញ្ចប់ដោយចេតនា។ ប្រជាជនខ្មែរក្រោមខ្លះដែលហ៊ានតវ៉ា ត្រូវយួនចាប់ជីកកប់ដងខ្លួនទាំងរស់ដល់កយកក្បាលធ្វើជាមុមចង្ក្រាន បង្កាត់ភ្លើងដាំទឹកធ្វើតែផឹក។ កូនគិតមើលតើមនុស្សរស់ត្រូវកំដៅភ្លើងឆេះក្បាល តើវាក្តៅ យ៉ាងណា?

នៅឆ្នាំ ១៨៥៦ ព្រះរាជាខ្មែរជួបជាសម្ងាត់ជាមួយបារាំងសុំទឹកដីកម្ពុជាក្រោមមកឲ្យខ្មែរវិញ។ បារាំងអ៊ីអើតែមាត់ បំភ្លេចពាក្យសន្យា ទុកដីកម្ពុជាសំរាប់ខ្លួនឯង ហើយឲ្យឈ្មោះថ្មីទៅកម្ពុជាក្រោមថា កូសាំងស៊ីន។ នៅក្រោមអាណានិគមបារាំង ខ្មែរក្រោមបើកឲ្យមានសិទ្ធិទូលាយបន្តិច ប៉ុន្តែតាមពិតបារាំងចូលចិត្តជាតិយួនជាង ប្រើប្រាស់ជាតិយួនជាអ្នកកាន់ច្បាប់ត្រួតត្រា ឯជនជាតិខ្មែរមិនរាប់រកឲ្យលើសឋានៈជាគូលីកម្មករទេ។ នៅឆ្នាំ១៩៤៩ រដ្ឋសភាជាតិរបស់ប្រទេសបារាំង ត្រូវកាត់សេចក្តីទៅលើទឹក

ដី កូសាំងស៊ីន។ មិនស្តាប់ការតវ៉ាអំពីប្រតិភូខ្មែរ រដ្ឋសភាបារាំងកាត់សេចក្តីឲ្យទឹកដី កម្ពុជាក្រោមទៅយួន នៅថ្ងៃទី៤ខែមិថុនាឆ្នាំ១៩៤៩។ ក្នុងការកាត់សេចក្តីក៏តម្រូវឲ្យយួនទទួលស្គាល់កម្មសិទ្ធខ្លះរបស់ប្រជាជនខ្មែរ។ ប៉ុន្តែ ផ្ទុយទៅវិញមកដល់ ឥឡូវប្រជាជនខ្មែរត្រូវយួនហាមមិនឲ្យប្រកាន់ទំនាមទំលាប់ខ្មែរ រក្សាអក្សរសាស្ត្រវប្បធម៏ខ្មែរ។

ជីតារបស់កូន តា ថាច់ចាន់ មានកំណើតនៅកម្ពុជាក្រោម អំពីអ្នកគ្រួសារខ្មែរសុទ្ធៗ រកស៊ីធ្វើស្រែ ដាំបន្លែ ធ្វើនេសាទនៅទន្លេមេកុង។ គាត់បានជ្រើសរើសឲ្យចូលធ្វើទាហានបារាំង ដោយឧត្តមសេនីយបារាំង។ គាត់បានឡើងសក្តិ យ៉ាងឆាប់រហ័សក្នុងកងទ័ព។ គាត់បានសិក្សានៅក្នុងកងយោធាវិជ្ជាស្ថានប្រទេសខ្មែរ គាត់ចេះភាសាបារាំងយ៉ាងស្ទាត់ គាត់ត្រូវបានបារាំងបញ្ជូនឲ្យទៅសិក្សានៅប្រទេសបារាំង។ គាត់បានកាន់កាប់កិច្ចការដ៏ធំៗនៅ ក្រសួងមេបញ្ជាការ **(Etat Major** ជាពាក្យបារាំង) ជំនាន់សង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ក្នុងកងទ័ពដែលមានឈ្មោះជា **FARK (the *<u>Force Armée Royal Khmère</u>*,** ក្រោមការដឹកនាំ សម្តេចព្រះនរោត្តមស៊ីហានុ) ក្រោយមកក្នុងកងទ័ព **FANK (the *<u>Force Armée Nationale Khmère</u>*,** ក្រោមរបបសាធារណៈរដ្ឋ ដឹកនាំដោយលោក លន់ណុល (១៩៧០-៧៥) ធ្វើជានាយកក្រសួងស៊ើបអង្កេត (ប៊ុយរ៉ូទី២)។ គាត់បានធ្លាប់ចាប់ចងមេបញ្ជាការខ្មែរក្រហម ដែលនៅពេលនោះប្រឆាំងនិងសម្តេចនរោត្តមស៊ីហានុ ដូចជា សាឡុតស (ក្រោយមកដូរឈ្មោះទៅ ប៉ុលពត), ហ៊ូយន់, ហ៊ូនឹម, អៀងសារី, និង ខៀវសំផនជាដើម។ គាត់បានរដ្ឋាភិបាលបញ្ជាឲ្យកាន់កាប់ កាសែតរដ្ឋជាភាសាខ្មែរ ចំណោះដែលគាត់ចេះធ្វើកាសែតនៅ ម៉ុងត្រេអាល ប្រទេសកាណាដា ពេលដែលគាត់រ៉ីត្រែតនៅថ្ងៃក្រោយ។ ធ្វើមេបញ្ជាការកងពលធំលេខ២២ កាន់កាប់ការពារផ្នែកខាងកើតប្រទេសខ្មែរ តទល់និង

យួនខាងជើងដែលពួននៅលើទឹកដីខ្មែរវាយសង្គ្រាមជាមួយយួនខាងត្បូង និងកងទ័ពអាមេរិកាំង។ គាត់ត្រូវបានឡើងសក្តិជាវរសេនីយឯក។ គាត់ធ្លាប់រស់នៅៗកម្ពុជាក្រោម ចេះភាសាយួន ងាយនិងទាក់ទងជាមួយកងទ័ពយួនខាងត្បូងដែលកំពង់ដេញយួនខាងជើងលើទឹកដីខ្មែរ។

តាមានមិត្តច្រើនណាស់រស់នៅក្នុងសហរដ្ឋ កាណាដា និង ប្រទេសបារាំង ភាគច្រើនខ្មែរកម្ពុជាក្រោម។ តាចូលចិត្តធ្វើនយោបាយណាស់ក្រោយពីរ៉ិត្រែតហើយ។ ពីឆ្នាំ២០០០ឡើងមកនេះ ជនជាតិខ្មែរក្រោមដែលរស់នៅបរទេសទាំងអស់ បោះឆ្នោតឲ្យគាត់ធ្វើជាប្រធានាធិបតីដំណាងអ្នកនយោបាយខ្មែរកម្ពុជាក្រោម។ រួចហើយសាកល្បងធ្វើញត្តិទាមទារសុំអង្វរ ឲ្យអង្គការសហប្រជាជាតិ ទទួលស្គាល់ខ្មែរក្រោមជាជនភាគតិចរស់នៅប្រទេសវៀតណាម។ ធ្វើដូចនេះឲ្យយួនទទួលស្គាល់សិទ្ធិរស់នៅរបស់ខ្មែរក្រោម សង្ឃឹមថ្ងៃណាមួយនិងអាចទាមទារឯករាជ្យយកទឹកដីមកវិញ។ សព្វថ្ងៃតាមានអាយុ៨៩ឆ្នាំហើយៗក៏ឈប់ធ្វើនយោបាយដែរ គាត់មិនអាចសរសេរ ឬ អានបានច្រើនទៀតទេ។

រហូតមកដល់ពេលសព្វថ្ងៃនេះ ឆ្នាំ២០១៣ៈ ប្រទេសថៃនិងយួននៅតែ ឆ្លៀតចង់លួចទឹកដីខ្មែរមិនឈប់ឈរ។ ភស្តុតាងព្រឹត្តិការណ៏ដែលទើបនិងកើតឡើងថ្មីៗនេះ ប្រទេសថៃទាមទារថា "ព្រះវិហារ "ដែលនៅជាប់ព្រំប្រទល់ខ្មែរ-ថៃជារបស់ថៃៗបញ្ជូនទាហាន បាញ់ផ្លោងចូល កំញើញទាហានខ្មែរឲ្យដើរចេញ ទុកឲ្យថៃយក។

## ប្រាសាទព្រះវិហារ ត្រូវប្រទេសថៃធ្វើជម្លោះជណ្តើមចង់បានរហូតមកដល់សព្វថ្ងៃ



***ទាហានខ្មែរម្នាក់ កំពង់យាមល្បាត ប្រាសាទព្រះវិហារ ដែលជាកេរ្តិ៍ដំណែលខ្មែរ តាំងពីសតវត្សទី១១***

រហូតមកដល់ពេលសព្វថ្ងៃនេះ ឆ្នាំ២០១៣: ប្រទេសយួន នៅតែឆ្លៀតចង់លួចទឹកដីខ្មែរមិនឈប់ឈរ បញ្ជូនជនជាតិយួនឲ្យមករស់នៅក្នុងទឹកដីខេត្រខ្មែរតាមព្រំប្រទល់យួន-ខ្មែរ ឲ្យធ្វើស្រែ ធ្វើចំការ។ គឺជាជំហានទី១នៃការសម្រុកចូលទាំងហ្វូងៗ ដូចភស្តុតាងព្រឹត្តិការណ៏ដដែលកើតឡើងនៅកម្ពុជាក្រោមក្នុងឆ្នាំ១៦៩៨ បន្តិចទៅប្រទេសខ្មែរនិងបាត់បង់ខេត្រទាំងឡាយនៅផ្នែកខាងកើតជាប់ដីយួន។




ដូច្នេះការលេបទឹកដីអំពីខាងកើតនិងខាងលិចមកលើប្រទេសខ្មែរមិនទាន់ចប់នៅឡើយទេមកដល់សព្វថ្ងៃ។ ប្រវត្តិសាស្ត្រថ្ងៃមុខនិងប្រាប់យើងអំពីការពិត។

# ជំពូក ទី៥

## ប្រទេសកម្ពុជា ១៩៥៣-១៩៧០ (រាជាណាចក្រខ្មែរ)

ក្នុងឆ្នាំ១៩៥៣ ប្រទេសកម្ពុជាលៃលករកបានឯករាជ្យបាន បណ្តោះខ្លួនចេញពីសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) និង សង្គ្រាមឥណ្ឌូចិនទី១ (១៩៤៦-១៩៥៤)។ ដោយសាការដឹកនាំវៃឆ្លាតរបស់ព្រះបាទនរោត្តមសីហនុ ព្រះអង្គទាមទារឯករាជ្យបានអំពីប្រទេសបារាំង។ ក្រោយពីបានឯករាជ្យ ព្រះអង្គដាក់រាជ្យចុះ ហើយចូលធ្វើនយោបាយជាពេញទី។ ព្រះអង្គចាប់ផ្តើមបង្កើតក្រុមនយោបាយឲ្យឈ្មោះថា សង្គមរាស្ត្រនិយម ដែលបានឈ្នះឆ្នោត ទទួលសន្លឹកឆ្នោតដ៏លើសលប់នៅឆ្នាំ១៩៥៥។ តាមការសង្កេតការណ៏របស់ជនបរទេសថា ព្រះអង្គឈ្នះដោយសារមានប្រជាប្រិយ៏ និង ការសម្លុតកំហែងរបស់ អាជ្ញាធម៏ ប៉ូលីសនៅរោងបោះឆ្នោត។

នេះជាសម័យឪពុកចាប់ផ្តើមសាលា (១៩៥៥-១៩៧០)។ យើងក្មេងៗមិនយល់សោះនយោបាយ។ ប្រទេសកម្ពុជាទើបនិងបានឯករាជ្យ អស់មានសង្គ្រាម។ គឺជាពេលដែលប្រជាពលរដ្ឋខ្មែរត្រូវសប្បាយទាំងអស់គ្នា។

នៅឆ្នាំ១៩៦០ ពេលដែលព្រះបីតាព្រះអង្គចូលសុវណ្ណគតទៅ ព្រះអង្គមានព្រះនាមជាអ្នកដឹកនាំប្រទេសកម្ពុជា រហូតដល់មាននាមជានាយករាជមន្ត្រីផង។ ព្រះអង្គបានប្រកាសកាន់នយោបាយអន្តរជាតិជាផ្លូវកណ្តាលមិនចូលបក្សណា ក្នុងការប្រយុទ្ធប្រទល់រវាង សហរដ្ឋអាមេរិក និង សហភាពសូវៀតលើ ផ្ទៃពិភពលោក។ ប៉ុន្តែផ្ទុយទៅវិញនៅឆ្នាំ១៩៦៥

ព្រះអង្គទាត់ចោលផ្លូវទូតសហរដ្ឋអាមេរិក។ ក្នុងពេលជា១គ្នា នេះព្រះអង្គអនុញ្ញាតិឲ្យប្រទេសយួនកុម្មុយនីស្តចូល ជ្រកកោនពួននៅលើទឹកដីខ្មែរធ្វើចំបាំងជាមួយយួនខាងត្បូងនិងសហរដ្ឋអាមេរិក។

ជាចុងក្រោយដោយសេដ្ឋកិច្ចប្រទេសជាតិត្រូវចុះដុនដាប គ្មានប្រាក់កាស ព្រះអង្គបង្គាប់ ឲ្យមានការទាក់ទងដាក់ទូតជាមួយសហរដ្ឋអាមេរិកវិញ។ ក្នុងពេលជា១នេះដែរសហរដ្ឋរៀបចំផែនការសម្ងាត់ទម្លាក់គ្រាប់បែកលើ ជំរកយួនកុម្មុយនីស្តនៅលើទឹកដីខ្មែរ។

## ការប្រជុំនៅក្រុង ហ្សឺណែវ និង ការរាតត្បាតយួនយៀកមិញ

ថ្វីបើប្រទេសខ្មែរបានឯករាជ្យ នៅឆ្នាំ១៩៥៣ កងទ័ពខ្មែរនៅបែកបាក់គ្នា មិននៅជាធ្លុង១។ កងទ័ពមិនមែនកុម្មុយនីស្ត ខ្មែរអ៊ីសារ៉ាក់បានសុខចិត្តចូលរួមជាមួយរាជដ្ឋាភិបាលប៉ុន្តែខ្មែរចូលចិត្តវៀតមិញមិនព្រមចុះចូល។ នៅខែមេសា ឆ្នាំ១៩៥៤កងទ័ពយៀកមិញជាច្រើនកងពលតូច ឆ្លងព្រំប្រទល់យួនខ្មែរ មកតាំងទីនៅលើទឹកដីខ្មែរ។ កងទ័ពរាជដ្ឋាភិបាល FARK ធ្វើចំបាំងបណ្តេញទ័ពយៀកមិញ ប៉ុន្តែមិនបានសំរេច។ តាមការពិតយកលេសដែលខ្លួនមាននៅលើទឹកដីខ្មែរ តវ៉ានៅការប្រជុំនៅហ្សឺណែវ យកចំណេញដល់ប្រយោជន៏ខ្លួនថែមទៀត។ គឺជាការប៉ិនប្រសប់១រកស្មានមិនឃើញមុន។

ការប្រជុំនៅហ្សឺណែវនៅចុងខែមេសា មានប្រទេស ខ្មែរ វៀតណាមខាងជើង (យៀកមិញ) វៀតណាមខាងត្បូង លាវ ចិន សូវៀត បារាំង អង់គ្លេស និង សហរដ្ឋអាមេរិក។ ការចាប់ផ្តើមនិយាយអំពីឥណ្ឌូចិន នៅថ្ងៃ ទី៨ឧសភា ១៩៥៤។

ភ្លាមនោះប្រទេសយួនខាងជើងសុំឲ្យមាន អ្នកដំណាងកុម្មុយនីស្តនៅយួនខាងត្បូងមានសំឡេង ការស្នើត្រូវទាល់ចោល។ នៅថ្ងៃទី២១ ខែកក្កដា ១៩៥៤ ការប្រជុំសំរេចចិត្ត ដូចតទៅសំរាប់ ប្រទេសកម្ពុជាៈ
កងទ័ពយៀកមិញទាំងអស់ត្រូវដកថយចេញពីទឹកដីខ្មែរក្នុងរយៈ៩០ថ្ងៃ
កងទ័ពខ្មែរចូលចិត្តយៀកមិញត្រូវរំលាយក្នុងរយៈ៣០ថ្ងៃ (នេះគ្រាន់តែលើក្រដាស់ស្នាម ប្រវត្តិសាស្ត្របង្ហាញ ខ្មែរយៀកមិញ គឺរបប ហ៊ុនសែន កាន់កាប់ប្រទេសខ្មែរសព្វថ្ងៃ ពីឆ្នាំ១៩៧៩-ដល់ឥឡូវ)។ នៅក្នុងការព្រមព្រាង១ដាច់គ្នា អ្នកដំណាងប្រទេសខ្មែរ បារាំង និង វៀតមិញ ស៊ីញ៉េសុខចិត្តដកថយអំពីទឹកដីខ្មែរនៅខែតុលា ១៩៥៤។ ក្នុងការព្រមព្រាងដកថយយៀកមិញសុំឲ្យអង្គប្រជុំសំរេចការ ថា ប្រទេសខ្មែរ និង លាវ នៅជាអ្នកកណ្តាល គឺមិនឲ្យមានមហាអំណាចប្រទេសណាសង់មូលដ្ឋានយោធានៅលើទឹកដីប្រទេសទាំងពីរ។ នៅពេលរាត្រីមុនថ្ងៃអង្គប្រជុំសំរេច លោក សំសារី (អតីតមេអ្នកដឹកនាំខ្មែរសេរី កងទ័ពខ្មែរអ៊ីសារ៉ាក់ដែលទើបចុះចូលជា១រាជដ្ឋាភិបាល) ជាអ្នកដំណាងប្រតិភូខ្មែរតវ៉ាថា បើប្រទេសកម្ពុជានិងបានឯករាជ្យដ៏បរិសុទ្ធ គឺមិនត្រូវឲ្យមានការសំរេចដូច្នេះឡើយ ពីព្រោះប្រទេស កម្ពុជានិងមានសិទ្ធិឯករាជ្យរុករកជំនួយអំពី មហាអំណាចណាក៏បានតាមចិត្ត។ អង្គប្រជុំយល់ស្រប‌លោក សំសារី ផ្ទុយទៅវិញមានការខឹងមហិមាអំពី វៀតណាមខាងជើង (តាមពិតប្រទេសខ្មែរទើបតែសុំជំនួយពេលមុនបន្តិចនេះអំពី សហរដ្ឋអាមេរិក)។ ប៉ុន្តែនៅការសំរេចចុងក្រោយបង្អស់ ពេលវែកញែកពីពាក្យនៅជាកណ្តាលមិនចូលបក្សណារបស់ប្រទេសខ្មែរៗបានស្បថសន្យាថាមិនចូលបក្សណា ទាំងយោធា និង មិនឲ្យមហាអំណាចតែងតាំងមូលដ្ឋានសង្គ្រាមលើទឹកដីខ្លួន ទៅតាមច្បាប់អង្គការសហប្រជាជាតិ។ យួនយៀកមិញឈ្នះ។

ការជំនុំក្រុងហ្សឺណែវសំរេចឲ្យមានគណៈកម្មការប្រទេសក្រៅមើលត្រួតត្រាឲ្យមានការ ឈប់បាញ់គ្នា ការដកថយកងទ័ពបរទេស ការប្តូរអ្នកជាប់ទោសពេលសង្គ្រាម។ ប្រទេសចាត់ចែងនេះ មាន កាណាដា ប៉ូឡូញ និង ឥណ្ឌា។

## *សកម្មភាពកើតឡើងក្នុងផ្ទៃក្នុងប្រទេសខ្មែរ*

ការជំនុំក្រុងហ្សឺណែវក៏សំរេចឲ្យមានការបោះឆ្នោតជាទូទៅនៅប្រទេសកម្ពុជាដែរក្នុងឆ្នាំ១៩៥៥ដែលមានគណៈកម្មការប្រទេសក្រៅមើលត្រួតត្រាឲ្យមានការយុត្តិធម៏។ ព្រះបាទនរោត្តមសីហនុបានប្តេជ្ញាព្រះទ័យជាដាច់ខាតនិងបង្កើតគណៈបក្សនយោបាយឲ្យឈ្នះ គណៈបក្សនយោបាយប្រជាធិបតេយ្យឯទៀត។ ព្រះអង្គសាកល្បងនិងដូរច្បាប់រដ្ឋធម្មនុញ្ញ មិនបានសំរេច។ នៅថ្ងៃទី២ខែមិនា ១៩៥៥ ព្រះអង្គដាក់រាជ្យចុះ ប្រគល់រាជ្យថ្វាយទៅព្រះបិតា ព្រះនរោត្តមសូរាមិរិទ្ធ។ យកព្រះនាមជា សម្តេច (ព្រះអង្គម្ចាស់) បង្កើតគណៈបក្សនយោបាយឲ្យឈ្មោះ សង្គមរាស្រ្តនិយម ។ គឺជាគណៈបក្សដែលមានសមាជិកភាគច្រើនមកពីខាងស្តាំ (ចូលចិត្តបច្ចិមប្រទេសឬមូលធននិយម) ដែលប្រឆាំងនិងគណៈបក្សខាងឆ្វេង (ចូលចិត្តកុម្មុយនីស្ត)។ នៅដើមឆ្នាំ១៩៥៥ គណៈបក្សសង្គមរាស្រ្តនិយមឈ្នះឆ្នោត ៨៣% លើគណៈបក្សប្រជាធិបតេយ្យ២ គឺគណៈបក្សខ្មែរឯករាជ្យ (មូលធននិយម) របស់លោកសឺង៉ុកថាញ់ និង គណៈបក្សប្រជាជន (កុម្មុយនីស្ត)។ គណៈបក្សសង្គមឈ្នះអស់កៅអីនៅរដ្ឋសភាទាំងមូល។

លទ្ធផលនៃការបោះឆ្នោតឆ្នាំ១៩៥៥ បានធ្វើដោយមានការលួចបន្លំសន្លឹកឆ្នោត ការគំរាមកំហែង។ ប្រជាជនអ្នកបោះឆ្នោតត្រូវគេកំញើញ ដាក់

ឲ្យមានសន្លឹកឆ្នោតបោះជាពណ៌ មានអ្នកឈរមើលខាងសង្គម មានអាជ្ញាធម៌ មានប៉ូលីស តាមមើលជានិច្ច។ មានប្រការជាច្រើន ក្នុងជំបន់វៀតមិញកាន់កាប់ជាច្រើនឆ្នាំ គ្មានសន្លឹកឆ្នោត១សន្លឹកសោះបោះឲ្យគណៈបក្សខាងឆ្វេង ធុងប្រអប់ឆ្នោតត្រូវបានប្តូរ។ អ្នកសរសេរប្រវត្តិសាស្ត្រ ហ្វីលីពស្ទ្រាត បានសរសេរបង្ហាញថានៅឆ្នាំ១៩៥៧ សម្តេចនរោត្តមសីហនុបានធ្វើការសារភាពថាមានជំបន់៣៦សង្កាត់បោះឆ្នោតឲ្យគណៈបក្សប្រជាជន (កុម្មុយនីស្ត) ប៉ុន្តែតាមការរាប់សន្លឹកឆ្នោតជា ផ្លូវការគ្មាន១សន្លឹកសោះបោះទៅគណៈបក្សខាងឆ្វេង។

ជនជាតិខ្មែរដែលជាអ្នកស្នេហាជាតិ ជាអ្នកមានភក្តីភាពទៅរាជាមហាក្សត្រ មានការមិនសប្បាយចិត្តនិង សង្គមគ្មានយុត្តិធម៌ មានការពុករលួយ និងការយកព្រះពុទ្ធសាសនា ជាគោលប្រធានមនោគមវិជ្ជាបកស្រាយសំរាប់ការ ប្រើប្រាស់ក្នុងសង្គម។ គណៈបក្សសង្គមអនុវត្តតាមភាពមិនផ្លាស់ប្តូរ តាមព្រះពុទ្ធសាសនា ថេរ៉ាវ៉ាដា ដែលមានកាន់គ្រប់ប្រទេសអាស៊ីភាគអាគ្នេយ៍ពុទ្ធសាសនា (ថៃ លាវ ភូមា និង ខ្មែរ)។ ថេរ៉ាវ៉ាដាពុទ្ធសាសនាបង្រៀនថា ការមិនស្មើឋានៈគ្នាក្នុង សង្គមរស់នៅ និងសង្គមសេដ្ឋកិច្ច គឺមកពីធម៌ព្រះពុទ្ធ កាមា (កម្ម)។ អ្នកដែលក្រីក្រសព្វថ្ងៃមកពីបុណ្យទានដែលបានធ្វើពីជាតិមុន បើរស់នៅជាពលរដ្ឋគំរូគោរពច្បាប់ មិនខ្ជិល មិនធ្វើអាក្រក់ និងមានសំណាងកើតឡើងជាជីវិតថ្មីទៅជាអ្នកមានវណ្ណៈនិងឋានៈលើក្នុងសង្គម។

ក្នុងខែសីហាឆ្នាំ១៩៥៧ សម្តេចនរោត្តមសីហនុ កោះហៅអ្នកដឹកនាំគណៈបក្សប្រជាធិបតេយ្យទាំងប៉ុន្មានទៅជំនុំ ចចារ នៅព្រះបរមរាជវាំង។ អ្នកដឹកនាំទាំងនោះត្រូវសម្តេច ចំអកឡកលើយ និយាយបង្អាប់បន្ទោសអស់រយៈពេល៥ម៉ោង នៅចំពោះមុខវេទិការប្រជាជនជាសាធារណៈ។

ក្រោយពីប្រជុំហើយ អ្នកដឹកនាំទាំងនេះត្រូវ ប៉ូលីស និង កងឃោឃា របស់សម្ដេចចាប់ អូសចេញពីរថយន្តរបស់ខ្លួន វាយតប់បុកនិងត្រាកាំភ្លើង។

នៅជិតពេលៗនេះដែរ គណៈបក្សប្រជាជនតែងតាំងបេក្ខជន៥នាក់ឲ្យឈរឈ្មោះបោះឆ្នោត ប្រឆាំងនិងសម្ដេច។ សម្ដេចយាងទៅឃោសនាផ្ទាល់ដល់សង្កាត់បោះឆ្នោតទាំងនេះ (សង្កាត់កុម្មុយនីស្តៈ ស្ទឹងត្រែង ក្រចេះ ព្រៃវែង ស្វាយរៀង តាកែវ កំពត ជាដើម)។ វិទ្យុជាតិផ្សាយឃោសនាអំពីបេក្ខជនគណៈបក្សប្រជាជន ជាអ្នកលក់ជាតិ លក់ខ្លួនឲ្យប្រទេសយួន។ បដាបិទគ្រប់ទិសនៃសង្កាត់ទាំងនេះ បង្ហាញកំញើញប្រជាជនឲ្យឃើញលទ្ធផលអាក្រក់ ព្យរក បើបោះឆ្នោតឲ្យសត្រូវ។ ក្នុងទីបំផុតបេក្ខជន៤នាក់ដកឈ្មោះចេញឈប់ឈរ។ នៅសល់បេក្ខជនម្នាក់នៅឈរ ក្រោយពីបោះឆ្នោតហើយរាជដ្ឋាភិបាលប្រកាសថាបេក្ខជននេះបានសន្លឹកឆ្នោត ៣៩៦ ក្នុងចំណោមប្រជាជន ៣០,០០០ នាក់ ហើយដែលស្ថិតនៅសង្កាត់កុម្មុយនីស្ត។ មកដល់ចាប់ផ្ដើមឆ្នាំ១៩៦០ គណៈបក្សនយោបាយទាំងឡាយដែលប្រឆាំងនិងគណៈបក្សសង្គមរាស្ត្រនិយម ត្រូវបិទអស់ នៅល្មួចបើកក្រោមដី។ តាមអ្នកសរសេរប្រវត្តិសាស្ត្រ វិគើរី គណៈបក្សប្រជាធិបតេយ្យឯទៀតត្រូវរលប់ចោលក្រោយអំពីអ្នកដឹកនាំត្រូវវាយតប់ក្រោយពីជំនុំជាមួយសម្ដេចឆ្នាំ១៩៥៧។ អ្នកដឹកនាំខ្លះសុំចុះចូលជាសមាជិកគណៈបក្សសង្គមរាស្ត្រនិយម។

ថ្វីបើការប្រកាសជាក់ស្ដែងថាសង្គមការពារប្រយោជន៏ប្រជាជនខ្មែររាស្ត្រខ្មែរជាទូទៅ គណៈបក្សមិនមានតែសមាជិកខាងស្ដាំទេ សម្ដេចបានអញ្ជើញសមាជិកខាងឆ្វេង ដូចជា ហ៊ូនឹម ហ៊ូយន់ ខៀវសំផន ដែលជាមេដឹកនាំខ្មែរក្រហមនៅថ្ងៃក្រោយឲ្យចូល ធ្វើជារដ្ឋមន្ត្រី រវាងឆ្នាំ១៩៥៨ និង

១៩៦៣ ជួយជាជញ្ជើងទប់ទល់និងអ្នកខាងស្តាំ។ ខៀវសំផន ធ្លាប់បានបំរើជារដ្ឋមន្ត្រី ពាណិជ្ជកម្ម ឆ្នាំ១៩៦៣។

ប៉ុន្តែគណៈបក្សខាងឆ្វេងនៅតែជា តំរ៉ុយ ដែលគេបំរុងនិងបំផ្លាញចោលជានិច្ច។ នៅថ្ងៃទី៩ខែតុលាឆ្នាំ១៩៥៩ ចាងហ្វាងបោះពុម្ពផ្សាយកាសែត ប្រចាំអាទិត្យប្រជាជន ឈ្មោះ នុបបូផាន់ ត្រូវ ប៉ូលីសរដ្ឋាភិបាលសន្តិសុខ បាញ់សម្លាប់ នៅមុខហាងកាសែត។ នៅឆ្នាំ១៩៦០ មានប្រជាជន ២០០០ នាក់ ត្រូវចាប់ចងសង្ស័យធ្វើនយោបាយ ដាក់គុកនៅតង់នៅខាងក្រៅ រាជធានីភ្នំពេញ។ ប៉ូលីសរដ្ឋាភិបាលសន្តិសុខត្រូវកាន់កាប់ដោយមន្ទីរ កាត់សេចក្តីកងទ័ព ដូច្នេះគឺគ្មានការប្តឹងទៅសាលាឧទ្ធរណ៏ទៅលើទៀតទេ។ ប៉ូលីសរដ្ឋាភិបាលសន្តិសុខ កាត់សេចក្តីបាញ់សម្លាប់មនុស្សជាង ៣០ នាក់ ក្នុងរយៈពេល៦ខែ គឺជាការឲ្យបញ្ជាផ្ទាល់ពីសម្តេចសីហនុ។

នៅឆ្នាំ១៩៦០ ចាងហ្វាងកាសែត *អ្នកសង្កេតការ* **l'Observateur** ត្រូវ ប៉ូលីសរដ្ឋាភិបាលសន្តិសុខវាយ សំរាតខោអាវ  នៅជិតមន្ទីរមេបញ្ជាការ ប៉ូលីស។ ចាងហ្វាងកាសែតប្តឹងប៉ូលីស។ រដ្ឋសភាកោះហៅរដ្ឋមន្ត្រី ក្រសួងសន្តិសុខ មកពន្យល់អំពី សកម្មភាពរបស់ប៉ូលីស។ រដ្ឋមន្ត្រីឆ្លើយ ថាគឺជាមុខការរបស់ប៉ូលីស ការពារសន្តិសុខដល់អ្នកដែលប្រឆាំង និងរាជដ្ឋាភិបាល។ រួចហើយរដ្ឋមន្ត្រី ចាប់រាយឈ្មោះសមាជិករដ្ឋសភា ដែលប្រឆាំងនិងរាជដ្ឋាភិបាល។ ក្នុងនោះ មានឈ្មោះអ្នកដំណាងរាស្ត្រ អ៊ុចវ៉េន ដែលជាអ្នកបង្កហេតុរករឿងដល់មន្ត្រីរាជដ្ឋាភិបាលក្នុងរឿងនេះ។ សម្តេចសីហនុបញ្ចេញសេចក្តីថ្លែងការណ៏បន្ទោសសមាជិករដ្ឋសភាដែល ធ្វើសេចក្តីប្រមាថដល់ប៉ូលីសរដ្ឋាភិបាលសន្តិសុខ។ ពីរបីថ្ងៃក្រោយមក ហាងកាសែត

អ្នកសង្កេតការ និង ហាងកាសែត២ទៀតត្រូវបិទទ្វារ។ មនុស្ស៥០នាក់ត្រូវគេចាប់ចងជាមួយគ្នានេះដែរមិនលែងវិញសោះ។ ចាងហ្វាងផ្ទាល់កាសែតគណៈបក្សសង្គមរាស្ត្រនិយមត្រូវដេញចោល ដោយហ៊ានសរសេរទិទានការបិទកាសែតអ្នកប្រឆាំង។

នៅខែកក្កដា ១៩៦២ មេអ្នកដឹកនាំខាងឆ្វេងម្នាក់ឈ្មោះ ទូសាមុត ត្រូវប៉ូលីសរដ្ឋាភិបាលសន្តិសុខចាប់ពេលគាត់ទៅទិញថ្នាំឲ្យកូនផឹកនៅទីផ្សារ។ ប៉ូលីសរដ្ឋាភិបាលសន្តិសុខ ចាប់ទុកឃុំឃាំង ទូសាមុត នៅទីសម្ងាត់១វាយសួរចម្លើយ ហើយត្រូវសម្លាប់ចោល បោះខ្មោចចោលនៅមន្ទីរចាក់ចោលសំរាមនៅស្ទឹងមានជ័យ សង្កាត់១ក្នុងរាជធានីភ្នំពេញ។

នៅខែមិនាឆ្នាំ១៩៦៣ សម្តេចសីហនុបោះផ្សាយឈ្មោះមនុស្សខាងឆ្វេង៣៤នាក់។ សម្តេចចោទថាពួកនេះ ជាមនុស្សកំសាក លាក់ពុត ធ្វើការបំផ្លិចបំផ្លាញជាអាថ៌កំបាំង ធ្វើជាភ្នាក់ងារវិទ្ធង្សនា ហើយជាអ្នក ក្បត់ជាតិ។ សម្តេចកោះឲ្យប្រជុំពួកនេះ សុំឲ្យពួកនេះបង្កើត រដ្ឋាភិបាល។ បន្តិចក្រោយមកពួកនេះស៊ីញ៉េលើក្រដាស់ថា មានតែសម្តេចទេ ដែលអាចដឹកនាំប្រទេសបាន។ ក្រោយពីពេលនេះមក មាន ប៉ូលីសយាមនៅគ្រប់ផ្ទះអ្នកដឹកនាំទាំងនេះ សូម្បីកន្លែងធ្វើការក៏មាន ប៉ូលីសយាមដែរ។ តាមការពិតពួកអ្នកដឹកនាំទាំងនេះនៅក្រោម ការឃុំទុកក្នុងផ្ទះ។

លទ្ធផលតឹងតែងឆ្នាំ១៩៦២និង១៩៦៣ ធ្វើឲ្យមានចលនាក្រោមដីកើតឡើងក្រៅពីទីក្រុង នៅទីប្រជុំជនស្រុកជនបទ។ សូម្បីមានចលនាក្រោមដីកើតឡើង ឬសិទ្ធិបង្កើតគណៈបក្សនៅលើដីមាន គ្មានគណៈបក្សណា១ចេញមុខប្រឆាំងរាជដ្ឋាភិបាលកើត។

អកប្បកិរិយារបស់សម្តេចចំពោះពួកខាងឆ្វេង មានពេលខ្លះជាការចំអក។ ព្រះអង្គយល់ថា គណៈបក្សសង្គមរបស់ព្រះអង្គគឺជា

ជញ្ជីងថ្លឹងរវាង គណៈបក្សខាងឆ្វេងនិងគណៈបក្សខាងស្តាំ។ បើគណៈបក្សម្ខាងបំបាត់ គណៈបក្ស១ទៀត គណៈដែលឈ្នះនិងឈមមុខទល់គណៈបក្សព្រះអង្គ ហើយព្រះអង្គអាចចាញ់បាន។ ពេលខ្លះព្រះអង្គប្រកាសថាបើព្រះអង្គមិនជា ព្រះអង្គម្ចាស់ ព្រះអង្គនិងជាអ្នកបដិវត្តន៍។ ព្រះអង្គមានការសង្ស័យរាំរ៉ៃ១ អំពីសក្ដភាពសហរដ្ឋអាមេរិកនៅជំបន់អាស៊ីភាគអាគ្នេយ៏។ ព្រះអង្គមាន ការសរសើរគោរពដល់ការបដិវត្តន៏នៅប្រទេសចិន ដែលជាប្រទេស ជិតជិតនិងប្រទេសកម្ពុជាៗយូរអង្វែង។ ដោយសារមានការកោតដល់ បដិវត្តន៏ប្រទេសចិននិងមានអ្នកមានថ្វីដៃចំណានដូចជា ហ៊ូនឹម ហ៊ូយន់ ខៀវសំផន និងការយល់សប្តិរបស់ព្រះអង្គឲ្យមាន "លទ្ធិសង្គមរាជានិយម " នាំឲ្យព្រះអង្គបង្កើតគោលនយោបាយផ្ទៀងទៅលទ្ធិសង្គមនិយម។ គឺជា ការ១គួរឲ្យកត់សំគាល់ថាពេលណាដែលសម្តេចផ្ទៀងរបបទៅលទ្ធិសង្គមនិយម គឺជាការ១ដែលធ្វើឲ្យសម្តេចនិងអ្នកដើរតាមព្រះអង្គបានថ្កើងមុខ ជាអ្នកនយោបាយមានចិត្តទូលាយនិងជាមេដឹកនាំពិតៗ។ នៅឆ្នាំ១៩៦៣ សម្តេចប្រកាសយកធនាគារទាំងឡាយដាក់ជារបស់ជាតិ ពាណិជ្ជកម្មលក់ចេញទិញចូល និងក្រុមហ៊ុនធានារាប់រងដាក់ក្រោមបញ្ជាជាតិកាន់កាប់បំបាត់ជនបរទេសដែលកាន់កាប់សេដ្ឋកិច្ចខ្មែរ។ នៅឆ្នាំ១៩៦៤ ក្រុមហ៊ុនរដ្ឋជំនួញ កើតឡើង ក្រសួងពាណិជ្ជកម្មជាតិលក់ចេញទិញចូលកាន់កាប់ជំនួញជា១បរទេស។ ការប្រកាសរបស់សង្គមអំពីការបញ្ចូលជារបស់ជាតិ មកពីការចង់បំបាត់ជនបរទេស ចិន យួន ឲ្យជនជាតិខ្មែរមានមុខងារធ្វើជំនួញផ្ទាល់ គ្មានឈ្មួញអ្នកកណ្តាល បន្ថយបង់ពន្ធក្នុងការនាំចូលគ្រឿងប្រណិតៗជាដើម។ ដោយលទ្ធផលគោលនយោបាយនេះ អ្នករកស៊ីមកពីបរទេសប៉ុន្មានដកខ្លួនថយអស់ចេញពីប្រទេសខ្មែរ អំពី "លទ្ធិសង្គមញ្ញាតិនិយម " ដែលមានគំរូមិនសំរេចដូច

"លទ្ធិមូលធនញ្ញាតិនិយម" នៅប្រទេសហ្វីលីពីន របស់ប្រធានាធិបតី ហ្វែឌីណង់ម៉ាកូស។ កន្លែងរកបានកម្រៃជាច្រើនដែលកើតមកពី រដ្ឋជំនួញផ្តាច់មុខ គ្មានអ្នកប្រណាំងនិងចុះថ្លៃ បានទៅដៃអ្នកជិតដិតនិងសម្តេចដែលជីវិតយកប្រាក់ដាក់ហោប៉ៅច្រើនទៅទៀត។

សម្តេចសីហនុមានរាជដំណើរនយោបាយនេះមានការប៉ះទង្គិចជា១ពួកខាងស្តាំ។ ដើម្បីបញ្ឈប់ការទិទានដែលព្រះអង្គជាមនុស្សតែម្នាក់កាន់ការប្រទេស ព្រះអង្គប្រកាសបណ្តោយឲ្យមានបេក្ខជនមកពីគណៈបក្សឯទៀតឈរឈ្មោះបោះឆ្នោតជាសមាជិករដ្ឋសភា ខែកញ្ញា ឆ្នាំ១៩៦៦។ ការឲ្យត្រឡប់មកវិញនៅគណៈបក្សចំរុះ មានការភ្ញាក់ផ្អើលដល់អ្នកដែលមិនចូលចិត្តផ្លាស់ប្តូរ ដោយមានពួកខាងស្តាំ និង ឆ្វេងជាប់ឆ្នោតផងដែរ។ ថ្វីបើ ហ៊ូយន់ ហ៊ូនឹម និង ខៀវសំផន បានជាប់ឡើងវិញរក្សាកៅអីដដែលនៅរដ្ឋសភាលោកឧត្តមសេនីយ លន់ណុល (អ្នកខាងស្តាំ) ត្រូវជាប់ជានាយករដ្ឋមន្ត្រី។

ដោយបារម្ភថាពួកខាងស្តាំនិងធ្វើឲ្យគណៈបក្សសង្គមរបស់ព្រះអង្គបែកគ្នា ប្រឆាំងនិងសង្កត់ផ្លូវនយោបាយរបស់សង្គម សម្តេចបើក ឲ្យមាន "គណៈរដ្ឋមន្ត្រីអែប១ "សំរាប់ប្រឆាំងនិងរដ្ឋមន្ត្រីខាងស្តាំ (ដូចប្រទេសអង់គ្លេសដែលមាន "គណៈរដ្ឋមន្ត្រីស្រមោល" ពីក្រោយគណៈរដ្ឋមន្ត្រីមែនទែន) បំពេញទៅដោយអ្នកដើរតាមជិតដិតនិងព្រះអង្គនិងអ្នកដឹកនាំមកពីខាងឆ្វេង សង្ឃឹមថាពួកនេះនិងជួយទប់ទល់ រដ្ឋាភិបាលលន់ណុលកុំឲ្យមានឥទ្ធិពលពេក។ ពួកខាងឆ្វេងចាប់ផ្តើមចោទប្រកាន់លោកលន់ណុលថាស៊ុំគ្រលំជាមួយអ្នកស៊ើបការបស្ចឹមប្រទេសបំរុងនិងធ្វើបដិវត្តន៏បញ្ចេញឈាមចំបាត់ពួកកុម្មុយនីស្តខាងឆ្វេង ដូចបដិវត្តន៏ដែលលោកឧត្តមសេនីយស៊ឺហារតូ ទើបនិងធ្វើនៅប្រទេសឥណ្ឌូនេស៊ី

ដែរ។ នៅខែមេសាឆ្នាំ១៩៦៧ លោកលន់ណុលត្រូវមានគ្រោះថ្នាក់រថយន្ត លោកក៏លាលែងដំណែងនាយករដ្ឋាភិបាល។ សម្តេចតែងតាំងអ្នកជំនិតជំនួសគឺលោក សុនសាន។ នេះជាលើកទី២៣ ដែលគណៈបក្សសង្គមបាន តែងតាំងគណៈរដ្ឋមន្ត្រីជាប់គ្នាតាំងពីថ្ងៃកើតឡើងអំពីឆ្នាំ១៩៥៥។

## *គោលនយោបាយបរទេស អាជ្យាកណ្តាល មិនចូលបក្សណា*

គោលនយោបាយបរទេសរបស់សម្តេចនរោត្តមសីហនុ ដែលនៅជាអាជ្យាកណ្តាល ដុះកើតឡើងក្រោយអំពីការប្រជុំនៅក្រុងហ្សឺណែវប៉ុន្មានខែក្រោយមក ហើយដែលគេអាចយល់បានទៅ តាមប្រវត្តិសាស្ត្ររបស់ប្រទេសខ្មែរដើម្បីគង់វង់ជីវិត និងជាសវាងអំពីសង្គ្រាមយួនខាងជើងនិងយួនខាងត្បូងដែលមានរឹតតែខ្លាំងឡើង។ ក្រោយអំពីការប្រជុំនៅ ក្រុងហ្សឺណែវ ឆ្នាំ១៩៥៥ សម្តេច មានព្រះទ័យចង់ចូលរួមជាមួយ សន្ធិសញ្ញាអន្តរជាតិប្រទេសអាស៊ីភាគអាគ្នេយ៍ **Southeast Asia Treaty Organization (SEATO)** ដែលត្រូវមាន ប្រទេសខ្មែរ លាវ និងយួនខាងត្បូង។ ប៉ុន្តែក្រោយពីការជួបប្រជុំគ្នាឆ្នាំ១៩៥៥ជាមួយនាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា លោក យ៉ាវ៉ាហាឡាល់ នេរូ និងប្រមុខរដ្ឋភូមា លោក អ៊ូនូ សម្តេចស្តាប់មតិអ្នកទាំង២ផ្តាច់ចិត្តយកសភាពអាជ្យាកណ្តាល។ មានការបន្ថែមទៀតគឺសម្តេចមិនទុកចិត្តសហរដ្ឋអាមេរិកដែលជាអ្នកដឹកនាំអង្គការសន្ធិសញ្ញាអន្តរជាតិទាំងនេះ ហើយដែលមានជាតិសត្រូវ ប្រទេសថៃ និង ប្រទេសយួនខាងត្បូងជាសមាជិកផង ហើយប្រទេសទាំងនេះផងដែរឲ្យជម្រកជ្រកកោនដល់អ្នកមេដឹកនាំដែលប្រឆាំង

ក្បត់ព្រះអង្គ (មានលោក សំសារី លាក់ខ្លួននៅប្រទេសយួន សឺងង៉ុកថាញ់ លាក់ខ្លួននៅសៀម ជាដើម ហើយអ្នកទាំង២នេះមានការគាំទ្រអំពី សហរដ្ឋអាមេរិក)។

នៅខែមេសាឆ្នាំ១៩៥៥មានការប្រជុំជាឯកជន១នៅ បាន់ឌុង ជាមួយប្រមុខរដ្ឋ ប្រទេសចិន ជូអេនឡាយ និង រដ្ឋមន្ត្រីក្រសួង ការបរទេសយួនខាងជើង ផាំវ៉ាន់ដុង អ្នកទាំង២បានធ្វើការសន្យាថា និងគោរពឯករាជ្យប្រទេសកម្ពុជា និងទឹកដីព្រំប្រទល់កម្ពុជា។ ការពិសោធន៏ របស់សម្តេចជាមួយបារាំង ដំបូងសុំឲ្យបារាំងជួយសុខចិត្តទៅនៅក្រោម អាណានិគម រួចហើយធ្វើ ជារាជាអ្នកស្នេហាជាតិទាមទារឯករាជ្យ ឲ្យប្រទេសជាតិដេញបារាំងអំពីឥណ្ឌូចិន ធ្វើឲ្យព្រះអង្គយល់ថា សហរដ្ឋអាមេរិកមិនខុសពីបារាំងមិនយូរមិនឆាប់និងដកថយដូចបារាំង។ រួចហើយអ្នកដែលមានឋាមពលខ្លាំងបន្តការឈ្លានពានមានយួន និងសៀមដដែល។ ការយកចិត្តយៀកណាមខាងជើង និងជិតដិតជាមួយ ប្រទេសចិន និងនាំឲ្យប្រទេសខ្មែរបានសុខ ទប់ទល់និងការឡើងឋាមពល សៀម និង យួនខាងត្បូង។

ការទាក់ទងរវាងប្រទេសខ្មែរនិងចិនគឺជាការដែលមានប្រយោជន៏ ទាំងសងខាង។ ប្រទេសខ្មែរទាក់ទងចិនគឺចង់បានការការពារអំពី សៀមនិងយួន។ ឯប្រទេសចិនវិញគឺយកកម្ពុជាជាមិត្តកុំឲ្យប្រទេសកម្ពុជា ធ្លាក់ទៅដៃសហរដ្ឋអាមេរិកនាំឲ្យមានសត្រូវច្រើននៅជុំវិញប្រទេសខ្លួន។ ពេលដែលប្រមុខរដ្ឋប្រទេសចិន ជូអេនឡាយ ធ្វើទស្សនៈកិច្ចប្រទេស កម្ពុជា ឆ្នាំ១៩៥៦ លោកបានធ្វើសេចក្តីអំពាវនាដល់ប្រជាជនចិនភាគតិច រស់នៅកម្ពុជា ប្រហែល ៣០០,០០០ នាក់ឲ្យជាសវាងធ្វើនយោបាយ ឲ្យចូលខ្លួនជាអ្នកធ្វើការឲ្យប្រទេសខ្មែរជឿនលឿន ហើយឲ្យសុំចូលជាតិ ជាជាតិខ្មែរ។ កាយវិការនេះបានជួយបន្ធូរការដែលពិបាកដោះស្រាយ

មួយដែលមានទាក់ទងនិងការស្មោះចំពោះប្រជាជនជាតិចិននិង ប្រទេសខ្មែរ រវាងរដ្ឋាភិបាលប៉េកាំង និង ភ្នំពេញ។ នៅឆ្នាំ១៩៦០ ប្រទេសទាំង២ស៊ីញ៉េសន្ធិសញ្ញាមិត្តភាពនិងមិនឈ្លានពានទៅវិញទៅមក។ ក្រោយពីការទាក់ទងសហភាពសូវៀតនិងចិនមិនស្របគ្នា ការទាក់ទងជាមួយសូវៀត-ខ្មែរក៏ត្រជាក់ទៅដែរ។

ប្រទេសចិនមិនមែនតែប្រទេសមហាអំណាចដែលសម្តេចសីហនុរុករកជាប្រទេសឧបត្ថម្ភទេ។ ថ្ងៃក្រោយមកព្រះអង្គបែរទៅរកសហរដ្ឋអាមេរិក នៅឆ្នាំ១៩៥៥ សុំជំនួយកងទ័ព សម្ភារៈអាវុធដល់រាជកងទ័ព **Forces Armées Royales Khmères—FARK**។ សហរដ្ឋអាមេរិក បង្កើតក្រុមមើលបញ្ហាការកងទ័ពជំនួយ **A United States Military Assistance Advisory Group (MAAG)** នៅរាជធានីភ្នំពេញ ទទួលនិងចែកចាយជំនួយមកពីសហរដ្ឋ។ មកដល់ដើមឆ្នាំ១៩៦០ជំនួយមកពី វ៉ាស៊ីងតុន រាប់មាន ៣០% នៃថវិកាសំរាប់កងទ័ពកម្ពុជាទាំងមូល ហើយរាប់ជា ១៤% នៃថវិកាចូលរបស់ប្រទេស។

ចំណងមេត្រីរវាងសហរដ្ឋអាមេរិក-ខ្មែរមិនបាននឹងនរសោះ។ អ្នកផ្លូវការសហរដ្ឋនៅភ្នំពេញ និង វ៉ាស៊ីងតុន មិនទុកចិត្តសម្តេចស៊ីហនុសោះ គេយល់ថាព្រះអង្គមិនយល់ទម្ងន់នៃការរាតត្បាតរបស់កុម្មុយនីស្តនៅប្រទេសអាស៊ី។ ចំពោះសម្តេចវិញព្រះអង្គមិនទុកចិត្តសហរដ្ឋទាល់តែសោះ ហើយមានការមន្ទិលសង្ស័យជានិច្ចចំពោះស្ថានការណ៍ជុំវិញដែលសហរដ្ឋធ្វើនៅក្នុងប្រទេសខ្មែរ។

មានស្ថានការណ៍មួយគឺការដើរជឿនលឿននៃឥទ្ធិពលសហរដ្ឋអាមេរិក ជាមួយមេបញ្ជាការកងទ័ព។ ក្នុងដំណើរចែកចាយកងទ័ព យោធាសម្ភារៈ ការបង្ហាត់បង្រៀនកងទ័ពខ្មែរ

បានធ្វើឲ្យកងទ័ពទាំង២ប្រទេសមានការ ជិតដិតនិងគ្នា ទុកចិត្តគ្នា។ មេបញ្ជាការកងទ័ពទាំង២ប្រទេស យល់ដូចគ្នាអំពីគ្រោះថ្នាក់ដែលប្រទេសកុម្មុយនីស្តកំពង់រាតត្បាត ប្រទេសអាស៊ីអាគ្នេយ៍។ សម្តេចនរោត្តមសីហនុរាប់ទុក រាជកងទ័ព FARK ជាបេក្ខជនដែល វ៉ាស៊្មីងតុន នឹងជ្រើសរើសប្រឆាំងនិងព្រះអង្គ មានឧត្តមសេនីយលន់ណុល ចាប់ផ្តើមមានអំណាចខ្លាំងឡើងៗដោយ មកពីធ្វើការជាមួយនាយទាហានសហរដ្ឋអាមេរិកដែលចាប់មានឥទ្ធិពល ជីកបុសជ្រៅជាលំដាប់ ទៅលើប្រទេសខ្មែរ។

មានស្ថានការណ៏មួយប្រការទៀត គឺការរំលោភលើទឹកដីអាកាសអំពីកងទ័ពអាកាសរបស់សហរដ្ឋទម្លាក់គ្រាប់បែកលើទឹកដីខ្មែរលើជំរុំវៀតកុង ហើយមានកងទ័ពយួនខាងត្បូងដេញតាមវៀតកុងដែលរត់ចូលមកពួននៅលើទឹកដីខ្មែរ ជាការរំលោភទឹកដីខ្មែរផងដែរ។ ដោយហេតុការណ៏ទាំងនេះកើតឡើងជារាងរាល់ថ្ងៃ នៅដើមឆ្នាំ១៩៦០ឡើង ការមិនយល់ស្របគ្នាកាន់តែមានខ្លាំងរវាងសម្តេចនិងសហរដ្ឋអាមេរិក បណ្តាលឲ្យការទាក់ទងរវាងភ្នំពេញនិងវ៉ាស៊្មីងតុនរឹតតែចុះដាបទៅមុខ។

មានស្ថានការណ៏ទី៣ដែលកើតឡើង សម្តេចជឿច្បាស់ក្នុងព្រះចិន្តារបស់ព្រះអង្គជានិច្ចថាក្រសួងស៊ើបការសម្ងាត់របស់សហរដ្ឋរុករកនិងរំលំព្រះអង្គ ដាក់ ជំនួសជាមួយនរណាម្នាក់ដែលជាអ្នកខាងស្តាំ។ ភ័ស្តុតាងកើតឡើងនៅឆ្នាំ១៩៥៩ រាជដ្ឋាភិបាល រកឃើញការចូលដៃជាសម្ងាត់បដិវត្តន៏ទម្លាក់ព្រះអង្គ ហៅថា "ផែនការសម្ងាត់បាំងកក " ដែលមានអ្នកដឹកនាំខ្មែរមានពំនឹងអំពីសហរដ្ឋអាមេរិក ដូចជា សំសារី អ្នកដឹកនាំខ្មែរសេរីនៅប្រទេសយួនខាងត្បូង លោក សឹងង៉ុកថាញ់ អ្នកខាងស្តាំត្រូវនិរទេសនៅប្រទេសថៃ និង លោក ដាបឈួន មេកងទ័ព និងចៅហ្វាយខែត្រៗសៀមរាប។ មានការចោទប្រកាន់១ទៀតដែរ

ថាជាបឈ្មួនបំរុងនិងបំបែកប្រទេសខ្មែរជាពីរ យកខែត្រសៀមរាប និងកំពង់ធំ ចូលជាមួយ ព្រះអង្គម្ចាស់ ប៊ុនអុំ អ្នកនយោបាយខាងស្តាំ មកពីប្រទេសលាវ យកទឹកដីលាវខាងត្បូង ចូលគ្នាបង្កើតជាប្រទេសថ្មី១ (ជាបឈ្មួនត្រូវរាជកងទ័ព FARK សម្លាប់ ឪពុកនៅក្មេងៗកាលនោះ ធ្លាប់ឃើញ រូបថត ដែលរាជដ្ឋាភិបាល បោះពុម្ពផ្សាយ មានខ្សែច្រវាក់ចងក អូសខ្មោចពីក្រោយឡានឃ្វីប ពុកចាំឥតភ្លេចជាក្មេងតូចឃើញខ្មោចងាប់ យ៉ាងតែហោងដូច្នេះ -រីឯសំសារីនិងសឺងង៉ុកថាញ់ និរទេសទៅ យួននិង សៀមដឹកនាំ កងទ័ពខ្មែរសេរី (ខ្មែរស្តាំ) ប៉ុន្តែបានចូលមកប្រទេសខ្មែរ វិញជំនាន់សាធារណ: ១៩៧០-១៩៧៥ ក្រោយពីសម្តេចសីហនុត្រូវ រំលំដោយ លន់ណុល)។

ស្ថានការណ៏ដែលកើតឡើងទាំងនេះត្រូវពង្រីកនិងបំផ្លើសដោយ សម្តេចនរោត្តមសីហនុ ដេរភ្ជាប់និងការសង្ស័យរបស់ព្រះអង្គដែល មានជានិច្ចបន្ថយការទាក់ទងជាមួយសហរដ្ឋអាមេរិកតទៅទៀត។ នៅ ខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្តេចចោទ សហរដ្ឋអាមេរិកថា នៅតែទាក់ទងគាំទ្រ កងទ័ពខ្មែរសេរីនៅប្រទេសយួននិងប្រទេសថៃ ប្រកាសឲ្យផ្តាច់ជំនួយ យោធាអំពីសហរដ្ឋអាមេរិក។ ការរំលោភលើទឹកដីអាកាសអំពី កងទ័ព អាកាសរបស់សហរដ្ឋទម្លាក់គ្រាប់បែកលើទឹកដីខ្មែរលើជំរុំវៀតកុងនិង កងទ័ពយួនខាងត្បូងប្រដេញតាមវៀតកុងដែលរត់ចូលមកពួននៅលើ ទឹកដីខ្មែរដែលជាការរំលោភទឹកដីខ្មែរ ត្រូវព្រះអង្គរំលឹកថែម។ ចុងបញ្ចប់នៅ ខែឧសភាឆ្នាំ១៩៦៥ ប្រទេសកម្ពុជាផ្តាច់ចំណងទូតជាមួយ សហរដ្ឋអាមេរិក។

ស្របជាមួយគ្នានេះដែរ សម្តេចលេងល្បិចនយោបាយទៅតាមការ វិវត្តន៏នៃនយោបាយភូមិភាគអាស៊ីអាគ្នេយ៏ដែលកើតឡើងក្នុងពេលនោះ

ទាញប្រទេសកុំឲ្យធ្លាក់ចូលទៅក្នុងសង្គ្រាមយួនទាំង២។ ពីដើមឆ្នាំ១៩៦០ ឡើង សម្ដេចផ្អៀងខ្លួនទៅយួនខាងជើង ហាណូយ ពីព្រោះយួនខាងត្បូង បំរុងនិងក្រឡាប់កំពង់មានការបដិវត្តន៍ប្ដូររបប ពី ង៉ោឌិញដៀម (១៩៥៥-១៩៦៣) ទៅរបបកងទ័ព។ តាមអ្នកសង្កេតការណ៍ ប្រទេសខ្មែរប្រើនយោបាយស្នៀតថ្មីនឹកថាយួនខាងជើងនិងឈ្នះ ក្នុងឆ្នាំ១៩៦៣ខែសីហា ប្រទេសខ្មែរចងទូតជាមួយរបបថ្មីយួនខាងត្បូងសិន រួចហើយខែមិនា ឆ្នាំ១៩៦៤ ចងមេត្រីភាពជាមួយយួន ខាងជើង។ បន្ទាប់មកសម្ដេចចាប់ចរចារព្រំប្រទល់ដែនជាមួយយួនខាងជើង។ មិនបានសំរេចដូចព្រះអង្គបានគិតទុក យួនខាងជើងប្រាប់ព្រះអង្គថា ព្រំប្រទល់ទឹកដីជាមួយយួនខាងត្បូង ព្រះអង្គត្រូវចរចារជាមួយយួនខាងត្បូង។ ពាក់កណ្ដាលឆ្នាំ១៩៦៦ សម្ដេចចាប់ចរចារព្រំប្រទល់ជាមួយយួនខាងត្បូង។ មួយឆ្នាំក្រោយមក ឆ្នាំ១៩៦៧ យួនខាងត្បូងទទួលស្គាល់ព្រំប្រទល់ និង មិនធ្វើការរំលោភទៀតទេ។ បន្តិចក្រោយមកប្រទេសវៀតណាមខាងជើងក៏ទទួលស្គាល់ព្រំប្រទល់ប្រទេសខ្មែរដែរ។ ប្រទេសខ្មែរជាប្រទេសទី១ក្នុងលោកទទួលស្គាល់រដ្ឋាភិបាលយួនខាងត្បូងដែលចាប់កើតឡើងខែមិថុនាឆ្នាំ១៩៦៩។ បីខែក្រោយមក ហូជីមិញ ស្លាប់ សម្ដេចស៊ីហានុ ជាមេដឹកអ្នកនាំប្រទេសក្រៅនៅបរទេសតែម្នាក់គត់ដែលទៅចូលកាន់បុណ្យសពនេះ។

នៅឆ្នាំ១៩៦៥ សម្ដេចស៊ីហានុ ពិភាក្សាកិច្ចព្រមព្រៀងមួយជាមួយប្រទេសចិន និង វៀតណាមខាងជើង អនុញ្ញាតិឲ្យកងទ័ពយួនខាងជើង និង វៀតកុងមានមូលដ្ឋានកងទ័ពនៅលើទឹកដីខ្មែរជាអចិន្ត្រៃយ៏។ ប្រទេសខ្មែរបើក ផែសមុទ្រ ឲ្យប្រទេសចិន និង សហភាពសូវៀត ដឹកជញ្ជូនយោធាសម្ភារៈ ឲ្យយួនតាមផ្លូវសមុទ្រទៅដំបន់ខាងកើតក្នុងទឹកដីខ្មែរ។ ជាសំណង សងវិញដែរ មានចំនួនប្រាក់ជាច្រើនឥតឧបមា ប្រគល់ដល់ដៃអ្នកដឹកនាំ ប្រទេសខ្មែរពេលនោះ។

ជាពិសេសទៅទៀតក្នុងការសំណាងនេះដែរ មានការព្រមព្រាងរបស់ប្រទេសចិនសុខចិត្តទិញអង្ករខ្មែរដោយឲ្យតម្លៃ ហួសក៏រីតដល់រដ្ឋាភិបាលខ្មែរ។ ពេលដែលសម្តេចស៊ីហានុមាន ព្រះរាជស័ព្ទជាសាធារណៈថាព្រះអង្គកាន់ អាជ្ញាកណ្តាល ព្រះអង្គដឹក នាំប្រទេសចូលត្រង់ៗទៅក្នុងសង្គ្រាមវៀតណាម។

ក្រោយពីធ្វើមិត្តភក្តិជាមួយយួនខាងជើងនិងប្រទេសចិន សម្តេចស៊ីហានុ ចាប់បើកបន្ទូដៃឲ្យពួកខាងស្តាំធ្វើចលនា ហើយធ្វើការសង្កត់តឹងទៅពួកខាងឆ្វេងទូរទៅពេញទាំងប្រទេស។ ការសង្កត់នេះធ្វើឲ្យអ្នកដឹកនាំខាងឆ្វេងរត់ចូលពួនក្រោមដី។

នៅខាងចុងឆ្នាំ ១៩៦០ឡើង ពេលដែលសម្តេចរក្សាមិត្តភាពជាមួយចិន-យួន ព្រះអង្គរេរកធ្វើមិត្តនិងប្រទេសខាងលិចដើម្បីទប់លំនឹង។ ការនេះកើតឡើងម្យ៉ាងដែរដោយ ប្រទេសចិនកំពង់មានបដិវត្តន៏វប្បធម៏ផ្ទៃក្នុង ប្រទេសខ្មែរពេលនោះមិនអាចយកចិនជាបង្អែកបាន។ ក្នុងពេលជាមួយគ្នានេះ ទ័ពយួនខាងជើងស្ថិតនៅក្នុងដីខ្មែរផ្នែកខាងកើតមានច្រើនមហិមាដែលធ្វើឲ្យនយោបាយ និង សេដ្ឋកិច្ចប្រទេសខ្មែរលែងនឹងនរ។ យួនខាងជើងនិងវៀតកុងប្រើមូលដ្ឋានជំរកនៅប្រទេសខ្មែរកាន់តែច្រើនៗឡើង ប្រទេសខ្មែរក្លាយទៅជាមន្ទីរចុងខាងត្បូងនៃផ្លូវរត់ជំនួយហូជីមិញដែលពីដើមមានកំណើតនៅយួនខាងជើង ឥឡូវនេះចេញពីកំពង់ផែប្រទេសខ្មែរតែម្តង។ ប្រទេសខ្មែរមិនប្រកាន់ នយោបាយអព្យាកណ្តាលទៀតឡើយ ហើយប្រទេសចិនរវល់និងបដិវត្តន៏ផ្ទៃក្នុង បណ្តោយឲ្យយួនខាងជើងធ្វើតាមចិត្ត។ ទៅខាងកើតព្រំប្រទល់ប្រទេសខ្មែរ យួនខាងត្បូងជាការភ្ញាក់ផ្អើលមួយដែលប្រទេសនេះមិនទាន់ធ្លាក់ សូម្បីការលួចវាយឆ្មក់ប្រហារឆ្នាំ១៩៦៨ របស់យួនខាងជើងនិងវៀតកុងនៅ ពេលបុណ្យចូលឆ្នាំថ្មី

យប់សំពះលោកខែ (**Tet Offensive**) ក៏ដោយ។ ការវាយឆ្មក់នេះមានឈ្មោះដូចនេះដោយសារ មុនពេលបុណ្យចូល ឆ្នាំថ្មី១៩៦៨ ទាំងសងខាងប្រកាសការឈប់បាញ់គ្នា២ថ្ងៃក្នុងពេលបុណ្យ។ ផ្ទុយទៅវិញយួនខាងជើងនិងវៀតកុងវាយឆ្មក់គ្រប់ទិសក្នុងប្រទេស ចាប់ពីម៉ោងព្រលឹមយប់ខែមករាថ្ងៃទី៣០ជាថ្ងៃទី១សំពះព្រះខែ។ ពេលនោះប្រធានាធិបតីង្វៀងវ៉ាន់ធីវ និងកងទ័ពរដ្ឋាភិបាលព្រមទាំងសហរដ្ឋអាមេរិកអាចទប់យួនខាងជើងនិងយៀកកុងបាន។

ក្នុងឱកាសនេះដែររាជដ្ឋាភិបាលភ្នំពេញចាំមិនភ្លេចការបាត់បង់ជំនួយអំពីសហរដ្ឋអាមេរិក ដែលមានចំនួន ៤០០លានដុល្លា ពីឆ្នាំ១៩៥៥ ដល់១៩៦៣។ រាជដ្ឋាភិបាលមានការនឹកជាថ្មីចង់បានជំនួយនេះមកវិញ។ ក្រោយពីផ្តាច់ជំនួយសហរដ្ឋអាមេរិក យោធាសម្ភារៈ និង គ្រឿងបន្លាស់ក្នុងកងទ័ពត្រូវធ្លាក់ទៅក្នុងភាពដុនដាបជាទីបំផុត ការប្តូរជំនួសគ្រឿងសម្ភារៈមកពីប្រទេសចិន និង សូវៀត និងសែសសល់ពីបារាំងមានគុណភាពធុនអន់ និងចំនួនតិចពេកប្រើសឹងមិនកើត។

នៅចុងឆ្នាំ១៩៦៧ និង ដើមឆ្នាំ១៩៦៨ សម្តេចបើកអនុញ្ញាតិឲ្យកងទ័ពយួនខាងត្បូងនិងកងទ័ពសហរដ្ឋអាមេរិក ដេញតាមកងទ័ពយួនខាងជើងនិងវៀតកុងក្នុងទឹកដីខ្មែរ។ នៅឯសហរដ្ឋធានីវ៉ាស៊ីងតុនវិញត្រូវបានមេបញ្ជាការកងទ័ពជំនួយសហរដ្ឋអាមេរិកប្រចាំយួនខាងត្បូង **the United States <u>Military Assistance Command--Vietnam</u> (MACV)**ស្នើឲ្យ សហរដ្ឋចាប់ផ្តើមទម្លាក់គ្រាប់បែកក្នុងដីប្ររទេសខ្មែរទៅលើជំរុំយួនខាងជើងនិងយៀកកុងនៅខែមិនា១៩៦៩។ មានការទិទៀនមួយអំពីអ្នកសាពត៌មានប្រទេសអង់គ្លេស លោកវីលីយ៉ាំស្វាក្រស្ស ថាតើការចាប់ផ្តើមទំលាក់គ្រាប់បែកនេះជាការសំរេច

របស់ប្រធានាធិបតី និចសុន ឬ ក៏ជាការបើកដៃអំពីសម្តេចនរោត្តមស៊ីហនុ។ ប៉ុន្តែតាមការពិចារណាក្រឡេកមើលក្រោយវិញគឺសម្តេចបានបើកដៃឲ្យ មានការទម្លាក់គ្រាប់បែក ស្របតាមនយោបាយគោលដៅព្រះអង្គ ទប់លំនឹងជំហរអំពីការសម្រេចចិត្តពីមុនដែលអនុញ្ញាតិឲ្យយួនតាំងមូលដ្ឋាន រួចហើយវាយទប់កុំឲ្យវារីក។ ហេតុផលនេះបង្ហាញជាក់ស្តែង នៅផ្លូវទំនាក់ទំនងការទូត គឺគ្មានប្រេះឆា ដើរទៅមុខជាធម្មតា។ មួយខែក្រោយមក ខែមេសាឆ្នាំ១៩៦៩ ប្រធានាធិបតី និចសុន ផ្ញើរសារថ្វាយសម្តេចថា ប្រទេសសហរដ្ឋ ទទួលស្គាល់ព្រំប្រទល់អធិបតេយ្យភាព ឯករាជ្យ នៃប្រទេសខ្មែរ។ បន្តិចក្រោយមកនៅខែ មិថុនាឆ្នាំ១៩៦៩ ការដាក់ទូតជាពេញផ្លូវការរវាងភ្នំពេញនិងវ៉ាស៊្នឹងតុនមានកើតឡើងវិញ។

## ***កំណើតជាជំហ៊ានរបស់ខ្មែរខាងឆ្វេង(កុម្មុយនិស្ត)***

---

ប្រវត្តិសាស្រ្តអំពីចលនាកុម្មុយនីស្តនៅប្រទេសកម្ពុជាមានចែកជា៦ជំហ៊ានៈ
១- ការផុសចេញកើតគណៈបក្សកុម្មុយនីស្តឥណ្ឌូចិន **the Indochinese Communist Party (ICP)** ដោយលោក ហូជីមិញ ដែលមានសមាជិក សុទ្ធតែយួនមុនពេលសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥)។

២- ក្រោមការតស៊ូប្រយុទ្ធ១០ឆ្នាំដើម្បីបានឯករាជ្យពីបារាំង ហូជីមិញ ជួយឧបត្ថម្ភអ្នកដឹកនាំកុម្មុនីស្តខ្មែរបង្កើតគណៈបក្ស ប្រជាជនបដិវត្តន៏ខ្មែរ **the Kampuchean (or Khmer) People's Revolutionary Party (KPRP)**។

៣- រយៈពេលបន្តរបស់ គណៈបក្ស ប្រជាជនបដិវត្តន៏ខ្មែរ **the KPRP** មកឆ្នាំ១៩៦០ ដែលមានសមាជិកសភាជំនាន់ទី២ ដូចជា សាឡុតស

(ដូរឈ្មោះទៅ ប៉ុលពត ឆ្នាំ១៩៧៦) ហ៊ូនឹម ហ៊ូយន់ អៀងសារី និង ខៀវសំផន ថ្ងៃក្រោយមកជាមេដឹកនាំខ្មែរក្រហមនៅថ្ងៃក្រោយ ឡើងកាន់កាប់គណៈបក្ស។

៤- ការបដិវត្តន៏តស៊ូ កំណើតការបះបោរខ្មែរក្រហម ១៩៦៧-៦៨ រហូតដល់រលំនៃរបប លន់ណុល ខែមេសា ឆ្នាំ១៩៧៥។

៥- របបខ្មែរក្រហម ប្រជាធិបតេយ្យកម្ពុជា the **Democratic Kampuchea** ពីខែមេសាឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

៦- រយៈពេលបន្តរបស់ គណៈបក្ស ប្រជាជនបដិវត្តន៏ខ្មែរ the KPRP មកដល់ខែមករាឆ្នាំ១៩៧៩ ដែលមានសមាជិកសភាជំនាន់ទី៣ដូចជា ជាស៊ីម ហេងសំរិន ហ៊ុនសែន និង ហ៊ររណាំហុង ហើយពេលនេះហាណូយ ជាទីបញ្ជប់បានក្តាប់ជាប់ទឹកដីប្រទេសខ្មែរ និង ត្រួតត្រាគណៈបក្ស កុម្មុយនីស្តខ្មែរ ទាំងមូល។

ភាគច្រើននៃចលនាប្រវត្តិសាស្ត្រប្រទេសខ្មែរត្រូវបានគ្របបិទចោល ដោយអាថ៌កំបាំង មិនអាចរកឃើញមកវិញដោយការចម្រាញ់សម្លាប់ចោល មិនឈប់ឈររបស់របបខ្មែរក្រហម ដល់អ្នកចេះដឹងដែលសព្វថ្ងៃ នៅ សល់យ៉ាងតិចបំផុតនៅចាំរឿងដើម។ ទោះជាយ៉ាងនេះក៏ដោយ រឿងមួយ ដែលជាធំ គឺ ការប្រឆាំងរវាងយួននិងខ្មែរ ជាប្រធាន ដែលបណ្តាល ឲ្យមានហេតុការណ៏ទាំងនេះកើតឡើង។ នៅក្នុងរវាង ៣០ឆ្នាំ ចន្លោះក្រោយសង្គ្រាមលោកលើកទី២ និងការជោគជ័យរបស់របប ខ្មែរក្រហម អ្នកបញ្ញវន្តខ្មែររៀននៅបស្ចិមប្រទេសចាប់ប្រកាន់យក ទ្រឹស្តីកុម្មុយនីស្ត (ដែលមាន១ភាគគឺចង់ដោះស្រាយការក្រីក្រលំបាករបស់ ប្រជាជនខ្មែរភាគច្រើន) ស្របនិងគ្នានេះដែរមានចលនាយួនកុម្មុយនីស្ត ប្រឆាំងនិងរាជាធិរាជ ង្វៀង ដែលប្រើលទ្ធិនិយមសាសនាខុងជឺ

កើតឡើងនៅប្រទេសវៀតណាម ហើយជាមួយនេះដែរយួនចង់ប្រើនយោបាយនិយមកុម្មុយនីស្តយកទឹកដីខ្មែរ។ ដោយដឹងហេតុដូច្នេះហើយបានជាកុម្មុនីស្តខ្មែរក្រហមក្រោយឆ្នាំ១៩៦០ រាប់បញ្ចូលសេចក្តីស្នេហាជាតិនិងគំនិតបដិវត្តន៍ ពេលខ្លះហ៊ានបរិយាយអំពីគំនិតឈ្លានពានរបស់យួនទៅលើខ្មែរ។ ការបោះផ្សាយជាអក្សរសាស្រ្តនៅឆ្នាំ១៩៧០ឡើងរបបខ្មែរក្រហម ហៅជនជាតិវៀតណាម ជា "យួន" (អ្នកព្រៃផ្សៃ) គឺជាពាក្យដែលមានកើតឡើងតាំងអំពីជំនាន់អង្គរ។

នៅឆ្នាំ១៩៣០ ហូជីមិញ បង្កើត គណៈបក្សយួនកុម្មុយនីស្ត ដោយបង្រួបបង្រួមចលនាកុម្មុយនីស្ត៣ នៅតុងកឹង នៅអាណាម និងកូសាំងស៊ីន ដែលកើតក្រោយពីឆ្នាំ១៩២០ឡើង។ ហូជីមិញ ដូរឈ្មោះភ្លាមៗ ហៅថា គណៈបក្សឥណ្ឌូចិន the **Indochina Communist Party ICP** រាប់បញ្ចូល ចលនាបដិវត្តន៏គណៈបក្សប្រជាជននៅប្រទេសខ្មែរ the **KPRP** និង ប្រទេសលាវ ចលនា អ៊ីតសាលា **Lao Itsala**។ សមាជិកដំបូងរបស់ចលនាមានសុទ្ធតែជនជាតិយួន។ ក្រោយពីសង្គ្រាមលោកលើកទី២ មានជនជាតិខ្មែរ២-៣នាក់ចាប់ចូលជាសមាជិក ប៉ុន្តែគ្មានសកម្មភាពនយោបាយគួរឲ្យកត់សំគាល់នៅឯប្រទេសខ្មែរនៅឡើយ។ កងទ័ពយៀកមិញមានពេលខ្លះចូលប្លន់មូលដ្ឋានទ័ពបារាំងនៅប្រទេសខ្មែរដែលពេលនោះយួនចូលដៃជាមួយទ័ពសៀមដែលមានអ្នកកាន់អំណាចរដ្ឋាភិបាលជាអ្នកខាងឆ្វេងរហូតដល់ឆ្នាំ១៩៤៧។ កងទ័ពយៀកមិញបង្ខំឲ្យមានចលនាកាន់អាវុធជាក្រុមហៅ ខ្មែរអ៊ីសារ៉ាក់ នៅប្រទេសខ្មែរ។ នៅថ្ងៃទី១៧ខែមេសាឆ្នាំ១៩៥០ (២៥ឆ្នាំក្រោយថ្ងៃខែជាមួយដែរកងទ័ពខ្មែរក្រហមបានជោគជ័យកាន់កាប់ភ្នំពេញ) ការបង្កើតជាដំបូងសមាជិកសភាជំនាន់ទី១នៃរបបកុម្មុយនីស្តនៅប្រទេសខ្មែរ ចលនា

ខ្មែរអ៊ីសារ៉ាក់ ដែលមានអ្នកដឹកនាំឈ្មោះ សឺងង៉ុកមិញ (មិនប្រាកដជាបង បង្កើតរបស់ សឺងង៉ុកថាញ់ មេដឹកនាំខ្មែរសេរី -ខ្មែរខាងស្តាំ-ថ្ងៃក្រោយ) រាប់បញ្ចូល១ភាគ៣សមាជិកមកអំពី គណៈបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់ ហូជីមិញ។ តាមការសរសេររបស់អ្នកប្រវត្តិសាស្ត្រ ដេវីដ ព. ឆែនលើរ ចលនាកុម្មុយនីស្តខ្មែរអ៊ីសារ៉ាក់ ដោយមានការគាំទ្រពីកងទ័ពយៀកមិញ កាន់កាប់១ភាគ៦នៃទឹកដីកម្ពុជានៅឆ្នាំ១៩៥២ រួចហើយនៅពេលយប់មុនថ្ងៃ ប្រជុំនៅក្រុងហ្សឺណែវ កាន់កាប់ពាក់កណ្តាលប្រទេសខ្មែរ។

បើតាមប្រវត្តិសាស្ត្រដែលសរសេរឡើងដោយរបបខ្មែរក្រហម គណៈបក្សប្រជាធិបតេយ្យកម្ពុជា **the Democratic Kampuchea** ថា វៀតមិញមានបរាជ័យមិនបានទាមទារទឹកដីកម្ពុជាឲ្យ **KPRP** នៅការជនុំសន្និសិទ្ធក្រុងហ្សឺណែវឆ្នាំ១៩៥៤ គឺជាការក្បត់១យ៉ាងធំ ដោយសារពេលនោះមានកងទ័ពខ្មែរយៀកមិញដែលកាន់អាវុធនៅព្រៃ ៥000នាក់ទៅហើយ។ ក្រោយពីការជំនុំហ្សឺណែវ មានសមាជិក **KPRP** ១000នាក់ដែលក្នុងនោះមាន សឺងង៉ុកមិញផង ធ្វើដំណើរ "ផ្លូវវែង" ចូលនិទេសខ្លួននៅប្រទេសវៀតណាមខាងជើង។ ក្រោយពីឆ្នាំ១៩៥៤ សមាជិកណាដែលនៅសល់មិនទៅវៀតណាមខាងជើង បង្កើតគណៈបក្ស ប្រជាជន ចូលបោះឆ្នោតដំណាងរដ្ឋសភាប្រជែងជាមួយគណៈបក្ស សង្គមរាស្ត្រនិយមរបស់សម្តេច នរោត្តមស៊ីហនុ ឆ្នាំ១៩៥៥ និង ឆ្នាំ១៩៥៨។ លទ្ធផលបោះឆ្នោតខែកញ្ញាឆ្នាំ១៩៥៥ មាន ៤% ឈ្នះឆ្នោត ប៉ុន្តែមិនអាចឈ្នះកៅអីនៅរដ្ឋសភាបាន។ សមាជិករបស់គណៈបក្ស ប្រជាជន ត្រូវមានការរុគគួនជានិច្ចអំពីអាជ្ញាធម៏របស់សម្តេច។ ការរុគគួន របស់រាជដ្ឋាភិបាល ធ្វើឲ្យគណៈបក្សប្រជាជនមិនហ៊ានឈរឈ្មោះនៅ ការបោះឆ្នោតឆ្នាំ១៩៦២ ហើយសមាជិកនាំគ្នារត់ចូលក្រោមដី។ សម្តេច នរោត្តមស៊ីហនុ មានការទម្លាប់ព្រះបន្ទូលហៅឲ្យឈ្មោះអ្នកដឹកនាំខាងឆ្វេង

ថា ខ្មែរក្រហម គឺជាឈ្មោះក្លាយទៅជាឈ្មោះហៅជាសកលដែលថ្ងៃក្រោយមក មានឈ្មោះរដ្ឋាភិបាលខ្មែរក្រហមជាដើមដែលមាន ប៉ុលពត អៀងសារី ខៀវសំផន និងអ្នកដឹកនាំចូលដៃឯទៀត។

នៅពាក់កណ្តាលឆ្នាំ១៩៥០ឡើង គណៈបក្ស ប្រជាជន KPRP មានចែកជា២ "គណៈកម្មការទីក្រុង" ដែលដឹកនាំដោយ ទូសាមុត និង "គណៈកម្មការជនបទ" ដឹកនាំដោយ ស៊ីវហេង។ ក្នុងន័យទូរទៅនេះជាការបែកគ្នារបស់ចលនាកុម្មុយនីស្តប្រទេសខ្មែរ។ យួនខាងជើងកាន់ជើង គណៈកម្មការទីក្រុង ទូសាមុត ទទួលស្គាល់ថាសម្តេចស៊ីហនុជាមេដឹកនាំប្រទេសខ្មែរពិតប្រាកដទើបនិងទាមទារបានឯករាជ្យពីបារាំង ហើយដោយសារម្យ៉ាងទៀតដែរ ព្រះអង្គមិនទុកចិត្តសហរដ្ឋអាមេរិកជាសត្រូវរបស់យួនខាងជើង អាចនិងបញ្ចុះបញ្ចូលឲ្យប្រកាន់នយោបាយចូលខាងឆ្វេងបានទៅថ្ងៃក្រោយ។ រីឯគណៈកម្មការជនបទ ភាគច្រើនជាមេដឹកនាំចុងកាត់មាត់ញក ដែលស្គាល់ភាពលំបាកតោកយ៉ាកពិតៗរបស់ប្រជារាស្ត្រចង់រំលំរបបសក្តិភូមិរបស់សម្តេចស៊ីហនុ។ នៅឆ្នាំ១៩៥៩ ស៊ីវហេង ក្បត់រត់ចូល រាជាដ្ឋាភិបាល បង្ហាញឈ្មោះបក្សពួកដល់អាជ្ញាធម៌ក្រសួងសន្តិសុខ ដែលត្រូវសម្លាប់បំផ្លាញ ៩០% ដល់សមាជិកម៉ាស៊ីនរបស់គណៈបក្សជនបទ។ ថ្វីបើ គណៈបក្ស ទូសាមុត មានសមាជិកកុម្មុយនីស្តច្រើន ហើយខ្លាំងជាង មកដល់ឆ្នាំ១៩៦០ មានតែប្រហែល រាប់រយនាក់ដែលនៅសេសសល់មានសកម្មភាព។

## *ពួកក្រុមនិស្សិតនៅប៉ារីស*

នៅឆ្នាំ១៩៥០ឡើង និស្សិតខ្មែរនៅប៉ារីសបង្កើតចលនាកុម្មុយនីស្តដោយផ្ទាល់ ហើយដែលសឹងតែគ្មានទាក់ទងសោះនិងចលនាកុម្មុយនីស្តនៅឯស្រុក។ ដោយមានឋានន្តរស័ក្តិចែកចាយរួចរាល់ មកដល់ប្រទេសវិញមនុស្សទាំងប្រុសស្រី ចាប់កាន់មុខដំណែងជាម៉ាស៊ីនបដិវត្តន៏នៅឆ្នាំ១៩៦០ឡើង ដឹកនាំការបះបោរដោយប្រសិទ្ធិភាពប្រឆាំងនិងសម្តេចនរោត្តមស៊ីហនុ និង លន់ណុល ពីឆ្នាំ១៩៦៨ រហូត ឆ្នាំ១៩៧៥ ដែលបានជ័យជំនះបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

<u>ប៉ុលពត **Pol Pot**</u> បានឡើងជាអ្នកដឹកនាំចលនាកុម្មុយនីស្តចាប់ពីឆ្នាំ១៩៦០ឡើង។ កើតនៅឆ្នាំ១៩២៨ (ប្រភពខ្លះថាឆ្នាំ១៩២៥) នៅខែត្រកំពង់ធំ ខាងជើងនៃរាជធានីភ្នំពេញ។ រៀននៅសាលាវិទ្យាល័យតិកនិកភ្នំពេញរួចហើយទៅបន្តវិជ្ជានៅទីក្រុងប៉ារីសឆ្នាំ១៩៤៩រៀនវិទ្យុអេឡិកត្រូនិក (ប្រភពផ្សេងទៀតថារៀនប្រដាប់វាយពុម្ពតួអក្សរនិងវិស្វករសំណង់)។ និយាយរៀបរាប់ដោយប្រភព១ថាប៉ុលពតជាមនុស្ស "ប្តេជ្ញាតឹងរឹង ប៉ុន្តែយឺតខាងការរៀបចំ "គាត់រៀនមិនបានសញ្ញាប័ត្រទេ។ បើតាមលោកអាចារ្យ សាសនា កាតូលិក ហ្វ្រង់ស្វា ប៉ុងស្សូដ ថា ប៉ុលពតចូលចិត្តជាខ្លាំងអានអក្សរសាស្ត្របារាំងដែលសរសេរអំពី អ្នកផ្តើមមេកុម្មុយនីស្តប្រទេសអាឡឺម៉ង់និងសូវៀត ម៉ាកស៊ីស្ត និង ស្តាលីនីស្ត។

សមាជិក១ទៀតក្នុងចំណោមក្រុមនិស្សិតនៅប៉ារីសមាន <u>អៀងសារី **Ieng Sary**</u> ។ គាត់ជាកូនកាត់ចិន-ខ្មែរ កើតនៅប្រទេសយួនខាងត្បូង។ គាត់រៀននៅ វិទ្យាល័យសម្រាំង ស៊ីសូវ័ត្ថ នៅភ្នំពេញ ក្រោយមកបន្តការសិក្សានៅប៉ារីស សាលាពាណិជ្ជកម្ម និង នយោបាយ នៅសាលាវិទ្យាស្ថានសិក្សានយោបាយប៉ារីស (ដែលមានឈ្មោះហៅជា ***Sciences Po***)។

ខៀវសំផន Khieu Samphan ចាត់ទុកជាអ្នក "វៃឆ្លាតចំណានជាងគេក្នុងចំណោមមិត្តភក្តិបញ្ញវន្តទាំងនេះ" កើតនៅឆ្នាំ១៩៣១ រៀនខាងសេដ្ឋកិច្ច និង នយោបាយនៅប៉ារីស។

អ្នកប្រណាំងនិងខៀវសំផន គឺ ហ៊ូយន់ Hou Yuon កើតនៅឆ្នាំ១៩៣០ រៀនសេដ្ឋកិច្ចនិងច្បាប់ ដែលមានការកោតអំពីមិត្តភក្តិជាអ្នកមាន "សមត្ថកិច្ចខ្លាំងខាងផ្លូវកាយនិងចិត្ត"។ សុនសែន Son Sen កើតនៅឆ្នាំ១៩៣០ រៀន កិច្ចការអប់រំ និង អក្សរសាស្ត្រ។ ហ៊ូនឹម Hu Nim កើតនៅឆ្នាំ១៩៣២ រៀន ច្បាប់។

មនុស្សទាំងនេះជាអ្នកដែលបានរៀនអប់រំជ្រៅជ្រះក្នុងប្រវត្តិសាស្ត្រនៃអ្នកដឹកនាំកុម្មុយនីស្តទាំងមូលនៅប្រទេសអាស៊ី។ ពីរនាក់ ខៀវសំផន និង ហ៊ូយន់ រៀនបានបណ្ឌិត អំពី មហាវិទ្យាល័យប៉ារីស។ ហ៊ូនឹម បានទទួលសញ្ញាប័ត្រអំពីមហាវិទ្យាល័យភ្នំពេញ ឆ្នាំ១៩៦៥។ បើពិចារណាត្រឡប់ក្រោយ គឺគ្មានអ្វីដែលអាចពន្យល់បានថាអ្នកមានចំណេះវិជ្ជាជ្រៅជ្រះទាំងនេះ ត្រូវបានបញ្ជូនទៅប្រទេសបារាំងដោយសារអាហារូបករណ៏រដ្ឋាភិបាល អាចធ្វើបដិវត្តន៏បង្ហូរឈាមក្នុងប្រវត្តិសាស្ត្រនៃប្រទេសអាស៊ី។ ភាគច្រើននៃអ្នកទាំងនេះកើតមកអំពីគ្រួសារអ្នកមានសម្បត្តិ ឬអ្នកធ្វើការរដ្ឋការ។ ប៉ុលពត និង ហ៊ូយន់ មានទាក់ទងនិងពូជស្តេច។ បងស្រីបង្កើតរបស់ប៉ុលពត ជាអ្នកម្នាងស្នំរបស់ព្រះរាជាមូនីវង់។ មានបីនាក់ក្នុងចំណោមនិស្សិតក្រុងប៉ារីស រស់នៅជិតដិតតស៊ូលំបាកធ្វើបដិវត្តន៏ជាមួយគ្នា គឺ ប៉ុលពត និង អៀងសារី រៀបការណ៏ជាមួយ ខៀវប៉ុណ្ណារី និង ខៀវធីរិទ្ធ (មានឈ្មោះជា អៀងធីរិទ្ធដែរ) ដែលជាបងប្អូនរបស់ ខៀវសំផន។ ស្ត្រីដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ទាំងពីរ ក៏មានមុខងារជាអ្នកចាត់ចែងក្នុងរបបខ្មែរក្រហម

ប្រជាធិបតេយ្យកម្ពុជាឆ្នាំ១៩៧៥ដែរ។ បើគិតស្មានឲ្យដល់ទៅ និយាយពីក្មេងៗជំនាន់នោះនៅភ្នំពេញឬទើបនិងមកពីខែត្រនានាធ្វើការជាមួយអ្នកបញ្ញាវន្តទាំងនេះ ធំក្លិនប្រាជ្ញាចេញថ្មីៗពីប៉ារីស និងធ្វើឲ្យវិលមុខ។ អ្នកខ្លះបូជាខ្លួនចូលជ្រកកោនក្នុងទ្រឹស្តី ម៉ាកស៊ីស្ត-លេនីននីស្តតាមគេ។ នៅចន្លោះឆ្នាំ១៩៤៩ និង ១៩៥១ ប៉ុលពត និង អៀងសារី ចូលខ្លួនជាមួយគណៈបក្សកុម្មុយនីស្តបារាំង the **French Communist Party** ដែលមានវិន័យតឹងរឹងបំផុត និង ចូលដៃជាមួយអ្នកគោរព ស្តាលីននីស្តកុម្មុយនីស្តអឺរុបផ្នែកខាងលិច។ នៅឆ្នាំ១៩៥១ អ្នកទាំង២ធ្វើដំណើរទៅក្រុងប៉ែរឡាំងខាងកើត ចូលរួមនិងពីធីបុណ្យយុវភាពកុម្មុយនីស្ត។ ការពិសេធន៏នេះគឺជាការដែលចាប់បដិសន្ធិក្នុងគតិមនោគមវិជ្ជាកុម្មុយនីស្តរបស់អ្នកទាំង២។ ក្រោយមកបានជួបនិងពួកខ្មែរដែលចូលរួមវាយប្រហារជាមួយយៀកមិញ (ដែលគេទាំងអស់យល់ថាជាពួកលក់ខ្លួនឲ្យយួនយៀកមិញ) គេមានគំនិតថានិងបង្កើតគណៈបក្សដែលមានវិន័យតឹងរឹងមានកាន់អាវុធ ទើបអាចសំរេចការបដិវត្តន៏បាន។ ពួកគេចាប់ប្តូរសមាគមនិស្សិតខ្មែរ the **Khmer Students' Association** **(KSA)** ដែលមានសមាជិក ២០០នាក់ ទៅជា អង្គការស្នេហាជាតិពួកខាងឆ្វេង។ នៅខាងក្នុងអង្គការនេះ មាន អ្នករង្វង់មូលម៉ាកស៊ីស្ត the **Cercle Marxiste (Marxist Circle)**។ អង្គការនេះមានអ្នកដឹកនាំមែនទែន ៣ទៅ៦នាក់ ចំណែកអ្នកភាគច្រើនគ្មានដឹងអ្វីសោះអំពីការរៀបចំផែនការណ៏របស់គណៈបក្ស។ នៅឆ្នាំ១៩៥២ ប៉ុលពត ហ៊ូយន់ អៀងសារី និងមិត្តភក្តិឯទៀត ដោយមានស៊ីញ៉េពីនិស្សិតទាំងអស់ ផ្ញើរសារទៅសម្តេចនរោត្តមស៊ីហនុ ឲ្យនាមព្រះអង្គជា "អ្នកច្របាច់កកូនង៉ែតប្រជាធិបតេយ្យ"។ មួយឆ្នាំក្រោយ មកអាជ្ញាធម៏បារាំងបិទទ្វារ សមាគមនិស្សិតខ្មែរនៅប៉ារីស។ ផ្ទុយទៅវិញ នៅឆ្នាំ១៩៥៦ ហ៊ូយន់ និង ខៀវសំផន បង្កើតជាក្រុមថ្មី

សហគមនិស្សិត ខ្មែរ។ នៅក្នុងការដឹកនាំនេះមាន អ្នករង្វង់មូលម៉ាកស៊ីស្ត ជាអ្នកដឹកនាំដដែល។

ការសរសេរក្បួនតម្រាវិទ្យានិពន្ធវិជ្ជបណ្ឌិតរបស់ ហ៊ូយន់ និង ខៀវសំផន មានសំដែងការប្រតិបត្តិដែលមានកើតឡើងនៅប្រទេសកម្ពុជាពេលដែល ខ្មែរក្រហមឡើងកាន់ដំណែង ដេញប្រជារាស្ត្រពីក្រុងទៅជនបទ។ ការសរសេរជាតំរុយនៃនិក្ខេបបទវិជ្ជបណ្ឌិតរបស់ហ៊ូយន់ឆ្នាំ១៩៥៥ ដែលមានចំណងជើងថា ប្រជាជនបទខ្មែរនិងការជឿនលឿនទៅមុខ **Hou Yuon 1955 thesis, *The Cambodian Peasants and Their Prospects for Modernization*** រៀបរាប់ថាការរីកដុះដាលរបស់ប្រជាជននៅស្រុកស្រែ រួចហើយការវិវត្តន៏ឧស្សាហក្ម ជាទីលើកដំបូងធ្វើឲ្យបានមុននិងមានការជឿនលឿនកើតឡើងដល់ប្រទេសជាតិ។ មានការពិភាក្សាធំវែកញែក១ទៀតនៃនិក្ខេបបទវិជ្ជបណ្ឌិតរបស់ខៀវសំផន ឆ្នាំ១៩៥៩ ឈ្មោះថា សេដ្ឋកិច្ចប្រទេសខ្មែរនិងការវិវត្តន៏ឧស្សាហកម្មជឿនលឿន **Khieu Samphan's 1959 thesis, *Cambodia's Economy and Industrial Development*** បកស្រាយថា ប្រទេសជាតិត្រូវមាន ការពឹងពាក់ដោយខ្លួនឯង ឈប់ពឹងពាក់សេដ្ឋកិច្ចជំនួយពីប្រទេសឯទៀត។ ស្រប និងន័យនេះ ខៀវសំផន ចង់និយាយពីអានុភាពឥទ្ធិពលរបស់ "ទ្រឹស្តីពឹងពាក់"របស់ប្រទេសក្រីក្រ មិនប្រឹងខ្លួនឯងបែរជា បន្ទោស ការគាបសង្កត់សេដ្ឋកិច្ចអំពីប្រទេសឧស្សាហកម្មនិងអ្នកមានៗឯទៀត។

## ***គណៈបក្សប្រជាជនបដិវត្តន៏ខ្មែរ KPRP សមាជិកសភាជំនាន់ទី២***

ក្រោយពីការត្រឡប់មកដល់ប្រទេសខ្មែរវិញនៅឆ្នាំ១៩៥៣ ប៉ុលពត ដាក់ខ្លួនចូលបំរើធ្វើការឲ្យគណៈបក្ស។ ដំបូងចូលជាមួយទ័ពខ្មែរដែលវាយប្រយុទ្ធជាមួយទ័ពយៀកមិញនៅខែត្រកំពង់ចាម។ ក្រោយពីសង្គ្រាមចប់ចូលមកភ្នំពេញធ្វើការឲ្យ ទូសាមុត "គណៈកម្មការកុម្មុយនីស្តទីក្រុង" ជាអ្នកសំខាន់ទាក់ទងជាមួយសមាជិកគណៈបក្សខាងឆ្វេងចេញមុខលើដី និង ចលនាកុម្មុយនីស្តលួចលាក់ក្រោមដី។ សមៈមិត្តរបស់ប៉ុលពត អៀងសារី និង ហ៊ូយន់ បង្រៀននៅសាលាវិទ្យាល័យឯកជន កម្ពុបុត្រ ដែលបង្កើតឡើងដោយហ៊ូយន់។ ខៀវសំផន ត្រឡប់ពីប៉ារីស ឆ្នាំ១៩៥៩ ធ្វើសាស្ត្រាចារ្យបង្រៀនច្បាប់នៅសាលាមហាវិទ្យាល័យភ្នំពេញ ហើយចាប់បើកកាសែតខាងឆ្វេងជាភាសាបារាំង អ្នកសង្កេតការណ៏ *L'Observateur* ។ បន្តិចក្រោយមកកាសែតចាប់ផ្តើមមានឈ្មោះល្បីក្នុងចំណោមអ្នកសិក្សា១ភាគនៅភ្នំពេញ។ ១ឆ្នាំបន្ទាប់មករាជដ្ឋាភិបាលបិទកាសែត ហើយប៉ូលីសរបស់សម្តេចនរោត្តមស៊ីហនុ វុគគួននិងវាយតប់ខៀវសំផនជាសាធារណៈ ចាប់សំរាតខោអាវ ថតរូប – លោកអ្នកសរសេរប្រវត្តិសាស្ត្រ ស្តុក្រស្ស បរិយាយថា "គឺជាការប្រមាថ១ ដែលមនុស្សម្នាក់មិនអាចលើកលែងទោស ឬ បំភ្លេចបាន"។ ប៉ុន្តែផ្ទុយទៅវិញរឿងនេះមិនបញ្ឈប់ ខៀវសំផន ធ្វើការសហប្រតិបត្តិការណ៏ជាមួយសម្តេច ផ្សព្វផ្សាយជាគំនិតរួមប្រឆាំងនិងសហរដ្ឋអាមេរិកនៅវៀតណាមខាងត្បូង។ ដូចមាននិយាយមកហើយ ខៀវសំផន ហ៊ូយន់ និង ហ៊ូនីម បានបង្ខំខ្លួនធ្វើការជាមួយរាជដ្ឋាភិបាលសម្តេច បំរើគណៈបក្សសង្គមរាស្ត្រនិយម កាន់ដំណែងផ្សេងៗក្នុងរាជដ្ឋាភិបាល។

នៅចុងខែកញ្ញាឆ្នាំ១៩៦០ អ្នកដឹកនាំកុម្មុយនីស្ត **KPRP** ២១នាក់ បានមកប្រជុំគ្នា ជាសម្ងាត់នៅស្ថានីយរទេះភ្លើងភ្នំពេញបន្ទប់ដែលគេមិនប្រើការ។ ការប្រជុំនេះបានគ្របដណ្តប់ដោយអាថ៌កំបាំងពីព្រោះ

លទ្ធផលនៃការប្រជុំមានការមិនស្រុះស្រួលគ្នា (រាប់ទុកជាការសរសេរប្រវត្តិសាស្ត្រជាសារថ្មី) រវាងអ្នកដឹកនាំចូលចិត្តយៀកណាម និងអ្នកមិនចូលយៀកណាម។ សំនួរដែលតម្រូវឲ្យធ្វើសហប្រតិបត្តិការជាមួយសម្តេច ឬ មិនត្រូវៗបានវែកញែកយ៉ាងក្បោះក្បាយ។ ទូសាមុត ដែលជាអ្នកចាត់ចែងឲ្យធ្វើការជាមួយសម្តេចឬមិនធ្វើ ត្រូវបានគេបោះឆ្នោតឲ្យធ្វើជាលេខាធិការទូរទៅ ហើយគណៈបក្សដូរឈ្មោះពី **KPRP** ទៅជាគណៈបក្សអ្នកធ្វើការកម្ពុជា**Workers' Party of Kampuchea** **(WPK)**។ មិត្តជិតស្និទ្ធរបស់ទូសាមុត នួនជា (មានឈ្មោះជា ឡុងរេត ដែរ) បានបោះឆ្នោតជា អនុលេខាធិការ។ ប៉ុលពត និង អៀងសារី បានជាប់ជាអ្នកដឹកនាំទី៣ និង ទី៥ តាមឋានន្តរសក្តិនៃគណៈបក្ស។ ការដូរឈ្មោះគណៈបក្ស គឺការធ្វើតាម ហូជីមិញ ដែលទើប និងដូរ គណៈបក្សកុម្មុយនីស្តឥណ្ឌូចិនទៅ គណៈបក្សអ្នកធ្វើការយៀកណាម **the Vietnam Workers' Party**។ ពួកអ្នកដឹកនាំរបបចូលដៃនិងយួន ហ៊ុនសែន គណៈបក្សប្រជាជនខ្មែរ **Cambodian Poeples's Party (CPP)** បានបញ្ជាក់នៅ ឆ្នាំ១៩៨០ថ្មីៗនេះដែរ ថា ការជំនុំខែកញ្ញាឆ្នាំ១៩៦០ មិនក្រៅពីគណៈបក្ស បដិវត្តន៏ប្រជាជន **the KPRP** សមាជិកសភាជំនាន់ទី២។

នៅថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៦២ ទូសាមុត ត្រូវសម្លាប់ដោយរាជដ្ឋាភិបាលរបស់សម្តេចព្រះនរោត្តមស៊ីហនុ។ នៅខែកុម្ភៈឆ្នាំ១៩៦៣ ប៉ុលពត ត្រូវបានជ្រើសរើសជា លេខាធិការ បន្តពីទូសាមុត គណៈបក្ស **KPRP** សមាជិកសភាជំនាន់ទី២។ អ្នកជិតដិតទូសាមុត នួនជា និង កែវមាស ត្រូវដកចេញហើយដាក់ជំនួស សុនសែន និង វនវិត។ ចាប់តាំងពីពេលនេះទៅ ប៉ុលពត និង មិត្តភក្តិស្មោះអំពីក្រុង ប៉ារីស ចាប់កាន់ផ្ទៃកណ្តាលសំខាន់របស់ចលនា ផ្តាច់អ្នកដឹកនាំជើងចាស់ដែលចូលចិត្តយួន។

នៅខែកក្កដាឆ្នាំ១៩៦៣ ប៉ុលពត និង សមាជិកគណៈកម្មការកណ្ដាលចេញពីភ្នំពេញទៅចាត់ចែងរៀបចំទ័ពនៅ ខែត្រូវតណៈគីរី ស្ថិតនៅទិសឥសាន្តនៃប្រទេសខ្មែរ។ មុនពេលនេះបន្តិចដែរ ប៉ុលពត ត្រូវបានសម្ដេចនរោត្តមស៊ីហានុរាប់បញ្ចូលក្នុងបញ្ជីឈ្មោះមនុស្ស៣៤នាក់ដែលត្រូវកោះហៅឲ្យទៅជួបព្រះអង្គ ស៊ីញ៉េថាព្រះអង្គជារាជាតែ១អង្គគាត់ដែលអាចដឹកនាំប្រទេសខ្មែរពេលនោះ។ មានតែប៉ុលពតនិងជូចិតពីរនាក់គត់ដែលមានឈ្មោះក្នុងបញ្ជីតែមិនបានស៊ីញ៉េញត្តិថ្វាយសម្ដេច។ អ្នកឯទៀតដែលស៊ីញ៉េធ្វើសហប្រតិបត្តិការត្រូវបានប៉ូលីសតាមឃ្លាំមើល២៤ម៉ោង។

ដំបន់ដែលប៉ុលពត និងសមាជិកឯទៀតក្នុងចលនាចូលទៅនៅគឺដំបន់កុលសម្ព័ន្ធខ្មែរលើៗដែលមិនសប្បាយចិត្តដោយត្រូវរាជដ្ឋាភិបាលបង្ខំឲ្យផ្លាស់ប្ដូរលំនៅ ឬឲ្យចូលជាសង្គម ជាការងាយនិងពន្យល់ឲ្យចុះចូលជាកងទ័ពឈ្លបតស៊ូប្រឆាំងរបស់គេ។ នៅឆ្នាំ១៩៦៥ ប៉ុលពត បានទៅនៅរៀនជាច្រើនខែនៅវៀតណាមខាងជើងនិងប្រទេសចិន។ ពេលដែលបានត្រឡប់មកវិញ មានកិត្តិយសណាស់ចំពោះមិត្តដឹកនាំឯទៀតក្នុងដំបន់រំដោះ។ ថ្វីបើពេលនោះសម្ដេចនរោត្តមស៊ីហានុត្រូវរ៉ូវនិងប្រទេសចិននិងវៀតណាមខាងជើង ការធ្វើទស្សនៈកិច្ចរបស់ប៉ុលពតនៅស្ថិតជាការសម្ងាត់អាថ៌កំបាំងដល់សម្ដេច។ នៅខែកញ្ញាឆ្នាំ១៩៦៦ គណៈបក្សដូរឈ្មោះទៅ គណៈបក្សកុម្មុយនីស្តកម្ពុជា **the Kampuchean (or Khmer) Communist Party (KCP)**។ ការដូរឈ្មោះត្រូវពួកគេរក្សាជាការសម្ងាត់មិនឲ្យសមាជិកតូចតាចដឹង សូម្បីយៀកណាមក៏មិនឲ្យដឹងដែររហូតដល់ថ្ងៃក្រោយមកបានដឹង។

# ជំពូក ទី៦

# ប្រទេសខ្មែរឆ្នាំ១៩៧០-១៩៧៥(ខ្មែរសាធារណរដ្ឋ)

ពេលដែលសម្តេចនរោត្តមសីហនុទៅបរទេសឆ្នាំ១៩៧០ ព្រះអង្គត្រូវរំលំអំពីអំណាចដោយរដ្ឋប្រហារធ្វើដោយឧត្តមសេនីយលន់ណុល។ សម្តេចភាសព្រះអង្គទៅជ្រកកោននៅប្រទេសចិន។ ឧត្តមសេនីយលន់ណុល ពេលនោះជានាយករដ្ឋមន្ត្រី ធ្វើរដ្ឋប្រហារសង្ស័យមថានិងបានជំនួយអំពី សហរដ្ឋអាមេរិកផ្តុយទៅវិញសហរដ្ឋអាមេរិកដែលរវល់ដៃជាមួយសង្គ្រាមយួនមិនអាចជួយបាន។ ពេលជាមួយគ្នានេះកងទ័ពខ្មែរខ្សោយគ្មានសម្ភារៈ មិនអាចបញ្ឈប់កងទ័ពយួនខាងត្បូងដែលដេញតាមកងទ័ពយួនខាងជើងនៅលើទឹកដីប្រទេសខ្មែរបាន។

ក្នុងឱកាសរដ្ឋប្រហារនេះដែរ ឪពុកទើបនិងចាប់ផ្តើមរៀនឆ្នាំទី១នៅសាលាមហាវិទ្យាល័យវិទ្យាសាស្រ្តភ្នំពេញ។ ការទម្លាក់របបរាជានិយមបង្កើតឡើងរបបសាធារណៈគឺជាការ១ដែលធ្វើឲ្យយើងក្មេងៗ អ្នកសិក្សាអ្នកបញ្ញាវន្ត មានសេចក្តីសប្បាយរីករាយអស្ចារ្យ។ មានយុវជនក្មេងៗជាច្រើនស្ម័គ្រចិត្តចូលធ្វើជាកងទ័ពទាហានច្បាំងជាមួយកុម្មុយនីស្ត។ ក្រោយមកពួកយុវជនខ្លះក៏ត្រូវគេចាប់ទាំងបង្ខំឲ្យធ្វើជាទាហានដែរ។ ផ្លូវធំៗទាក់ទងនិងរដ្ឋធានីភ្នំពេញត្រូវបានកាត់ផ្តាច់ដោយទ័ពកុម្មុយនីស្ត។ ពុកនៅរៀននៅមហាវិទ្យាល័យគ្មានស្បៀងអាចផ្តល់អំពីជីតាឯងអំពីខែត្រពោធិសាត់។ ពុកសំរេចចិត្តចូលធ្វើជាទាហាន កងពលទ័ពជាតិខ្មែរ *Force Armée Nationale Khmère* : **FANK** រួចហើយត្រូវក្រសួងបញ្ជូនឲ្យទៅរៀននៅវិទ្យាស្ថានកងទ័ពខ្មែរសាលានាយទាហានជំនាន់ទី២៨

ដែលមាននិស្សិតនាយទាហានទាំងអស់ ២៩៥នាក់។ ពុកប្រឡងចេញបានលេខ៣ អំពីសាលានាយទាហាន។ មកដល់សព្វថ្ងៃមានមិត្ត ១១នាក់នៅមានជីវិតក្នុងចំណោម ២៩៥នាក់: ពុក និង ៦នាក់ទៀតរស់នៅសហរដ្ឋអាមេរិក រដ្ឋកាលីហ្វ័នីយ៉ា និង ៨នាក់ទៀតរស់នៅឯប្រទេសកម្ពុជា។ សល់ពីនោះត្រូវស្លាប់ក្នុងសង្គ្រាមសាធារណៈរដ្ឋ ១៩៧០-១៩៧៥ និងស្លាប់ក្រោមរបបប៉ុលពត ១៩៧៥-១៩៧៩។

បន្ថែមជាបញ្ហាដល់លោក លន់ណុល សង្គ្រាមផ្ទៃក្នុងជាទូរទៅកើតឡើង១រំពេជ។ សម្តេចនរោត្តមស៊ីហនុត្រូវបញ្ចុះបញ្ចូលឲ្យចូលដៃជាមួយខ្មែរក្រហម បង្កើតរដ្ឋាភិបាលក្រៅប្រទេសធ្វើចំបាំងនិង សាធារណៈលន់ណុល។ កងទ័ពខ្មែរក្រហមដែលមានកងទ័ពយួនពីក្រោយ ជាបន្លាក្នុងកែវភ្នែករបស់របបលោកលន់ណុល រហូតដល់ថ្ងៃបញ្ចប់។ ការទម្លាក់គ្រាប់បែកនៅជនបទ ជាហេតុបណ្តាលឲ្យបាត់ប្រជាប្រិយ៍ហើយក៏ជាលំនាំ១ ឲ្យរបបសាធារណៈចាញ់ខ្មែរក្រហមទៅថ្ងៃក្រោយដែរ។

## ***ជីវប្រវត្តិ***

ប្រកាសឡើងជាផ្លូវការណ៏ ខែតុលា ឆ្នាំ១៩៧០ ជា សាធារណៈប្រទេសខ្មែរ មានដើមកំណើតជា បក្សខាងស្តាំ ចូលចិត្តសហរដ្ឋអាមេរិក ជារដ្ឋាភិបាលកងទ័ព ដឹកនាំដោយលោកឧត្តមសេនីយលន់ណុល និង អង្គម្ចាស់ស៊ីសុវត្ថិសិរិម៉ាតាក់ ឡើងកាន់កាប់អំណាចថ្ងៃទី១៨ខែមិនាឆ្នាំ១៩៧០ដោយធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមស៊ីហនុដែលជាអ្នកដឹកនាំប្រទេសពេលនោះ។

រឿងធំដែលបង្ករឲ្យមានរដ្ឋប្រហារ គឺសម្តេចព្រះនរោត្តមសីហនុអនុញ្ញាតិឲ្យកងទ័ពយួនខាងជើងកាន់កាប់ពេញទឹកដីផ្នែកខាងកើតនៃប្រទេសខ្មែរ។ មានប្រការ១ទៀតសេដ្ឋកិច្ចរបស់ប្រទេសធ្លាក់ដុនដាបដោយសារសម្តេចដើរតាមគោលនយោបាយអាផ្ញាកណ្តាលទាត់ចោលជំនួយសហរដ្ឋអាមេរិក។ ការដកសម្តេចចេញពីអំណាចធ្វើឲ្យរាជាណាចក្រកម្ពុជាក្លាយទៅជាប្រទេសសាធារណៈជាស្វ័យប្រវត្តន៏ ថ្វីបើព្រះរាជបល្ល័ង្កតាមការពិតគ្មានព្រះរាជាសោយរាជ្យ អស់ពេលជាច្រើនឆ្នាំក្រោយពីព្រះបាទនរោត្តមសូរាមីរិទ្ធ ទទួលសុរវណ្ណគតក៏ដោយ។ លក្ខណៈសម្បត្តិរបស់របបថ្មីគឺបក្សខាងស្តាំ អ្នកស្នេហាជាតិ ដែលចង់បំបាត់ការចូលដៃរបស់ សម្តេចសីហនុជាមួយយួនខាងជើងនិងវៀតកុង ហើយចូលខ្លួនជាមួយ យួនខាងត្បូងនិងសហរដ្ឋអាមេរិកធ្វើចំបាំងក្នុងសង្គ្រាមឥណ្ឌូចិនជាលើកទី២។ ប្រទេសខ្មែរសាធារណៈចាប់មានសង្គ្រាមជាមួយ ក្រុមថ្មី រណសិរ្សប្រជុំជាតិកម្ពុជា **the *Front Uni National du Kampuchea* or FUNK** គឺជាក្រុមដែលមានសម្តេចសីហនុនិងប្រជាជនហែរហាម និង គណៈបក្សកុម្មុយនីស្តកម្ពុជា ដែលមានប៉ុលពតជាមេ។ ថ្វីបើរប្រទេសសាធារណៈមាន លក្ខណៈសម្បត្តិកងទ័ពនិងជំនួយថវិការ អំពីសហរដ្ឋអាមេរិក កងទ័ព កងពលជាតិខ្មែរនេះ **the *Force Armée Nationale Khmère*, or FANK** មានកម្លាំងខ្សោយគ្មានការបង្ហាត់បង្រៀន មិនអាចប្រយុទ្ធប្រទល់និងកងទ័ពយួនខាងជើងនិងវៀតកុងបានឡើយ។ នៅថ្ងៃ ទី១៧ខែមេសាឆ្នាំ១៩៧៥ ប្រទេសខ្មែរសាធារណៈ ជាចុងបញ្ចប់ធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តខ្មែរដែលចូលមកកាន់កាប់យករដ្ឋធានីភ្នំពេញ។

## រដ្ឋប្រហារ

សម្តេចព្រះនរោត្តមសីហនុ នៅតែតវ៉ាថា រដ្ឋប្រហារទម្លាក់ព្រះអង្គមានមកអំពី ការជម្លោះរឿងចាស់ហើយត្រូវនិរទេសទៅសៀមរបស់ សឺងង៉ុកថាញ់ និងនយោបាយផ្ទៃក្នុងរបស់ព្រះអង្គម្ចាស់ ស៊ីសូវត្ថសិរិម៉ាតាក់ (ដែលសម្តេចតែងតែនិទានថាជាមេចង់ដណ្តើមរាជបល្ល័ង្កអំពីព្រះអង្គ) និង អង្គការស៊ើបអង្កេតសហរដ្ឋអាមេរិក ស៊ីអាយអេ CIA ដែលតែងតែចង់ផ្លាស់ប្តូរព្រះអង្គជាមួយអ្នកខាងស្តាំ។ មានការគាំទ្រតិចណាស់ដែលបញ្ជាក់ថា ស៊ីអាយអេ ចូលដៃជាមួយរដ្ឋប្រហារ ប៉ុន្តែការពិតមានកងទ័ពពិសេសមួកបៃតងសហរដ្ឋអាមេរិក បានធានាជួយគាំទ្រ ពេលដែលលន់ណុលពឹងឲ្យជួយ។

ពេលសម្តេចទៅធ្វើទស្សនកិច្ចនៅប្រទេសបារាំង បាតុកម្មប្រឆាំងនិងយួនកើតឡើងនៅភ្នំពេញ ពេលនោះទូតរបស់យួនខាងជើង និង វៀតកុងត្រូវបានបំផ្លិចបំផ្លាញ។ ការបះបោរនេះរៀបចំឡើងដោយនាយករដ្ឋមន្ត្រីលន់ណុលនិងអនុរដ្ឋមន្ត្រីព្រះអម្ចាស់ ស៊ីសូវត្ថសិរិម៉ាតាក់។ នៅថ្ងៃទី១២ ខែមិនា រដ្ឋមន្ត្រីបិទផែកប៉ាល់ ក្រុងស៊ីហានុ ដែលជញ្ជូនគ្រឿងស្បៀងនិងយោធារសម្ភារៈឲ្យយួនខាងជើងនិងយៀកកុង។ រួចហើយប្រកាសជាផ្លូវការឲ្យកងទ័ពយួនដកចេញពីប្រទេសខ្មែរក្នុងរយៈពេល៧២ម៉ោង ក្នុងថ្ងៃទី១៥ ខែមិនា បើមិនដូច្នេះទេនិងត្រូវដេញដោយកងទ័ព។

បើនិយាយអំពីការពិតវិញ ថ្វីបើមានការវិវត្តន៏ដូច្នេះ លន់ណុលមិនចង់ផ្លាស់ប្តូរសម្តេចអំពីអ្នកដឹកនាំប្រទេសទេ គ្រាន់តែចង់ឲ្យសម្តេចបង្អន់ការលុកលុយទឹកដីអំពីយួនខាងជើង។ ចាប់ដំបូងគាត់មិនព្រមធ្វើ ប៉ុន្តែផ្ទុយទៅវិញ "អង្គម្ចាស់សិរិម៉ាតាក់មានបំណាងធ្វើរដ្ឋប្រហារតាំងពីដំបូង"។ ដើម្បីនិងពន្យល់លន់ណុលអំពីការពិតព្រះអម្ចាស់ចាក់កាសែតស្តាប់ដែលគេញព្រះអង្គលួចថតការប្រជុំរបស់សម្តេចនៅ ក្រុងប៉ារីស

ថានិងធ្វើឃាត អ្នកទាំង២ (លន់ណុលនិងសិរិម៉ាតាក់) បើព្រះអង្គបាន យាងមកដល់ ប្រទេសវិញ។ មិនទុកចិត្តលន់ណុល ព្រះអង្គម្ចាស់ សិរិម៉ាតាក់ឲ្យ នាយទាហាន៣នាក់ យកក្រដាស់ស្នាមមាន កាំភ្លើងនៅដៃ ប្រគល់ឲ្យ លន់ណុលស៊ីញ៉េ លន់ណុល ស៊ីញ៉េដោយមានកាំភ្លើងភ្ជង់ទាំង ទឹកភ្នែក។

នៅថ្ងៃទី១៨ខែមិនា មានការបោះឆ្នោតនៅរដ្ឋសភាដែលមានលោក អ៊ិន **In Tam** ជាអ្នកដឹកនាំ ដកហូតដំណែងអំពីសម្តេចនរោត្តមស៊ីហនុ ហើយតែងតាំង លន់ណុល ជាអ្នកដឹកនាំប្រទេសក្នុងរយៈអាសន្ននោះ។ នៅថ្ងៃទី២៨និង២៩ខែមិនា មានបាតុកម្មជាច្រើនកើតឡើងតាមៗខែត្រ ប្រឆាំងនិងរដ្ឋាភិបាលថ្មីគាំទ្រស៊ីហនុ កងទ័ពលន់ណុលបាញ់សម្លាប់បាតុករ ជាច្រើនរយនាក់។ ខាងរដ្ឋាភិបាល វិញ មានអ្នកខ្លះត្រូវបាតុករសម្លាប់ដែរ រាប់បញ្ចូល ប្អូនប្រុសរបស់ លន់ណុល ឈ្មោះ លន់នីល។ ប្រទេស បរទេសជាច្រើនមិនដឹងកាន់អាកប្បកិរិយាយ៉ាងណាជាមួយរដ្ឋាភិបាលថ្មី។ ប្រទេសយួនខាងជើងនៅទទូចដាក់ទូតបន្តជំនួញជាមួយប្រទេសខ្មែរសាធារ ណៈរដ្ឋ តែការនេះមិនកើតមានឡើង រហូតដល់ពេលចុងបញ្ចប់។

## ***ការប្រកាសជា សាធារណៈ និង ការបង្កើតកងទ័ពជាតិ FANK***



កងទ័ពសេះ-រថក្រោះ លេខ១១របស់សហរដ្ឋអាមេរិក ចូលដល់ទឹកដីខ្មែរ ស្ទួល ជាដំបូង ថ្ងៃទី៩ខែឧសភា ឆ្នាំ១៩៧០

អ្វីដែលគួរកត់សម្គាល់ជាលទ្ធផលក្រោយពីរដ្ឋប្រហារគឺការឃោសនាផ្លូវយោធា ខែមេសា-ដល់ខែកក្កដា ឆ្នាំ១៩៧០ ពេលនេះកងទ័ពយួនខាងត្បូងដែលមានកងទ័ពសហរដ្ឋអាមេរិកពីក្រោយចូលដីខ្មែរខាងកើតដេញតាមយួនខាងជើងនិងវៀតកុង។ ថ្វីបើមានការវាយលុកនេះកងទ័ពកុម្មុយនីស្ដយួន រត់ចូលជ្រៅទៅទិសខាងលិចប្រទេសខ្មែរបង្កប់ខ្លួន ជួយកងទ័ពខ្មែរក្រហមក្នុងស្រុក វាយលុកកងទ័ពលន់ណុលឡើងវិញ។ លន់ណុល មានប្រតិកម្ម១រំពេជ គឺជាការខុសច្បាប់ដែលបរទេសលុកលុយ លើទឹកដីសាធារណៈខ្មែរ។ លន់ណុលធ្វើសេចក្តីរាយការណ៏ឲ្យ អាឡិចហ៊ែរូនឌើរហេគ **Alexander Haig** មេបញ្ជាការកងទ័ពអាមេរិក ថា ប្រទេសកម្ពុជាស្ថិតនៅក្នុងការគ្រោះថ្នាក់ណាស់របៀបនេះ សុំឲ្យកងទ័ពសហរដ្ឋជួយការពារកងទ័ពខ្មែរ ពេលដែលសហរដ្ឋប្រកែក លន់ណុលឃំស្រក់ទឹកភ្នែកជាសាធារណៈ ព្រោះស្របទៅតាមទ្រឹស្តី និចសុនថាមិនជួយខ្មែរវាយបំបាត់សត្រូវ ប៉ុន្តែសុខចិត្តប្រគល់អំណោយវិញ។

នៅថ្ងៃទី៩ខែតុលាឆ្នាំ១៩៧០ តុលាការកងទ័ព កាត់សេចក្តីប្រហារព្រះជន្មដល់ សម្តេចស៊ីហនុ។ ព្រះមាតាព្រះអង្គ ម្ចាស់ក្សត្រីយានី កុសូម៉ាក់ជាដំណាងរាជានិវង្សជំនាន់សម្តេចស៊ីហនុត្រូវជាប់ឃុំឃាំង ព្រះមហេសីអ្នកម្នាងមូនិកត្រូវកាត់ទោសជាប់ទីឃុំឃាំង១ជី វិត។ របបថ្មី ប្រកាសបង្កើតសាធារណៈរដ្ឋខ្មែរ ច្បាប់រដ្ឋធម្មនុញ្ញកើតឡើងនៅឆ្នាំ១៩៧២។ ពេលជាមួយគ្នានេះសម្តេចចាប់បង្កើតរាជដ្ឋាភិបាលក្រៅប្រទេសហៅថា **GRUNK** **(Gouvernement Royal d'Union Nationale du Kampuchéa)** មានមូលដ្ឋាននៅ ប៊ីជ៊ីង **Beijing** ប្រទេសចិន មានកងទ័ពខ្មែរក្រហមប៉ុលពត អមព្រះអង្គ ដើម្បីរំលំរបបសាធារណៈ។ សម្តេចជេរប្រទិចហៅ

លន់ណុល ជាមនុស្សល្ងង់ខ្លៅ ហៅ ស៊ីសូវត្ថសិរិម៉ាតាក់ ជាមនុស្សស្មោគគ្រោកក្បត់រាជបល្ល័ង្ក ជាមនុស្សកើតគ្មានខាន់ស្លា។

កងទ័ពរាជាកងទ័ព **FARK** មានគ្នាតិចណាស់ ៣៥,០០០នាក់ នៅពេលដែលសម្ដេច ស៊ីហនុប្រកាសពេលប្រជុំអន្តរជាតិជារាណាចក្រធិបតេយ្យអាផ្ទារកណ្ដាល។ កងទ័ពជាតិជំនាន់សាធារណៈ **FANK** បានឡើងទៅដល់ ១៥០,០០០ នាក់នៅចុងឆ្នាំ១៩៧០ ភាគច្រើនដោយការចូលស្ម័គ្រចិត្តរបស់ពលរដ្ឋដែលមានក្ដីស្នេហាជាតិប្រឆាំងនិងយួន។ សហរដ្ឋអាមេរិកអនុវត្តន៏គ្រោងការណ៏បើកបង្រៀនសាលាបង្វឹកបង្វើនទាហាន រៀបចំយន្តហោះបង្ហោះចូលពួកកងទ័ពខ្មែរសេរីបង្ហោះចូលកងឈ្លបជីវពលទ័ពខ្មែរកម្ពុជាក្រោម ដែលនៅរៀននៅមូលដ្ឋានទាហានសហរដ្ឋអាមេរិកនៅប្រទេសយួនខាងត្បូង។ នាយទាហានកងទ័ពបញ្ជាការសហរដ្ឋមានបំណងនិងជំឡើងកងទ័ពខ្មែរទៅដល់ ២០០,០០០នាក់ ដែលមុខនិងមានការទាក់ទងដល់សេដ្ឋកិច្ចប្រទេសខ្មែរ ថ្វីបើ ឧត្តមសេនីយ ត្អេអូឌ័រ សេ. មាតាអ្សីស **Theodore C. Mataxis** មេបញ្ជាការកងទ័ពសហរដ្ឋចែកចាយយោធាសម្ភារៈដល់កងទ័ពខ្មែរមានការប្រឆាំងថា កងទ័ពខ្មែរត្រូវដូររបបពីបារាំងទៅអាមេរិកាំងសិនបានធ្វើជំនួយបានជោគជ័យក៏ដោយ។

ថ្វីបើមានជំនួយយោធាសម្ភារៈអំពីសហរដ្ឋដល់កងទ័ពខ្មែរ **FANK** (ដែលដឹកនាំដោយលោកឧត្តមសេនីយ សុស្តែនហ្វែរណាង់ដេស **Sosthene Fernandez**) កងទ័ពខ្មែរត្រូវមានការពុករលួយផ្ទៃក្នុងយ៉ាងសម្បើមជាពិសេស កងពលដែលទាមទារថាមានចំនួនទាហានប៉ុន្តែគ្មានមនុស្សយកតែប្រាក់ខែរវាយចំបាំងគ្មានឥទ្ធិពល។ ទោះបីជាដូច្នេះក៏ដោយ មានអម្ចាស់មេបះបោរម្នាក់ជំនាន់ដើមដែល ឧត្តមសេនីយលន់ណុល អង្វរឲ្យ

ចេញពីវៀតណាមមកជួយធ្វើចំបាំង ឧត្តមសេនីយ៍ នរោត្តមចាន់វង្គស៊ី កាន់កាប់ កងពលតូចលេខ១៣ ដែលមានជោគជ័យការពារសន្តិសុខដំបន់សំខាន់ ផ្លូវជាតិលេខ៤និងមណ្ឌលគីរីរម្យជាជាងឧត្តមសេនីយ៍ឯទៀតៗដែលមាន ការពិសោធន៏តិចបំផុតឬក៏គ្មានសោះកាន់កងទ័ព។ ចំបាំងដែលបានធ្វើយ៉ាងធំរបស់កងទ័ពខ្មែរ FANK គឺការវាយលុកដេញយួន ប្រតិបត្តិការចេនឡាទី១ និង ចេនឡាទី២ ដែលមានជ័យជំនះទៅកងទ័ពយួន ថ្វីបើកងពលកងទ័ពថ្មើរជើងខ្មែរមានសេចក្តីក្លាហានយ៉ាងណាក៏ដោយ។

## *ប្រវត្តិសាស្ត្រ នយោបាយ របស់របបសធារណៈខ្មែរ*

ជាមួយគ្នាដែលរបបសាធារណៈធ្វើសង្គ្រាមផ្ទៃក្នុងរវាងទ័ពហែរហមសម្តេច និងកងទ័ពខ្មែរក្រហម និងទ័ពបរទេសយួនខាងជើង នយោបាយផ្ទៃក្នុងរបបសាធារណៈក៏មិនស្របស្រួលគ្នាដែរ។ គណៈបក្សសម្តេចដែលគាបសង្កត់ត្រួតត្រាពីឆ្នាំ ១៩៥០ឡើង និង ១៩៦០ឡើង ធ្វើឲ្យគណៈបក្សថ្មីដែលកើតឡើងគ្មានការពីសោធន៏និងរស់រានជា១គ្នាទៅវិញទៅមក បណ្តាលឲ្យមានការជម្លោះគ្នារវាងអ្នកនយោបាយ។ ចាប់ពីដំបូងដៃមានការជម្លោះរវាងអ្នកនយោបាយដែលទើបបែកចេញអំពីគណៈបក្សសម្តេច អ្នកមេធំគឺរវាងលន់ណុល និង ស៊ីសូវ៉ត្ថសិរិម៉ាតាក់ដណ្តើមអំណាចគ្នា។ នៅពេលដែលលន់ណុលមានសុខភាពដុនដាប ត្រូវទៅព្យាបាលជម្ងឺនៅបរទេស (រដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក) អម្ចាស់សិរិម៉ាតាក់ឡើងកាន់កាប់ជា រដ្ឋមន្ត្រីរដ្ឋាភិបាលជំនួសរបស់សាធារណៈ១ឆ្នាំដំបូង ប៉ុន្តែព្រះអង្គម្ចាស់មិនត្រូវមានប្រជាប្រិយ៏សោះ ដោយទី១មកអំពីការគំរូចាត់ចែងរដ្ឋាភិបាលរបស់ព្រះអង្គមិនមានជោគជ័យ និង ទី២ព្រះអង្គជារាជវង្សរបស់ព្រះរាជាខ្មែរ។

ម្យ៉ាងទៀត រដ្ឋាភិបាលមានការពុករលួយ គ្មានប្រសិទ្ធភាពកាន់តែខ្លាំងផង ដែរ ជាហេតុឲ្យមានការំជើបរំជួលរវាងយុវជនក្មេងៗនៅទីក្រុង។ នៅពេល ដែលលន់ណុល ត្រឡប់មកពីហាវ៉ៃ ព្យាបាលខ្លួនវិញ ខែមេសា១៩៧១ លោកចាប់ផ្តើមបង្កហេតុ ដោយលាលែងជានាយករដ្ឋមន្ត្រី ក្រោយមក រំលាយរដ្ឋាភិបាល តាមការពិតមកអំពីកាស្នើរបស់ប្អូនប្រុស លន់ណុន (ពេលនោះជាមេកោយក្នុងអ្នកដឹកនាំកងទ័ព)។ ក្រោយអំពី ការប្រទាញ ប្រទង់ក្នុងផ្លូវនយោបាយ រដ្ឋាភិបាលថ្មីកើតឡើង ប៉ុន្តែនៅមាន អម្ចាស់ សិរិម៉ាតាក់ កាន់កាប់ជានាយករដ្ឋមន្ត្រីជំនួសដដែល តែមានចំណងជើងថ្មី ហៅថា "នាយករដ្ឋមន្ត្រីប្រតិភូ"។ នៅថ្ងៃទី១៦ខែតុលាឆ្នាំ១៩៧១ លន់ណុល ចាប់ផ្តើមទម្លាក់អំណាចរដ្ឋសភា បញ្ជូឲ្យសរសេរច្បាប់ រដ្ឋធម្មនុញ្ញជាថ្មី ដោយយកលេសថាដើម្បីបញ្ឈប់អានាធិបតេយ្យ។ រឿងនេះធ្វើឲ្យមានការបះបោរអំពី អ៊ិនតាំ និង ព្រះសង្ឃ ៤០០ អង្គ។

## ***<u>ឆ្នាំ១៩៧២:ការដក អម្ចាស់ សិរិម៉ាតាក់ ចេញ</u>***

មកដល់ខែមិនា ឆ្នាំ១៩៧២ លន់ណុល និង ប្អូនប្រុស លន់ណុន បានគៀង សិរិម៉ាតាក់ ចេញពីអំណាច។ ក្រោយពី សិរិម៉ាតាក់ ទម្លាក់ កែវអាន **<u>Keo An</u>** អ្នកប្រឆាំងនិងការអប់រំអក្សរសាស្ត្រចេញ លន់ណុលរៀបចំក្បួន បាតុកម្មក្នុងចំណោមនិស្សិតឲ្យទម្លាក់ សិរិម៉ាតាក់។ សិរិម៉ាតាក់លាលែង ដំណែង (តាមការកំញែងការពិតជាការពារសេចក្តីសុខរបស់ខ្លួន) រួច ហើយត្រូវដាក់ក្នុងផ្ទះឃុំឃាំង។ លន់ណុលឆ្លៀតឱកាសនេះទម្លាក់ប្រមុខរដ្ឋ ចេងហេង **<u>Cheng Heng</u>** ហើយតែងតាំងខ្លួនឯងជាប្រមុខរដ្ឋ ហើយ ចាត់តាំង សឺងង៉ុកថាញ់ អ្នកជើងចាស់ខាងស្តាំប្រឆាំងនិងសម្តេច ជានាយករដ្ឋាភិបាល។ សឺងង៉ុកថាញ់ជាមេដឹកនាំកងទ័ពខ្មែរសេរី បានជួយ

កែនរើសកងទ័ពខ្មែរក្រោមហាត់រៀនជាមួយទ័ពសហរដ្ឋ ក្រោយមកឲ្យចូលជាកងទ័ពសាធារណៈ ជួយធ្វើឲ្យ **FANK** មានថាមពល គឺជាសគុណនិងការទំនុកបំរុងសំខាន់ដល់ រដ្ឋាភិបាលសាធារណៈដែលទន់ខ្សោយ។ ពេល ១ឆ្នាំក្រោយលន់ណុលប្រកាសឲ្យមានការបោះឆ្នោតរើសប្រធានាធិបតី ហើយមានការភ្ញាក់ផ្អើលដោយមាន អ៊ិនតាំ និង កែវអាន ឈរឈ្មោះ។ កែវអាន មានកេរ្តិ៍ឈ្មោះជាអ្នកកាន់ជើងសម្តេច។ អ្នកទាំង២ មិនត្រឹមតែប្រកាសខ្លួនជាបេក្ខជន ប្រកែកមិនដកឈ្មោះវិញ។ ការបោះឆ្នោតថ្មីបើលន់ណុលឈ្នះជាការជាសមិនផុត បង្ហាញឲ្យឃើញការមិនស្របស្រួលគ្នាក្នុងសាធារណះ។ មានការរាយការណ៏ថាមានការមិនត្រឹមត្រូវក្នុងការរាប់សន្លឹកបោះឆ្នោត មានមតិខ្លះថា បើរាប់ត្រឹមត្រូវ អ៊ិនតាំ និងឈ្នះ។ រឿង នេះធ្វើឲ្យ អ៊ិនតាំ ប្រកាសថា "អាមេរិកាំងត្រូវលន់ណុលដាក់ចូលស្មោរក្នុងទឹកស៊ុបរបស់លន់ណុល"។

ស្ថានការណ៏នយោបាយ នៅតែបន្តការទាស់ទែងរហូតដល់ឆ្នាំ១៩៧២ មានគណៈបក្សប្រឆាំង២ គណៈបក្សអ៊ិនតាំប្រជាធិបតេយ្យ **Democratic Party** និង គណៈបក្សសិរិម៉ាតាក់សាធារណៈរដ្ឋ **Republican Party** ប្រកែកមិនចូលបោះឆ្នោតជ្រើសរើសដំណាងរដ្ឋសភា ជាមួយគណៈបក្សសង្គមសាធារណៈរដ្ឋ របស់ លន់ណុល **Socio-Republican Party** (***Sangkum Sathéaranak Rậth***) ដែលធ្វើឲ្យលន់ណុលឈ្នះរដ្ឋសភាទាំងមូលនៅខែកញ្ញាឆ្នាំ១៩៧២។ ឆ្នាំនេះចាប់មានភេរវកម្មគប់គ្រាប់បែក បាញ់គ្នា នៅរដ្ឋធានីភ្នំពេញជាញឹកញាប់។ មានភេរវកម្ម១ បំណងជីវិតនាយករដ្ឋមន្ត្រី សឺងង៉ុកថាញ់ ដោយលោកបានធ្វើសកម្មភាពចុងក្រោយបំផុត គឺ បិទកាសែតសិរិម៉ាតាក់។ សឺងង៉ុកថាញ់ត្រូវបង្ខំឲ្យលាលែងពីដំណែង ដកខ្លួនថយទៅនិរទេសឯប្រទេសយួនខាងត្បូងវិញ ហើយដាក់តាំង ហង់ធុនហាក់ អ្នកនយោបាយកណ្តាលឲ្យធ្វើជានាយករដ្ឋ

មន្ត្រីជំនួស។ ក្រោយពេលដែលរដ្ឋាភិបាលសាធារណៈខ្មែរចាប់ចុះខ្សោយ ដោយការវាយប្រហារពីយួនខាងជើង មានប្រតិបត្តិការ ចេនឡាទី១ ចេនឡាទី២ជាដើម យួនខាងជើង ចាប់បន្ថយទ័ពទៅខាងយួនខាងត្បូងវិញ ទុកតែកងទ័ពគាំទ្រ និង ទ័ពផ្គត់ផ្គង់ ឲ្យការវាយប្រហារធំៗទៅកងទ័ពកុម្មុយនីស្តខ្មែរក្រហម និង កងទ័ពហែរហមសម្តេចនរោត្តមសីហនុ ដែលចាប់មានកើនឡើងច្រើន ជាលំដាប់ ដោយប្រជារាស្ត្រជនបទនៅតែស្រឡាញ់ស្ម័គ្រនិងសម្តេចឪជានិច្ច។

## *ឆ្នាំ១៩៧៣: ការប្រកាសឈប់ប្រយុទ្ធ និង ការផ្ដាករង្វេសនាវាជាតិ*

ការព្រមព្រាងសន្តិភាពនៅប៉ារីស ដើមឆ្នាំ១៩៧៣ផ្តល់ឲ្យមាន ការពន្យាសង្គ្រាមផ្ទៃក្នុងរបស់ប្រទេសខ្មែរ: លន់ណុល ប្រកាសឲ្យឈប់បាញ់គ្នាជាឯកតោភាគី ថ្វីបើកងទ័ព **FANK** មានកម្លាំងខ្សោយលើសមរភូមិ។ តាមការពិតមានការទាក់ទងជាសម្ងាត់របស់សមាជិកខ្មែរក្រហមដែលជាអ្នក

កណ្តាល ហ៊ូយន់ និង របបសាធារណៈលន់ណុល។ យួនខាងជើងបង្ខំកងទ័ពកុម្មុយនីស្តខ្មែរឲ្យទទួលស្គាល់ការព្រមព្រាងប៉ារីស ការសំខាន់របស់គេគឺទុកសង្គ្រាមឲ្យនៅឆេះឆួល ទាញយកទ័ពយួនខាងត្បូងជាមួយផង មិនគិតដល់ជ័យជំនះឲ្យកុម្មុយនីស្តខ្មែរក្រហមទាល់តែសោះ។ មេដឹកនាំខ្មែរក្រហមផ្ទុយទៅវិញ មិនព្រមដកថយឈប់ចំបាំងសោះ។

ការចាប់បាញ់គ្នា ចាប់ផ្តើមឡើងវិញនៅយប់ថ្ងៃទី៧ខែកុម្ភៈឆ្នាំ១៩៧៣ ទ័ពកុម្មុយនីស្តវាយឡោមព័ទ្ធកងទ័ព **FANK** យកបានទីក្រុងខែត្រកំពង់ធំ។ មកដល់ខែមេសា របបសាធារណៈធ្លាក់ចូលក្នុងភាពច្របូកច្របល់កូនទាហានកងទ័ព **FANK** ប្រកែកមិនព្រមច្បាំង ចាប់លួចឆក់ទីក្រុង

រដ្ឋធានី។ ជាមួយគ្នាកងទ័ពខ្មែរក្រហមវាយយកកន្លែងសំខាន់ៗពេញ
ប្រទេស។ ជាចម្លើយផងដែរ សហរដ្ឋអាមេរិក កំញើញនិងកាត់ជំនួយ
បើលន់ណុល មិនពង្រីកអ្នកកាន់កាប់រដ្ឋាភិបាល ឲ្យមានបញ្ចូលមកវិញ
អម្ចាស់សិរិម៉ាតាក់ ដែលជាអ្នកចូលជើងសហរដ្ឋ និង បន្ថយអំណាចអំពី
ប្អូនប្រុស លន់ណុន។ ព្រោះហេតុនោះនៅថ្ងៃទី២៩ខែមេសាលន់ណុល
ប្រកាស បញ្ឈប់បណ្ដោះអាសន្នរដ្ឋសភា បង្កើតក្រុមប្រឹក្សានយោបាយ១
មាន លន់ណុល សិរិម៉ាតាក់ ចេងហេង និង អ៊ិនតាំ កាន់កាប់ប្រទេស
ដោយក្រិត គឺមិនមានការបោះឆ្នោតទេ។ ការវាយទៅមុខចូលរដ្ឋធានីភ្នំពេញ
ដោយកងទ័ពខ្មែរក្រហមនិងទ័ពសម្ដេចស៊ីហានុត្រូវបញ្ឈប់ដោយការទម្លាក់
គ្រាប់បែកពីកងទ័ពសហរដ្ឋអាមេរិក ដែលថាមានការខូចខាតមហិមាដល់
កងទ័ពកុម្មុយនីស្ដ។ អ្នកសង្កេតការបរទេសខ្លះនិយាយថាដោយការទម្លាក់
គ្រាប់បែកសម្លាប់រង្គាលនេះហើយបានជាមានការមិនយោគយល់ សាហាវ
ដល់ប្រជាជនក្នុងក្រុងពេលដែលមេកងពលកុម្មុយនីស្ដវាយចូលយកបាន។

## ឆ្នាំ១៩៧៤: ការធ្លាក់ដំបន់ ឧដុង

មកដល់ដើមឆ្នាំ១៩៧៩ គណៈបក្សនយោបាយប្រឆាំងបានស្ងប់ស្ងាត់
ហើយគណៈបក្សលន់ណុល សង្គមសាធារណៈ ដើរតែម្នាក់ឯងគត់។
ស្ថានការណ៏កងទ័ពយោធាវិញ មានការចុះខ្សោយជានិច្ច កងទ័ពកុម្មុយនីស្ដ
មកដល់ជិតៗភ្នំពេញអាចបាញ់គ្រាប់ផ្លោងមកដល់ រួចហើយវាយយកបាន
ក្រុងឧដុង ដែលជាអតីតរាជវាំងជំនាន់បូរាណ នៅខែមិនា: ជំលៀសប្រជា
ជនចេញ បាញ់សម្លាប់អ្នករដ្ឋការ និង គ្រូបង្រៀន ដុតចោល ទីក្រុងសឹង
តែទាំងមូល។ មានការជឿនលឿនបន្តិចក្រោយមកក្នុងឆ្នាំនេះ កងទ័ព

**FANK** វាយយកបានក្រុង ឧដុង វិញ បើកផ្លូវផ្តល់ឲ្យមាន សន្តិសុខ ឲ្យមានជំនួយហូរទៅវិញទៅមកដល់ បឹងទន្លេសាប។

***<u>ការបញ្ចប់របស់ របប សាធារណ:</u>***

ថ្វីបើមានរឿងដូចនេះក៏ដោយ របបសាធារណៈខ្មែរមិនអាចរស់លើស ការវាយលុកលុយរដូវប្រាំងឆ្នាំ១៩៧៥។ កងទ័ពកុម្មុយនីស្តបានឡោមព័ទ្ធ រដ្ឋធានីភ្នំពេញៗដែលមានប្រជាជនកើនឡើងជាលំដាប់ ប្រជាជនភាសខ្លួន អំពីសង្រ្គាមរត់ចូលមក។ លន់ណុលជឿមន្តអាគមណាស់ បញ្ជាឲ្យ កប៉ាល់ហោះឧទ្ធភាគចក្រ ហោះបាចខ្សាច់មានសូត្រធម៏អាបឺ កុំឲ្យសត្រូវ ចូលបាន។ កងទ័ពសាធារណៈមកដល់ពេលនេះ វាយតស៊ូសំបើមណាស់ កងទ័ពកុម្មុយនីស្តផ្ទុយទៅវិញនឿយហត់ ធ្លាក់ទឹកចិត្ត ភាគច្រើនកើត ជម្ងឺគ្រុនចាញ់ ហើយមានការខូចខាតច្រើនជាងកងទ័ពសាធារណៈ។ ប៉ុន្តែអាវុធថ្មីៗ គ្រាប់សម្ភារៈថ្មីៗទើបតែយកចូលមកពីប្រទេសចិនតាម យួនខាងជើង ផ្លូវហូរជីមិញ ធ្វើឲ្យកងទ័ពកុម្មុយនីស្តមានកម្លាំងវាយឲ្យឈ្នះ អស់ប៉ុស្តិ៍ខ្មែរដែលនៅសែសសល់ប៉ុន្មាន។ មានការស្នើឲ្យមានការចរចារ ជាថ្មីប៉ុន្តែសម្តេចស៊ីហនុប្រកែកមិនចរចារជាមួយលន់ណុល ហើយស្នើរថា ចរចារបានលុះត្រាដកលន់ណុលចេញ។ មានគំរោងការណ៏១រៀបចំឡើង ដោយលោករដ្ឋទូតប្រទេសបារាំងប្រចាំប្រទេសចិន អេដែនម៉ាណាច្ហ **<u>Étienne Manac'h</u>** ថានិងឈប់បាញ់គ្នា ឲ្យសម្តេចនរោត្តមស៊ីហនុ ត្រឡប់ចូលមកដឹកនាំប្រទេសវិញ ដែលមានរដ្ឋាភិបាលរួម ប៉ុន្តែការស្នើ នេះមិនបានសំរេច (ដោយសារកងទ័ពខ្មែរក្រហមមិនព្រមព្រោះភាគច្រើន សុទ្ធតែអ្នកស្រែចំការ)។

នៅថ្ងៃទី១ខែមេសាឆ្នាំ១៩៧៥ លន់ណុល លាលែង រត់ចោលប្រទេស ទៅនិរទេសខ្លួននៅសហរដ្ឋអាមេរិករដ្ឋកោះហាវ៉ៃ ពេលនោះកងទ័ព **FANK** សឹងតែត្រូវរលាយ១រំពេច។ ពេលជាមួយគ្នា សិរិម៉ាតាក់ ឡុងបូរ៉េត និង លន់ណុន នៅក្នុងប្រទេសនៅឡើយសាកល្បងនិងចរចារការឈប់បាញ់គ្នានៅរដ្ឋធានីភ្នំពេញ។ កងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ពីរឬបីថ្ងៃក្រោយ ខ្មែរក្រហមធ្វើពិឃាតប្រហារជីវិតដល់អ្នកដឹកនាំរបបសាធារណៈដែលនៅរស់ទាំងប៉ុន្មាន។ ពេលនេះប្រទេសខ្មែរសាធារណៈបានមកដល់ជាការចប់ចុងក្រោយ។ នៅពេលដែលកើតឡើង ក្នុងរយៈពេល៦ឆ្នាំ គេបានទទួលអំណោយអំពីសរដ្ឋអាមេរិក ទាំងសេដ្ឋកិច្ច និង យោធា ១លានដុល្លាក្នុង១ថ្ងៃ។ ដំបន់ដែលកងទ័ពសែសសល់របស់ សាធារណៈនៅកាន់កាប់ គឺ ដំបន់ព្រះវិហារ **Preah Vihear Temple** ជិតភ្នំដងរែក **Dângrêk Mountains** ទល់ដែនជាមួយប្រទេសសៀម នៅចុងខែមេសា ឆ្នាំ១៩៧៥។ ចុងបញ្ចប់ដំបន់នេះ យកបានដោយកងទ័ពខ្មែរក្រហមថ្ងៃទី២២ខែឧសភា ឆ្នាំ១៩៧៥។

ពេលដែលឪពុកចូលបំរើកងទ័ព សាធារណៈរដ្ឋខ្មែរ **FANK** ពីឆ្នាំ ១៩៧០-១៩៧៥ (៦ឆ្នាំ): ពុកធ្វើការនៅទីលានចំបាំងខាងក្រៅអស់រយៈ៣ឆ្នាំ -១ឆ្នាំត្រូវបញ្ជូនទៅរៀនយុទ្ធសាស្ត្រនៅសាលានាយទាហាន និង កងទ័ពសហរដ្ឋអាមេរិកពិសេសមួកបៃតង -២ឆ្នាំធ្វើគ្រាប់និងគ្រាប់បែក និងចែកចាយគ្រាប់ទៅកងទ័ពនៅទីចំបាំងនានា។ រួចហើយនៅឆ្នាំ១៩៧៣ ត្រូវក្រសួងទាញឲ្យមកធ្វើការនៅប៉ុយរ៉ូ (សំណាងល្អគេចាប់យកឈ្មោះពីលើ អ្នកដែលបានប្រឡងចេញអំពីសាលានាយទាហានលេខខ្ពស់ ពុកបានលេខ៣ ក្នុងចំណោមនិស្សិត២៨៥នាក់) នៅក្រសួងការពារជាតិអស់រយៈពេល៣ឆ្នាំ មុននិងប្រឡងជាប់ទៅរៀននៅសាលាទាហានបច្ចេកទេស

នៅសហរដ្ឋអាមេរិកអាប៉ែរឌីនប្រូវិងគ្រោន រដ្ឋ ម៉េរីលែន ខែមិនាឆ្នាំ១៩៧៥ (រៀនជួសជុលរទេះតង់)។ ១ខែគត់មុននិងសាធារណៈធ្លាក់ទៅក្នុង កណ្ដាប់ដៃខ្មែរក្រហម។ នៅពេលដែលរៀនចប់ សាលាយោធាបច្ចេកទេស សហរដ្ឋមានសំនួរ៣ឲ្យពុកៈ ១-ត្រឡប់ទៅប្រទេសខ្មែរវិញ គេមិនធានា សេចក្ដីសុខដល់ជីវិត (មាននាយទាហាននិងទាហានខ្មែរជំនាន់ នោះដែល មករៀននៅសហរដ្ឋគ្រប់រដ្ឋនានា ១១០នាក់សុខចិត្តត្រឡប់ទៅវិញ អ្នក ទាំងអស់ត្រូវខ្មែរក្រហមសម្លាប់អស់នៅអាកាសយានដ្ឋាន ពោធិ៍ចិនតុង បើតាមពាក្យចាមអារ៉ាម) ២-ចូលជាទាហានសហរដ្ឋប៉ុន្តែឋានន្តរស័ក្ដ និងត្រូវចុះ ពីព្រោះសហរដ្ឋតម្រូវឲ្យមានសញ្ញាប័ត្រពីមហាវិទ្យាល័យ ហាត់រៀនបានធ្វើជានាយទាហានបាន ៣-ចេញពីទាហានធ្វើជាជនស៊ីវិល ដែលមានធ្វើឲ្យកាតបៃតងឲ្យរស់នៅបាន។ ពុករើសខទី៣ រកផ្ទះនៅ ការធ្វើ ទៅសាលាមហាវិទ្យាល័យភ្លាមៗនៅខែកញ្ញា រដូវរំហើយ ឆ្នាំ១៩៧៥ រៀនចប់នៅឆ្នាំ១៩៧៩។ តាំងពីនោះអ្វីៗជាសាវតារមកដល់ពេលនេះ (រស់រានមានជីវិត រស់នៅសហរដ្ឋតាំងពីពេលនោះមក)។

# ជំពូក ទី៧
# ប្រទេសខ្មែរឆ្នាំ១៩៧៥-១៩៧៩(ជំនាន់ខ្មែរក្រហម)

**នៅឆ្នាំ១៩៧៥** កងទ័ពខ្មែរក្រហមយកភ្នំពេញបាន ក្រោយបន្តិចនេះកងទ័ពយួនខាងជើងក៏យកយួនខាងត្បូងបានដែរ។

ខ្មែរក្រហមមានសេចក្តីស្អប់ខ្ពើមខ្មែរអ្នកនៅទីក្រុង បង្ខំឲ្យចាកចេញសំដៅស្រុកស្រែ ហើយបង្ខំឲ្យធ្វើការជាអ្នកស្រែចំការកសិកម្ម។ អ្នកដឹកនាំមានឈ្មោះថា សាឡុតស ដែលគេស្គាល់ជា ប៉ុលពត។ ខ្មែរក្រហមបង្កើតរដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ **<u>Democratic Kampochea (DK)</u>** ដែលមានមេកងជាខ្មែរអ្នកស្រែ គ្មានចំណេះវិជ្ជា ប៉ុន្តែបានធ្វើចំបាំងជាមួយខ្មែរក្រហម។

ការចំអក និង ការប្រកាន់ទោសចំពោះអ្នកធ្លាប់នៅទីក្រុង មានប្រសើរជាងនៅពេលដើម ចំពោះអ្នកបញ្ញាវន្ត អ្នកប្រកាន់សាសនា និងអ្នកដែលគេជឿថាប្រឆាំងនិងរបប ប៉ុន្តែចំពោះខ្មែរក្រហម ការដាក់ទណ្ឌកម្មគឺ ពិឃាតចោល។ នៅក្នុងរបបខ្មែរក្រហម ប៉ុលពត ប្រជាជនខ្មែរ ២០% ត្រូវគេប្រហារធ្វើឃាត។

នៅឆ្នាំ១៩៧៩ ប្រទេសយួន វាយលុកប្រទេសខ្មែរ របបខ្មែរក្រហមដោយប្រើទាហាន ១០០,០០០ នាក់។ កងទ័ពយួនត្រូវនាំចូលដោយពួកខ្មែរក្បត់ (ខ្មែរហ៊ុនសែន) ពីក្រោយខ្នង ចូលមកដល់ភ្នំពេញដែលពេលនោះត្រូវរត់បោះបង់ចោលដោយទ័ពខ្មែរក្រហមពី១ថ្ងៃមុន។

កងទ័ពខ្មែរក្រហម ដែលមាន ប៉ុលពតផងដែររត់ទៅចូលដីសៀមដែលមានសេចក្ដីអនុញ្ញាត្តិអំពីសៀមឲ្យជ្រកកោន ពីព្រោះសៀមមិនត្រូវរ៉ូវនិងយួន។

កងទ័ពយួនបង្កើតរបបថ្មីនៅប្រទេសខ្មែរដែលមាន ហ៊ុនសែននិងបក្សពួកនិងសមាជិកខ្មែរក្រហមដែលមិនរត់ និងខ្មែរដែលរត់ចេញពីរបបខ្មែរក្រហម ទៅស្រុកយួនមុនឆ្នាំ១៩៧៥។ ជាបន្ទាន់ដែរខ្មែរក្រហមនិងកងទ័ពបង្កើត រដ្ឋាភិបាលក្រៅស្រុកដែលតតាំងនិងយួនឲ្យឈ្មោះថាកម្ពុជាប្រជាធិតេយ្យដែរ។

អង្គការសហប្រជាជាតិទទួលស្គាល់រដ្ឋាភិបាលខ្មែរក្រហមក្រៅស្រុកនេះដែលមានប្រទេស សហរដ្ឋអាមេរិក ចិន និង ថៃ ចូលផងដែរ។ ដោយមានជម្លោះជាថ្មីរវាងរដ្ឋាភិបាលទាំង២ មានប្រជាជនខ្មែរ ៥00,000នាក់ជាជនភៀសខ្លួន ហើយត្រូវទៅរស់នៅៗប្រទេសដ៏ទៃៗផ្សេង។

ខ្មែរក្រហម (ជាបារាំងៈខ្មែររូហ្ស *Khmer Rouge*; ជាអង់គ្លេសៈ រិដខ្មែរ *Red Khmers*) គឺជាឈ្មោះដែលគេដាក់ឲ្យទៅអ្នកដែលចូលគណៈបក្សកុម្មុយនិស្ត។ គណៈបក្សនេះកើតឡើងនៅឆ្នាំ១៩៦៨ ដែលលេចជាពន្លកមកពី កងទ័ពប្រជាជនយួន មកពីប្រទេសយួនខាងជើង។ របបខ្មែរក្រហមដែលមាន អ្នកដឹកនាំ ប៉ុលពត នួនជា អៀងសារី សុនសែន និង ខៀវសំផនកាន់កាប់ប្រទេសខ្មែរពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ប្រទេសខ្មែរបានដូរឈ្មោះ ទៅ កម្ពុជាប្រជាធិតេយ្យ **Democratic Kampuchea (DK)** ។



**ប៉ុលពត (មេដឹកនាំ ខ្មែរក្រហម ឆ្នាំ ១៩៧៥-១៩៧៩)**

អង្គការរបបខ្មែរក្រហមត្រូវគេចងចាំថា ជារបបសម្លាប់រង្គាលដល់មហាជនខ្មែរ ដែលជាលទ្ធផលមកពីគោលនយោបាយដឹកនាំបង្ខំសហករណ៏ក្នុងសង្គម។ គេចាប់ផ្ដើមរបបយកកសិកម្មជាធំ ជួយខ្លួនឯងជាដាច់ខាត ប៉ុន្តែបណ្ដាលឲ្យប្រជាជនអត់អាហារស្លាប់រង្គាល គេយកជំនួយជួយខ្លួនឯង ផ្ដត់ផ្ដង់ថ្នាំសង្កូវ ប៉ុន្តែបណ្ដាលឲ្យរាស្ត្រស្លាប់រាប់រយពាន់និងជម្ងឺគ្រុនចាញ់។ ការសម្លាប់តាមចិត្ត និងទារុណកម្មដល់ស្លាប់របស់មេកងចំពោះអ្នកដែលសង្ស័យប្រឆាំង ឬ កំចាត់ចោលអ្នកដែលមានថានន្តរស័ក្តដូចគ្នា ពីឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៨ ចាត់ទុកការសម្លាប់រង្គាលរបស់របបនេះ។ មកដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវរត់ចោលស្រុក ហើយរបបថ្មីសាធារណៈប្រជាជនកម្ពុជា **People's Republic of Kampuchea** ចាប់បង្កើតឡើង។ ពេលនោះរដ្ឋាភិបាលក្រៅប្រទេស (ដែលមានខ្មែរក្រហមរាប់បញ្ចូល) នៅមានរក្សាកៅអីនៅអង្គការសហប្រជាជាតិ ប៉ុន្តែត្រូវបាត់កៅអីនេះទៅវិញនៅឆ្នាំ១៩៩៣ ពេលដែល រាជាណាចក្រ

បានលើកដំកល់ឡើងវិញនៅប្រទេសខ្មែរ។ ១ឆ្នាំក្រោយមក ឆ្នាំ១៩៩៤ កងទ័ពឧទ្ទាមរបស់ខ្មែរក្រហមរាប់ពាន់នាក់ មកចុះចូលជាមួយកងទ័ពរដ្ឋាភិបាលថ្មី ក្នុងពីធីប្រណីលើកលែងទោស។ នៅឆ្នាំ១៩៩៦ មានគណៈបក្ស ប្រជាធិបតេយ្យជាតិចលនារួម **Democratic National Union Movement** បង្កើតឡើងដោយ អៀងសារី ដែលត្រូវបានប្រណីលើកលែងទោសពីសមាជិកចាស់ខ្មែរក្រហម។ ប៉ុន្តែគណៈបក្សនេះត្រូវរំលាយ ខ្លួនឯងជាផ្លូវការ នៅឆ្នាំ១៩៩៩។

## *គោលនយោបាយ ជាប្រវត្តិសាស្ត្រ*

ក្រោយពីបានកាន់កាប់អំណាច ខ្មែរក្រហម ដូរឈ្មោះប្រទេស ទៅប្រជាធិតេយ្យកម្ពុជា។ ខ្មែរក្រហមដាក់ប្រទេសខ្មែរនៅក្រោមការកែរទម្រង់សង្គមយ៉ាងខ្លាំងបំផុត បង្កើតការសំអាតបរិសុទ្ធសង្គមកុម្មុយនីស្ត១ ដែលយកកសិកម្មជាជំហរ ហើយម្នាក់ៗមានចំណែកស្មើគ្នា។ ខ្មែរក្រហមបង្ខំឲ្យប្រជាជន ២លាននាក់ ចេញពីក្រុងទៅស្រុកស្រែ ចាប់ផ្តើមធ្វើកសិកម្ម។ គេបង្ខំឲ្យមនុស្សចាកចេញពីផ្ទះសម្បែង មិនគិតដល់សុខទុក្ខសេរីភាពរបស់មនុស្សធម៌ គេត្រួតត្រាមនុស្សឲ្យចេះបំពេញមុខងារចេះស្លៀកពាក់តាម ឲ្យចេះនិយាយទៅតាមគេ និងត្រួតត្រាគ្រប់មុខនៃការរស់នៅទាំងមូល។ នៅកំឡុងពេល១-២ឆ្នាំ ខ្មែរក្រហមសម្លាប់អស់ពួកអ្នកបញ្ញាវន្ត អ្នកដែលធ្លាប់រស់នៅតែទីក្រុង អ្នកដែលមានជាតិជាភាគតិច ហើយសម្លាប់មិត្តជិតដិតវាទាំងមេទាំងកូនទាហានដែរបើមានសង្ស័យថាក្បត់និងវា។

ខ្មែរក្រហមចង់បំបាត់អ្នកណាដែលសង្ស័យធ្វើ ជំនួញលក់ដូរ មានគំនិតជាមូលធននិយម អ្នកណាដែលមានការអប់រំ អ្នកណាដែលជាអ្នកទីក្រុង និងអ្នកណាដែលមានការទាក់ទងជា១បរទេស។

ខ្មែរក្រហមជឿថាឪពុក-ម្តាយមានខួរក្បាលប្រឡាក់ប្រឡូសនិងមូលធននិយម ដូច្នេះគេដកហូតកូនៗពីឪពុក-ម្តាយ បញ្ចុះបញ្ចូលមនោគមវិជ្ជាកុម្មុយនីស្ត ហើយបង្រៀនឲ្យចេះធ្វើទារុណកម្មយកសត្វជាឧទាហរណ៏។ យកក្មេងៗប្រើជា "ឈ្លាន់ និងឲ្យមានអំណាចផ្តាច់ការពីគណៈបក្ស" ឲ្យមានអំណាច និង ដឹកនាំជាមេកោយ ឲ្យមានអំណាចធ្វើទារុណកម្ម ឬ ពិឃាត ដល់មនុស្សចាស់ៗ។



**ទង់ជ័យជាតិ របស់ ប្រជាធិបតេយ្យកម្ពុជា**

ម៉ាស៊ីន១ធំពីក្រោយ ពេលនិយាយដល់អ្នកដែលទើបនិងមកដល់ (ជាពិសេសមនុស្សអ្នកក្រុង) ថាៈ "ទុកឲ្យហ្អែងរស់គ្មានចំណេញ សម្លាប់ហ្អែងចោលគ្មានខាតអ្វី"។ ទស្សនៈវិជ្ជារបស់ខ្មែរក្រហម កើតកើនឡើងជាយូរមកដែរ។ វាចាប់ផ្តើមកើតពេលដែលគណៈបក្សកុម្មុយនីស្តនៅធ្វើការជាមួយគ្នា រាវរកទិសដៅដឹកនាំ រង់ចាំលទ្ធផល អំពីកងវាយឈ្លបរបស់យួនខាងជើងដែលរវល់ធ្វើចំបាំង ផ្ទៃក្នុងរបស់គេដែរ។

ប៉ុលពតជាមេដឹកនាំសំខាន់ ក្នុងចលនាកុម្មុយនីស្តពេលត្រឡប់មកពីស្រុកបារាំងមកដល់ប្រទេសខ្មែរវិញ។ ប៉ុលពតបានចូលជាសមាជិក គណៈបក្សកុម្មុយនីស្តបារាំង **the French Communist Party (PCF)** ដែលផ្តល់គំនិតបង្កើត របបខ្មែរក្រហម។ ចលនាកុម្មុយនីស្តចាប់ផ្តើមមានកម្លាំងឋាមពលនៅក្នុងព្រៃទិសខាងជើង-ខាងកើត (ឥសាន្ត) របស់ប្រទេសពេលដែលសម្តេចត្រូវគេដកចេញពីមុខដំណែងប្រមុខរដ្ឋឆ្នាំ១៩៧០។ អតីតអម្ចាស់ចង់យកខ្មែរក្រហមជាអ្នកហែរហមពីក្រោយខ្នង។ ដោយមានសង្គ្រាមផ្ទៃក្នុងបំរុងនិងកើតឡើង ខ្មែរក្រហមដាក់ខ្លួនជា "គណៈបក្សសំរាប់សន្តិភាព " បានឡើងប្រជាប្រិយ៍ និងកើនឡើងជាលំដាប់។

ក្រោយពីកាន់កាប់អំណាចអស់រយៈ៤ឆ្នាំ របបខ្មែរក្រហមត្រូវរំលំចេញនៅឆ្នាំ១៩៧៩ ដោយការលុកលុយនៃកងទ័ពយួន ហើយដាក់របបថ្មី (រដ្ឋាភិបាលតុក្កតា-ហ៊ុនសែន) ចូលជាកុម្មុយនីស្តយួនទាំងស្រុង។ ខ្មែរក្រហមបានរស់រានមានជីវិតនៅមកដល់ឆ្នាំ១៩៩០ឡើង ហើយជាចលនាក្រុមអ្នកតស៊ូ នៅ មូលដ្ឋានខាងលិចប្រទេស បញ្ជាការក្នុងទឹកដីប្រទេសថៃ។ នៅឆ្នាំ១៩៩៦ ក្រោយពីការពិភាក្សាយល់ព្រមព្រាងសន្តិភាព ប៉ុលពតជាមេដឹកនាំសុខចិត្តរំលាយអង្គការខ្មែរក្រហមចោល។ នៅថ្ងៃទី១៥ ខែមេសាឆ្នាំ១៩៩៨ ប៉ុពត ស្លាប់ ដោយមិនបានដាក់ចូលឲ្យឈមមុខតុលាការផងទេ។

## *គតិ មនោគមវិជ្ជា*

គតិ មនោគមវិជ្ជារបស់ខ្មែរក្រហមគឺស្ថិតនៅក្នុងមូលដ្ឋានខ្លាំងបំផុតជាខ្មែរស្នេហាជាតិ និង ខ្មែរដែលស្អប់បំផុតជនបរទេស។ មនោគមវិជ្ជានេះ

កើតមានដោយមានភស្តុតាងរាជាណាចក្រអង្គរ (ឆ្នាំ៨០២-១៤៣១) ដែលមានការខ្លាចជានិច្ចអំពីប្រទេសក្រៅ គឺយួនពីខាងកើត និងសៀមពីខាងលិចចាំលេបទឹកដីបំបាត់ពូជខ្មែរជានិច្ច។ មនោគមវិជ្ជានេះក៏បានឆ្លងអំពីការអប់រំពីអាណានិគមបារាំងដែលដាក់ខ្មែរ ជាឧបធារណ៏ "អារិយ្យ-ភាសាសំស្រ្កឹត- អ្នកមានវណ្ណៈខ្ពស់ចំណោមជនជាតិអាស៊ី "មានចំណេះ វិជ្ជាខ្ពស់ជាង ចិន និង យួន។ ការខ្វាតខ្វាត់ខ្វាយប្រជាជនយួនពីសង្រ្គាមនៅយួនចូលមករស់នៅលើទឹកដីខ្មែរធ្វើឲ្យមានគំនិតស្អប់ខ្ពើមយួន។ ខ្មែរក្រហមបង្ហាញគោលដៅយ៉ាងច្បាស់ ស្អប់ ចិន យួន និង កូតកាត់ខ្មែរទាំងឡាយចង់បំបាត់ពូជ។ សូម្បីតែជនជាតិ ចាមឥស្លាម ក៏មិនយោគយល់ដែរបង្ខំឲ្យបញ្ចូល "សាច់និងឈាម " រៀបការណ៏ឆ្លងពូជ និងចូលជាតិខ្មែរជាដើម។ មានអ្នកដឹកនាំខ្មែរក្រហមជាច្រើនដែលជាកូនកាត់ចិនឬកាត់យួន យកតម្រាប់ដូចនៅប្រទេសសហភាពសូវៀត ជនកូនកាត់ ឬមួយត្រូវពិឃាត ឬ មួយត្រូវចូលជាអ្នកដៃដល់កាប់សម្លាប់ជា១គេដែរ។ ថ្វីបើខ្មែរក្រហមមានចលនាបដិវត្តន៏ខាងឆ្វេង គេមានចាប់យកផ្លូវព្រះពុទ្ធអប់រំ មកដើរតាមដែរ។ ពេលដែលគណៈបក្សចំណាយពេលនៅក្នុងព្រៃឆ្នាំ១៩៦០ឡើង មានការស្រាវជ្រាវរកឃើញវិជ្ជាដោះស្រាយរឿងសង្គមប្រៀបបាននិងរឿងព្រេងដែលព្រះពុទ្ធបានត្រាស់ក្នុងព្រៃព្រឹក្សាដែរ។ មុននិងឡើងកាន់អំណាច ខ្មែរក្រហមមានប្រកាន់ របៀបពុទ្ធសាសនាដែលមាន "អ្នកមានអ្នកក្រនិងសង្គមអយុត្តិធម៏ " ហើយដែលជាឧប្បសគ្គក្នុងរបបរដ្ឋាភិបាលសម័យឥឡូវនេះ។ ជាជាងប្រើការចាត់ចែងការរដ្ឋបាលដោយប្រើឈ្មោះជាធំ និង អ្នកល្បីៗឈ្មោះ ខ្មែរក្រហមប្រើអំណាចដឹកនាំជាសង្គម ឲ្យមានអ្នកគោរព បូជាដូចពុទ្ធសាសនិកដើរតាមព្រះដែរ។

គោលនយោបាយសង្គមរបស់ខ្មែរក្រហមគឺ បង្កើតសង្គមថ្មី បរិសុទ្ធដែលមានកសិកម្មជាជំហរ និង វណ្ណៈស្មើគ្នា។ ប៉ុលពតខ្លួនឯងជាអ្នកមាន

អានុភាពលើការឃោសនានេះ។ គេនិយាយថា ប៉ុលពត សរសើរពួកខ្មែរលើ រស់នៅលើភ្នំ ដែលគណៈបក្សគេស្រមៃឃើញជាជីវភាពដំបូងរបស់ កុម្មុយនីស្តពិតៗ។ ពួកកុលសម្ព័ន្ធខ្មែរលើទាំងនេះត្រូវបានខ្មែរក្រហម រាប់រកល្អមិនធ្វើបាប ជាង អ្នកទីក្រុង "ថៅកែ "ចិន និង យួន។ ប៉ុលពត ចង់ដកហូតគ្រឹស្ថានសង្គមសម័យ ទៅជាសង្គមថ្មី បរិសុទ្ធ ដែលមានកសិកម្មជាជំហរ និង វណ្ណៈស្មើគ្នា។ ខ្មែរក្រហមនិយាយទៅកាន់អ្នកដឹកនាំប្រទេសចិននៅឆ្នាំ១៩៧៥ថា របៀបដែលគេធ្វើនេះ គឺ "បង្កើតសង្គមកុម្មុយនីស្តទាំងមូល បំភ្លេចជំហានដែលជាជណ្ដើរ កណ្ដាលដែលត្រូវដើរ – គឺផ្លូវកាត់ត្រង់ដល់ទី "។ ខ្មែរក្រហម គិតម្យ៉ាង ទៀតថា ការដែលជន្លាសប្រជាជនចេញពីទីក្រុងភាគច្រើន គឺជារការដែលចង់បំបាត់បំផ្លាញ ចិន យួន ដែលមិនមែនជាខ្មែរសុទ្ធ មិនចេះធ្វើស្រែចំការ ធ្លាប់តែដេកស៊ី។ ពួកនេះត្រូវគេបំបែកញែកគ្នាអំពីជំរុំអ្នកធ្វើការខ្មែរ មិនឲ្យនិយាយភាសាដើម មិនឲ្យកាន់សាសនា ក្រៅពីសាសនាខ្មែរ។

## *ឈ្មោះជា ប្រវត្តិសាស្ត្រ*

ឈ្មោះដែលហៅថា "ខ្មែររូហ្ស " ជាភាសាបារាំង ជាខ្មែរ "ខ្មែរក្រហម " បានដាក់ចំណងជើងឲ្យដោយសម្ដេចព្រះនរោត្តមស៊ីហនុជាប្រមុខរដ្ឋប្រទេសខ្មែរពេលនោះ ហើយដែលក្រោយៗមកសូម្បីអ្នកនិយាយភាសាអង់គ្លេសក៏យល់ពាក្យនេះដែរ។ ហើយគេក៏គួរស្គាល់ដែរ បើនិយាយអំពីឈ្មោះគណៈបក្សកុម្មុយនីស្តដែលមានឈ្មោះបន្តបន្ទាប់គ្នាមក ដូចជា គណៈបក្សកុម្មុយនីស្តនៅប្រទេសខ្មែរ **Communist parties in Cambodia** រួចហើយដូរទៅ គណៈបក្សកុម្មុយនីស្តកម្ពុជា

**the Communist Party of Kampuchea (CPK)** ហើយក្រោយមក ហៅថា គណៈបក្សប្រជាធិបតេយ្យកម្ពុជា **the Party of Democratic Kampuchea**។ អង្គការដដែលនេះក៏មានឈ្មោះ ជា គណៈបក្សកុម្មុយនីស្តខ្មែរ **the Khmer Communist Party** រួចហើយជា កងទ័ពជាតិប្រជាធិបតេយ្យកម្ពុជា **the National Army of Democratic Kampuchea** ។

***សម្តេចបង្កើតរាជរដ្ឋាភិបាលក្រៅប្រទេសហៅថា GRUNK (Gouvernement Royal d'Union Nationale du Kampuchéa)***

ការធ្វើនយោបាយចេញមុខរបស់ខ្មែរក្រហម បានឡើងកើនយ៉ាងឆាប់រហ័ស ដោយការទម្លាក់សម្តេចនរោត្តមសីហនុអំពីប្រមុខរដ្ឋនៅឆ្នាំ១៩៧០ ពីព្រោះពលរដ្ឋរត់ចូលព្រៃតាមសម្តេច។ នាយក រដ្ឋមន្ត្រី លន់ណុល ដែលមានការគាំទ្រអំពី រដ្ឋសភា ទម្លាក់សម្តេចសីហនុ។ សម្តេចសីហនុ និរទេសព្រះអង្គទៅ ប៉ីជីង ប្រទេសចិន យកខ្មែរក្រហមជា អ្នកហែរហម ប្រកាសបង្កើតរាជរដ្ឋាភិបាលក្រៅប្រទេស ហៅថា រាជរដ្ឋាភិបាលបង្រួមជាតិកម្ពុជា ជាភាសាបារាំង **GRUNK (Gouvernement Royal d'Union Nationale du Kampuchéa)** គាំទ្រ ដោយប្រទេសសាធារណៈចិនប្រជាមានិត។ រដ្ឋាភិបាលសហរដ្ឋអាមេរិក របស់ប្រធានាធិបតី និចសុនថ្វីបើដឹងកម្លាំងខ្សោយរបស់កងទ័ព លន់ណុល គាំទ្រសាធារណៈខ្មែរ ដោយប្រើផ្លូវអាកាសជួយទម្លាក់ គ្រាប់បែកពីលើ។

ក្រោយអំពីសម្តេចសីហនុប្រកាសចូលខ្មែរក្រហម កងទ័ពខ្មែរក្រហម ដែលមាន ៦,០០០នាក់ កើនឡើងទៅដល់ ៥០,០០០នាក់ ពេលនោះ

សម្តេចបានទៅសម្ពោធនឹងដល់ទីលានប្រយុទ្ធ។ មានអ្នកប្រយុទ្ធជាច្រើនមហិមា (៨៩,០០០នាក់) ចង់ធ្វើចំបាំងឲ្យសម្តេច មិនទាំងយល់ផងទេអ្វីដែលហៅកុម្មុយនីស្ត។

សម្តេចស៊ីហនុប្រជាប្រិយ៏មានច្រើនរហូតដល់ឆ្នាំ១៩៧៣ ដែលខ្មែរក្រហមប្រកាសថាគេមានកាន់ទឹកដីច្រើនជាង ប៉ុន្តែមានប្រជារាស្ត្រតិចជាងសាធារណៈ។ ប្រជាជនភាគច្រើនដែលជួយខ្មែរក្រហមប្រឆាំងនិងលន់ណុល នឹកថាបើចំបាំង ឈ្នះគេនិងដាក់សម្តេចឲ្យធ្វើជាប្រមុខរដ្ឋវិញ។

មកដល់ឆ្នាំ១៩៧៥ រដ្ឋាភិបាលលន់ណុល អស់គ្រាប់បាញ់សត្រូវ គឺជាការច្បាស់ណាស់ដែលប្រទេសសាធារណៈនិងធ្លាក់ចុះ។ នៅថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលកាន់កាប់ភ្នំពេញ។

## ***ការចូលទាក់ទិន របស់ បរទេស***

ការទំនាក់ទំនង រវាងការទម្លាក់គ្រាប់បែកដ៏សំបើមនៅប្រទេសខ្មែរ និងការជឿនលឿនកើនឡើងយ៉ាងរហ័សរបស់កងទ័ពខ្មែរក្រហម ជាប្រធានដែលអ្នកសិក្សាប្រវត្តិសាស្ត្រចង់រកឲ្យឃើញឫសគល់។ អ្នកប្រវត្តិសាស្ត្រ ខ្លះមានយោបល់ថាការចូលប្រឡូកដៃរបស់សហរដ្ឋអាមេរិក និងការទម្លាក់គ្រាប់បែកដ៏សំបើមនៅជនបទ (ពីឆ្នាំ១៩៦៥-១៩៧៣) ធ្វើឲ្យប្រជារាស្ត្រខ្មែរស្អប់ខ្ពើមរបបសាធារណៈរត់ចូលខ្មែរក្រហម។ ផ្ទុយទៅវិញ ដេវីដឆែនលើរ អ្នកសរសេរជីវប្រវត្តិរបស់ ប៉ុលពត តវ៉ាថា ការទម្លាក់គ្រាប់បែកមាន "ផ្តល់លទ្ធផលដែលសហរដ្ឋអាមេរិកចង់ធ្វើ - គឺបញ្ឈប់ខ្មែរក្រហមមិនឲ្យឡោមព័ទ្ធភ្នំពេញ " ប៉ុន្តែមានលទ្ធផលអាក្រក់១ គឺមានប្រជារាស្ត្រាប់ពាន់ត្រូវស្លាប់។ ពីធើរ រ៉ដមែន និង ម៉ាយកិល លិន្ត

អះអាងថា ជំនួយសហរដ្ឋគឺបញ្ឈប់ខ្មែរសាធារណៈកុំឲ្យក្រឡាប់នៅឆ្នាំ១៩៧០ និង ឆ្នាំ១៩៧៣។ ក្រេក អិតឆេសុន យល់ព្រមថា ការជ្រលក់ដៃរបស់សហរដ្ឋមិនអាចធ្វើឲ្យខ្មែរក្រហមជោគជ័យទេ តែធ្វើឲ្យការជ្រើសរើសទាហានស្រួលមិនបាច់ឃោសនាច្រើនដល់ខ្មែរក្រហម។ ផ្ទុយទៅវិញ វីលីយ៉ាំ ស្វក្រស្ស សរសេរថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋ និង ការកើនទ័ពលើដីក្នុងប្រទេស ជាការរីករវរ និង ជាហេតុដែលសម្តេចនរោត្តមសីហនុជាសវាំងមិនឲ្យកើតមានលើប្រទេសព្រះអង្គអស់រយៈជាច្រើនឆ្នាំ។

ស្វក្រស្ស មានសរសេរផងដែរថា កងទ័ពខ្មែរក្រហមបានសុំអន្តរាគមន៍អំពីទ័ពយួនឲ្យជួយ ដែលចុងបញ្ចប់ធ្វើឲ្យមានជ័យជំនះ។ ហើយយួនក៏និយាយនៅពេលក្រោយដែរថា បានចូលធ្វើជាអ្នកលេងសំខាន់ក្នុងជ័យជំនះខ្មែរក្រហម។

ប្រទេសចិន ដាក់អាវុធលើដៃខ្មែកុម្មុយនីស្ត បង្ហាត់បង្រៀនខ្មែរក្រហម ហើយថ្ងៃក្រោយក៏នៅតែជួយជាជំនួយច្រើន ឆ្នាំដល់ខ្មែរក្រហម។

អង្គការសហប្រជាជាតិបានសំរេចសេចក្តី គាំទ្ររបប ខ្មែរក្រហមរដ្ឋាភិបាលក្រៅប្រទេស ហៅថារដ្ឋាភិបាលចំរុះប្រជាធិបតេយ្យកម្ពុជា **CGDK** **(the Coalition Government of Democratic Kampuchea)** ប្រឆាំងនិងប្រទេសយួនដែលដេញខ្មែរក្រហមចេញ ហើយដាក់តាំងរដ្ឋាភិបាលតុក្កតា ហ៊ុនសែន។

## ***របបខ្មែរក្រហម***

**<u>អ្នកដឹកនាំ</u>**

មេអ្នកដឹកនាំខ្មែរក្រហមភាគច្រើនមិនដូរសោះតាំងពីឆ្នាំ១៩៦០ឡើង ដល់ពាក់កណ្ដាលឆ្នាំ១៩៩០ឡើង។ អ្នកដឹកនាំជាច្រើនកើតចេញអំពីគ្រួសារអ្នកមានធុនកណ្ដាល បានរៀនសូត្រនៅបរទេសមហាវិទ្យាល័យប្រទេសបារាំង។

គណៈកម្មការកណ្ដាលរបស់របបខ្មែរក្រហមពេលកាន់កាប់អំណាចនៅប្រទេសខ្មែរមានដូចតទៅ:

- ប៉ុលពត **<u>Pol Pot</u>** (ឬសាឡុតស **Saloth Sar**) (ស្លាប់ឆ្នាំ១៩៩៨), "មិត្តទី១" អគ្គលេខាធិការទូរទៅ ពីឆ្នាំ១៩៦៣ដល់ថ្ងៃស្លាប់ជាមេដឹកនាំចលនា។
- នួនជា **<u>Nuon Chea</u>** (ឬឡុងប៊ុនរត់ **Long Bunruot**), "មិត្តទី២" នាយករដ្ឋមន្ត្រី ចាប់បានឆ្នាំ២០០៧ កាន់អំណាចខ្ពស់ អ្នកដៃស្ដាំរបស់ប៉ុលពត។
- អៀងសារី **<u>Ieng Sary</u>** (ប្អូនថ្លៃរបស់ប៉ុលពត) (ស្លាប់នៅមន្ទីរឃុំឃាំងរង់ចាំតុលាការកាត់សេចក្ដី បទចោទសម្លាប់ផុតពូជ នៅថ្ងៃ១៤ខែមិនាឆ្នាំ២០១៣), "មិត្តទី៣" អនុនាយករដ្ឋមន្ត្រី ចាប់បានឆ្នាំ ២០០៧។
- តាម៉ុក **<u>Ta Mok</u>** (ឬឈិតឈឿន **Chhit Chhoeun**) (ស្លាប់ថ្ងៃទី២១ខែកក្កដាឆ្នាំ២០០៦), "មិត្តទី៥" លេខាធិការដំបន់ទិសនារតី ស្លាប់នៅមន្ទីរឃុំឃាំងរង់ចាំតុលាការកាត់សេចក្ដីបទចោទសម្លាប់ ផុតពូជ។

- ខៀវសំផន Khieu Samphan "មិត្តទី៤" ប្រធានាធិបតីប្រជាធិបតេយ្យកម្ពុជា ចាប់បានឆ្នាំ ២០០៧។
- សុនសេន Son Sen (ស្លាប់ឆ្នាំ១៩៩៧) រដ្ឋមន្ត្រីក្រសួងការពារជាតិ ចៅហ្វាយរបស់ កាំងកេកអៀវ Kang Kek Iew ត្រូវបញ្ជាឲ្យធ្វើឃាតដោយប៉ុលពតដោយសារក្បត់។
- យន់យ៉ាត Yun Yat (ស្លាប់នៅឆ្នាំ១៩៩៧)
- កែប៉ុក Ke Pauk (ស្លាប់ឆ្នាំ២០០២) "មិត្តទី១៣" អតីតលេខាធិការដំបន់ទិសឧត្តរ។
- អៀងធី រិទ្ធ Ieng Thirith ចាប់បានឆ្នាំ២០០៧ ជាប្អូនស្រីថ្លៃរបស់ប៉ុលពត ជាភរិយារបស់អៀងសារី។

## ជីវិតរស់នៅក្រោមអំណាចខ្មែរក្រហម

នៅក្នុងអំណាច ខ្មែរក្រហមបញ្ជាឲ្យប្រទេសចេញឆ្ងាយបំផុតអំពីឥទ្ធិពលបរទេស ចាប់បិទសាលា បិទមន្ទីរពេទ្យ បិទរោងចក្រ បិទធនាគារ បិទជំនួញ បំបាត់ប្រាក់ចាយវាយ ប្រកាសថាខុសច្បាប់ដល់សាសនាទាំងអស់ ចាប់រឹបយកទ្រព្យសម្បត្តិទាំងឡាយ ផ្ទេរទីលំនៅប្រជាជនពី ទីក្រុងទៅ សហករណ៍កសិកម្មស្រុកស្រែ បង្ខំមនុស្សឲ្យធ្វើការឥតប្រណី។ គោលបំណងនយោបាយទាំងនេះ គឺចង់ផ្លូវប្រជាជនខ្មែរទៅជា "មនុស្សដើម "ដោយយកកសិកម្មពលកម្មជាគោល។

នៅភ្នំពេញនិងទីក្រុងឯទៀត ខ្មែរក្រហមប្រាប់មនុស្សថា គេនិងចាកចោលផ្ទះតែ "២ឬ៣គីឡូម៉ែត្រទេ "ទៅក្រៅទីក្រុងតែ "២ឬ៣ថ្ងៃ " និងត្រឡប់មកវិញ។ មានប្រជាជនខ្លះត្រូវខ្មែរក្រហមប្រាប់ឲ្យចេញភ្លាមៗ

"ទ័ពអាមេរិកាំងនិងទម្លាក់គ្រាប់បែក" មិនបាច់ចាក់សោរផ្ទះសម្បែងទេ កងទ័ពខ្មែរក្រហមនិងថែរក្សាឲ្យ លុះដល់ថ្ងៃត្រឡប់មកវិញ។ មនុស្សណាដែលប្រកែកមិនទៅ ផ្ទះអ្នកនោះត្រូវដុតចោល ហើយត្រូវគេធ្វើឃាតភ្លាមៗ។ ជនដែលគេជន្លៀសចេញ ដើរតម្រង់ទៅស្រុកស្រែ កូនក្មេងៗរាប់ពាន់ត្រូវស្លាប់តាមផ្លូវ មនុស្សចាស់ជរា មនុស្សឈឺថ្កាត់ត្រូវបាត់បង់ជីវិត។

ខ្មែរក្រហមបំរុងនិងដូរសង្គមខ្មែរទៅជាសង្គមគ្មានវណ្ណៈ បណ្តេញប្រជាជនចេញពីទីក្រុង ("មនុស្សថ្មី") បង្ខំឲ្យចូលរស់នៅជាអង្គការណ៏សហករណ៏កសិកម្ម។ ប្រជាពលរដ្ឋខ្មែរទាំងមូល ត្រូវបង្ខំឲ្យធ្វើការស្រែចំការ។ ប្រជារាស្ត្រតម្រូវឲ្យធ្វើផលឲ្យបាន ៣តោនក្នុង១ហិកតារដី។ តាំងពីជំនាន់ដើមមុនខ្មែរក្រហមប្រជារាស្ត្រខ្មែរធ្វើបានតែ ១តោនក្នុង ១ហិតារដី។ ការដែលគ្មានចំណេះនិងធ្វើស្រែចំការ ចំពោះមនុស្សធ្លាប់នៅទីក្រុង ធ្វើឲ្យមានការអត់ឃ្លាន ទុរ្ភិក្ស ជាសមិនផុត។ អ្នកដែលធ្លាប់នៅស្រែចំការគ្មានចិត្តនិងជួយ អ្នកទីក្រុង ឬមួយក៏ខ្លាចក្រែងខ្មែរក្រហមធ្វើបាបភាគច្រើនធ្វើមិនដឹងមិនឮ។ ការចេះបេះផ្លែឈើព្រៃទទួលទានដាក់ក្រពះជាការសម្ងាត់មិនប្រាប់ពីមាត់១ទៅមាត់១ ហើយបើខ្មែរក្រហមចាប់បានឃើញបេះផ្លែឈើព្រៃ ទណ្ឌកម្ម គឺប្រហារជីវិត។ ខ្មែរក្រហមបង្ខំមនុស្សឲ្យធ្វើការ ១២ម៉ោង គ្មានឈប់ គ្មានពេលសំរាក គ្មានម្ហូបអាហារ។ អំពើនេះធ្វើឲ្យ មហាជនស្លាប់រង្គាល ដោយការពិឃាត ដោយហត់នឿយ ដោយឈឺថ្កាត់ និងដោយអត់បាយ។ ខ្មែរក្រហមមិនជឿថ្នាំសង្កូវបស្ចឹមប្រទេស រុករកថ្នាំតាមប្រពៃណី ជាលទ្ធផល មនុស្សស្លាប់ដោយ ជម្ងឺគ្រុនចាញ់ រាប់រយពាន់នាក់។

ប្រាក់កាសត្រូវបំបាត់ចោល សៀវភៅត្រូវដុតអស់ គ្រូបង្រៀន អ្នកជំនួញ អ្នកចេះដឹងទាំងឡាយត្រូវគេធ្វើឃាត ដើម្បីនិងបង្កើតសង្គមកុម្មុយនីស្តថ្មីបរិសុទ្ធ ដែលមានកសិកម្មជាជំហរ និង វណ្ណៈស្មើគ្នា ហើយដែលប្រមើលឃើញ ដោយ ប៉ុលពត ជាការពិតដែលអាចបង្កើតបាន។ គំរោងការកើតឡើងជម្លៀសមនុស្ស ចេញពីទីក្រុងត្រូវបញ្ឈប់ចលនាសេដ្ឋកិច្ចទាំងមូល ការអប់រំ ការព្យាបាល ផលិតផលរោងចក្រ។ ធនាគារត្រូវគេវាយបំបែកបំផ្លាញអស់ក្រដាស់ប្រាក់ ដុតចោលបញ្ជីរកត់ត្រាសំគាល់។

នៅពេល៤ឆ្នាំដែលកាន់កាប់អំណាច ខ្មែរក្រហមបង្ខំឲ្យមនុស្សធ្វើការហួសកំរិត មិនឲ្យអាហារ ហើយជាមួយនេះ ធ្វើឃាតដល់អ្នកណាដែលគេសង្ស័យជាសត្រូវ ជាគេញអ្នកស៊ើបការដែល ចង់បង្កើតរបបថ្មី។ គេសម្លាប់មនុស្សដែលគេជឿថាមានបញ្ញា សូម្បីមនុស្ស ពាក់វ៉ែនតាគេសំគាល់ជាអ្នកចេះដឹង ក៏ត្រូវគេសម្លាប់ចោលដែរ។ មនុស្សក៏ត្រូវគេសម្លាប់ដែរ បើចង់រត់ពីឃុំ១ទៅ១ ឬក៏ធ្វើអ្វី១ខុសច្បាប់បន្តិចបន្តួច។ បើចាប់ទោសបានហើយមនុស្សនោះ យប់ឡើងត្រូវគេយកជាសម្ងាត់ទៅក្នុងព្រៃហើយសម្លាប់ចោល។

សាសនាទាំងអស់ត្រូវហាមឃាត់មិនឲ្យប្រព្រឹត្ត។ អ្នកណាក៏ដោយបើឃើញចូលគ្នាប្រព្រឹត្តជាទម្លាប់សាសនា ឬ ជុំគ្នាបន់ស្រន់ និងត្រូវ ពិឃាតភ្លាមៗ។ មានលោកសង្ឃ ឥស្លាម និង អ្នកសាសនាគ្រីស្ត ត្រូវគេសម្លាប់ដោយប្រើប្រាស់ជំនឿរបស់ខ្លួន។ រឿងរ៉ាវទាក់ទងក្នុងគ្រួសារត្រូវតែមានការយល់ព្រម ពីអង្គការ បើសមាជិកគ្រួសារចាប់ឃើញនិយាយរកគ្នា អង្គការនិងដាក់ទោសដល់ស្លាប់។ គ្រួសារប្តីប្រពន្ធឲ្យជួបគ្នាបានបើអង្គការបើកដៃឲ្យ។ បើមានមនុស្សចាប់បានប្រព្រឹត្តរួមសង្វាសនិងត្រូវគេសម្លាប់ចោលភ្លាមៗ។ ការធ្វើដំណើរចេញចូលទៅមកត្រូវបញ្ឈប់។ សេរីភាពរបស់មនុស្សត្រូវគេ

បំបាត់ចោល។ មនុស្សមិនអនុញ្ញាតិឲ្យទទួលទានអាហារជាផ្ទាល់ខ្លួន គេត្រូវទទួលទានជាមួយគេគ្រប់គ្នាក្នុងសហគមន៏។ ប្រជាប់ប្រដាចានឆ្នាំង សមស្លាបព្រាត្រូវហាមប្រាម មនុស្សម្នាក់គេចែកឲ្យតែស្លាបព្រា១។ មានការប្រភេទជាច្រើន សមាជិកគ្រួសារត្រូវគេបំបែកឲ្យរស់នៅក្នុងដំបន់ ផ្សេងៗពីគ្នាដែលគ្មានគ្រឿងអ្វីនិងទាក់ទង គ្មានប្រៃសណីយ គ្មានតេឡេហ្វូន អ្វីៗជាការទាក់ទងបានត្រូវគេបំផ្លាញចោលអស់។

## ការប្តូរភាសា

ភាសាខ្មែរ មានផ្សំផ្គុំឡើងស្មុគ្រស្មាញ សំរាប់ហៅទាក់ទងគ្នា អ្នកថ្លែងការអ្នកប្រធាន ឬអ្នកជាន់ថ្នាក់ៗ ក្នុងសង្គម។ នៅក្រោមអំណាចខ្មែរក្រហមភាសាទាំងនេះត្រូវគេលុបចោល។ មនុស្សឲ្យហៅគ្នាទៅវិញទៅមក "មិត្ត" ហើយឲ្យឈប់ ចាប់ដៃគ្នា បន្ទន់ខ្លួន ឬ សំពះគ្នាទៅវិញទៅមក។

ភាសាខ្មែរចាប់ផ្តូររូបរាង។ ខ្មែរក្រហមបង្កើត ពាក្យថ្មីៗ។ មនុស្សទាំងឡាយបង្គាប់ឲ្យ "លត់តាម " មានអកប្បកិរិយាបដិវត្តន៏ មានឈ្នាន់ "ឧប្បករណ៏ " គោរពតាមបញ្ជា "អង្គការ " ការអាឡោះអាល័យដល់របបចាស់ "ឈឺសតិអារម្មណ៏ " ត្រូវគេសម្លាប់ចោល។ រួចហើយភាសាតាមស្រុកស្រែដែលហៅ ម្តាយ ថា "ម៉ែ " ត្រូវផ្តូរពាក្យក្រុងដែលហៅម្តាយ ថា "ម៉ាក់ "។

## បទឧក្រិដ្ឋ ប្រឆាំងនិងមនុស្សធម៏



**លលាដ៍ក្បាលខ្មោចអ្នករងគ្រោះ**



**ឆ្អឹងអ្នករងគ្រោះនៅសល់ក្នុងអន្លង់ កំពង់ត្រាច គីរីសីលា រោងនីក (ឬហៅ រោងខ្មោចដែរ)**

រដ្ឋាភិបាលខ្មែរក្រហម ចាប់ចង ធ្វើទារុណកម្ម និង ធ្វើឃាត ដល់ពលរដ្ឋណាដែលមានសង្ស័យថាមានការទាក់ទងនិងពួកទាំងឡាយដូចខាងក្រោមនេះ ដែលគេចាត់ទុកជា "សត្រូវ":

- អ្នកណាម្នាក់ដែលទាក់ទងនិងរដ្ឋាភិបាលមុន ឬ រដ្ឋាភិបាលបរទេស។
- អ្នករដ្ឋការ និង អ្នកបញ្ញាវន្ត – ក្នុងការអនុវត្តន៏ គេរាប់ទាំងអ្នកណាដែលមានចំណេះវិជ្ជា ចេះនិយាយភាសាអង់គ្លេស មានពាក់វ៉ែនតា (ពី

ព្រោះគេកាត់យល់ថាជាមនុស្សចេះមើលអក្សរ)។ ដោយផ្ទុយទៅវិញ ប៉ុលពត ខ្លួនឯង មានការអប់រំនៅ មហាវិទ្យាល័យ (ទោះបីរៀនមិនចប់ក៏ដោយ) មានរសជាតិចូលចិត្ត អក្សរសាស្រ្តបារាំង ហើយចេះនិយាយភាសាបារាំងយ៉ាងស្ទាត់។ មានអ្នកសិល្បៈជាច្រើនត្រូវគេពិឃាត មានអ្នកធ្វើកុន អ្នកភ្លេង អ្នកចំរៀង ដូចជា រស់សិរិសុទ្ធា ប៉ែនរ៉ន និង ស៊ីនស៊ីសាមុត ដែលនៅតែល្បីចូលចិត្តដោយប្រជាជនខ្មែរក្នុងសម័យឥឡូវថ្វីបើបានស្លាប់ទៅហើយក៏ដោយ។

- អ្នកមានសញ្ជាត្តិជា យួន ចិន ថៃ ជនជាតិភាគតិចមកពីអ៊ឺរ៉ុបខាងកើត ខ្មែរកាន់គ្រីស្តសាសនា (ភាគច្រើនជាកាតូលិក) ជនជាតិ ឥស្លាម និង ព្រះសង្ឃខ្មែរ។ មហាព្រះវិហារ រូម៉ង់កាតូលិក នៅភ្នំពេញ ត្រូវវាយកំទេចចោល។ ខ្មែរក្រហមបង្ខំ ចាមឥស្លាមឲ្យទទួលទានសាច់ជ្រូកៗ ដែលឥស្លាមគោរពជាទីសក្ការបូជា។ អ្នកណាដែលប្រកែកត្រូវសម្លាប់ចោល។ គ្រូអាចារ្យគ្រីស្តសាសនា និង លោកសង្ឃចាម ត្រូវគេពិឃាត។
- "អ្នកធ្វើសេដ្ឋកិច្ចវិទ្ធង្សនា" – មនុស្សមកពីទីក្រុងដែលមិនចេះធ្វើកសិកម្ម ត្រូវគេចោទជាអ្នកធ្វើវិទ្ធង្សនា។

ចំពោះអ្នកនោះដែលគេចោទជាអ្នកក្បត់ត្រូវយកទៅគុកសម្ងាត់ហៅ អែស-២១ S-21 ។ គេកម្រនិងឲ្យអាហារណាស់ដល់អ្នកទោស ដោយលទ្ធផលនេះ ភាគច្រើនអ្នកទោសស្លាប់ដោយដាច់ពោះ។ អ្នកទោសឯទៀតស្លាប់ដោយទារុណកម្មយ៉ាងអាណោចអាធម្មដល់រូបរាងកាយ។

ក្នុងរយៈឆ្នាំ១៩៧០ឡើង ជាពិសេសក្រោយពីឆ្នាំ១៩៧៥ គណៈបក្សមានការជម្លោះគ្នាផ្ទៃក្នុង។ មានបក្សកាន់អាវុធចង់ប្រហារប៉ុលពត។ ការសម្លាប់កំចាត់ចោលត្រូវឲ្យអស់ ឡើងដល់ក៏រឹតឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ពេល

ដែលមនុស្សរាប់ពាន់ និង មេដឹកនាំសំខាន់របស់គណៈបក្សខ្មែរក្រហម ខ្លះផងដែរ ត្រូវគេប្រហារ។

ឧទាហរណ៍ពីរបៀបដែលខ្មែរក្រហមធ្វើ ទារុណកម្ម មានដាក់តាំងឲ្យមើលមកដល់ឥឡូវ នៅបណ្ណាល័យសម្លាប់ផុតពូជនៅ ទួលស្លែង **Tuol Sleng Genocide Museum** ។ បណ្ណាល័យនេះស្ថិតនៅកន្លែងសាលាវិទ្យាល័យចាស់ដែលគេយកធ្វើជាមន្ទីរគុក កាន់កាប់ដោយ កាំងកែកអៀវ ហៅ "មិត្តឌុច "។ មានមនុស្ស ១៧,០០០ នាក់ បានចូលកាត់មន្ទីរគុកនេះមុននិងយកទៅ កន្លែងក្រៅក្រុងឈ្មោះជើងឯក ដែលគេស្គាល់ថាជាលានវាយសម្លាប់ (ដោយប្រើត្បូងចបមិនបង្ខាតគ្រាប់កាំភ្លើង) ហើយកប់ក្នុងរណ្តៅតែ១ដែលមានខ្មោចរាប់ពាន់នាក់។ ក្នុងចំណោមមនុស្សរាប់ពាន់ដែលចូល ទួលស្លែង មានតែ១២នាក់គត់ដែលនៅរស់។ គេទុកឲ្យមានជីវិតក៏ដោយសារមនុស្សទាំងនេះជាអ្នកជំនាញមានទេព្យកោសល្យប្រើការបានៗជាទុកឲ្យមានជីវិតដោយមេគុក។

អគារទាំងឡាយនៅទួលស្លែងត្រូវទុករក្សាដូចដើមពេលដែលខ្មែរក្រហមត្រូវកងទ័ពយួនដេញចេញនៅឆ្នាំ១៩៧៩។ បន្ទប់ជាច្រើនឥឡូវនេះមានបិទរូបថតខ្មៅ-សជាច្រើនដែលថតទុកដោយខ្មែក្រហម។

## ចំនួនមនុស្សស្លាប់

ការស្រាវជ្រាវសម័យថ្មីបានរកឃើញ ២០,០០០អន្លង់ ដែលមានកប់ខ្មោចរាប់រយពាន់ក្នុងអន្លង់១ៗ នៅជំនាន់ខ្មែរក្រហម។ ការស្ទង់រៀនជាច្រើនប្រមាណការស្លាប់មានពី ៧៤០,០០០ នាក់ ទៅដល់ ៣,០០០,០០០នាក់ ខ្លះប្រមាណខ្ពស់បំផុតរវាង ១.៤លាន និង ២.២លាន ហើយពាក់កណ្តាល

នេះស្លាប់ដោយធ្វើឃាត និង នៅសល់ស្លាប់ដោយ អត់អាហារ និង ជម្ងឺ។ សហរដ្ឋអាមេរិកក្រសួងការបរទេស បានបង្កើតអង្គការជួយជាប្រាក់ដល់មហាវិទ្យាល័យ យ៉េល ឲ្យធ្វើ គំរោងការសិក្សាប្រទេសខ្មែរនិងការសម្លាប់រង្គាល បានប្រមាណ ថាមានមនុស្សស្លាប់មាន១.៧លាននាក់។ លោក រ.យ្ជេ.រ៉ុម៉ែល <u>**R. J. Rummel**</u> អ្នកប្រវត្តិសាស្ត្ររៀនពីនយោបាយកាប់សម្លាប់ ប្រមាណថា មាន ២លាននាក់ស្លាប់។ អង្គការសហប្រជាជាតិស៊ើបអង្កេតធ្វើសេចក្តីថ្លែងការថា មាន ២-៣លាន នាក់ស្លាប់ ឯអង្គការសហប្រជាជាតិ **UNICEF** ប្រមាណថាមាន ៣លាន នាក់ត្រូវស្លាប់។ អ្នកសិក្សាប្រជាជន ប៉ាទ្រិក ហ៊ូវើរលើន ប្រមាណថាមានស្លាប់ចន្លោះ ១.១៧ និង ៣.៩២លាន នាក់ ជាមួយគ្នានេះ លោក ម៉ារិក ស្លីវិនស្គី ប្រមាណថាចំនួនស្លាប់ ១.៨លាននាក់គឺយ៉ាងតិច។ អ្នកស្រាវជ្រាវឯកសារប្រទេសខ្មែរ ក្រេក អែតឆើសុន ប្រមាណថាមានអ្នកស្លាប់ ពី ២លាន ទៅ ២.៥លាននាក់ ឲ្យច្បាស់ប្រហែល ២.២លាននាក់។ ក្រោយពីដើរសង្កេតអន្លង់សម្លាប់ទាំងឡាយ គាត់ប្រមាណចំនួនឆ្អឹង ថាមានមនុស្ស ១,៣៨៦,៧៣៤ នាក់ដែលត្រូវគេសម្លាប់។

## *ការធ្លាក់របបខ្មែរក្រហម*

ជាមួយនិងអង្គការ រួបរួមមុខស្រោចស្រង់ជាតិកម្ពុជា **the Kampuchean United Front for National Salvation** ដែលជាអ្នកស្អប់និងធ្លាប់ជាសមាជិករបបប៉ុលពតដែលមានហ៊ុនសែននិងបក្សពួក បានចូលដៃជាមួយទ័ពយួនលុកលុយកាន់កាប់ភ្នំពេញនៅ ថ្ងៃទី៧ខែមករាឆ្នាំ១៩៧៩។ ថ្វីបើមានកេរ្តិ៍ដំណែលខ្មែរខ្លាចយួនយកទឹកដី អ្នកក្បត់ខ្មែរក្រហម រត់ទៅរកយួនឲ្យចូលកាន់កាប់ទឹកដី។ យួនយកពួកនេះនិងពួកខ្មែរដែលលក់ខ្លួនឲ្យយួនពី

កំណើត ធ្វើជាស្នូល បង្កើតរដ្ឋាភិបាលថ្មីហៅថា ប្រជាជនសាធារណៈកម្ពុជា **People's Republic of Kampuchea** ជាភ្លាមៗនោះរបបខ្មែរក្រហម ដែលរត់ទៅជ្រកកោនក្រៅប្រទេស និង ប្រទេសចិន ប្រឆាំងហើយ ឲ្យឈ្មោះរដ្ឋាភិបាលនេះជា "រដ្ឋាភិបាលតុក្កតារបស់យួន" "**puppet government**" ។

ពេលជាមួយគ្នានេះ ខ្មែរក្រហមដកខ្លួនទៅទិសខាងលិច ហើយចាប់ត្រួតត្រា ដំបន់ខ្លះជាប់ព្រំដែនប្រទេសថៃរយៈ១០ឆ្នាំក្រោយ ដែលមានដូចជា ដំបន់ភ្នំម៉ាឡៃ ដំបន់ភ្នំៗជិត បប៉ៃលិន ភ្នំក្រវាញ អន្លង់វែង និង ភ្នំដងរែក។

មូលដ្ឋានខ្មែរក្រហម មិនអាចផ្គត់ផ្គង់កងពលដោយខ្លួនឯងដោយគ្រប់គ្រាន់ ក្រៅពីរត់ពន្ធត្បូងនិងពេជនិងកាត់ឈើទៅលក់ឯប្រទេសថៃ មានជំនួយខ្លះមកពីប្រទេសចិនតាមកងទ័ពថៃឆ្លងព្រំប្រទល់ដែន។

មានប្រជារាស្ត្រខ្មែរជាច្រើនឆ្លងដែនចូលទៅសុំជ្រកកោននៅ មន្ទីរភាសខ្លួន ដូចជា សាកែវ ឬ ខៅអាយដាង ដែលជាជនភាសខ្លួនដែលបានយកមករស់នៅ ប្រទេស សហរដ្ឋអាមេរិក បារាំង កាណាដា និង អូស្ត្រាលី។ ឯជនភាសខ្លួនឯទៀតដូចជា សៃត៏៨ ភ្នំឆាត ឬ តាព្រិក មេកងខ្មែរក្រហម កាន់កាប់បង្កើតការចែកចាយអាហារបង្ខិតបង្ខំ និងឲ្យមានការទាក់ទងតិចតួចជាមួយអង្គការបរទេស។

## ខ្មែរក្រហមនិងកៅអីនៅអង្គការសហប្រជាជាតិ

ថ្វីបើត្រូវគេទម្លាក់ចោល ខ្មែរក្រហមនៅរក្សាកៅអីនៅអង្គការសហប្រជាជាតិ ដែលមាន ជួនប្រសិទ្ធ ជាមេហើយដែលជាមិត្តចាស់របស់ប៉ុលពតពេលជានិស្សិតដូចគ្នានៅទីក្រុង ប៉ារីស ហើយដែលជាអ្នកដឹកនាំ២១នាក់ចូលជំនុំជាសភាសមាជិកលើកទី២ របស់ គណៈបក្ស

KPRP ឆ្នាំ១៩៦០។ កៅអីនេះត្រូវរក្សាក្រោមឈ្មោះ "កម្ពុជាប្រជាធិបតេយ្យ" "Democratic Kampuchea" រហូតដល់ឆ្នាំ១៩៨២ រួចហើយក្រោមឈ្មោះ "រដ្ឋាភិបាលចំរុះប្រជាធិបតេយ្យកម្ពុជា" "Coalition Government of Democratic Kampuchea" រហូតដល់ឆ្នាំ ១៩៩៣។ រដ្ឋាភិបាលប្រទេសបស្ចឹមប្រទេស នៅតែបន្តការគាំទ្រកៅអីខ្មែរក្រហមនៅអង្គការសហប្រជាជាតិ។ អ្នកស្រីនាយករដ្ឋមន្ត្រីប្រទេសអង់គ្លេស ម៉ាគ្គារេត ថាច់ឆើរ មានវាចារថា "វាសមហេតុសមផលដែលខ្មែរក្រហមនៅរក្សាកៅអី ប៉ុន្តែខ្ញុំសង្ឃឹមថាពួកអ្នកឯងនិងបានភាគតិចក្នុងរដ្ឋាភិបាលចំរុះ ពីព្រោះខ្ញុំបានដឹងឮអំពីអំពើយង់ឃ្នងរបស់ខ្មែរក្រហមនៅប្រទេសខ្មែរ"។ ចំណែកប្រទេស ស្វីដិន វិញ មិនព្រមបោះឆ្នោតឲ្យកៅអីនៅអង្គការសហប្រជាជាតិទៅខ្មែរក្រហម ពីព្រោះមានប្រជាជនជាតិស្វីដិន សរសេរសំបុត្រទៅអ្នកដំណាងកុំឲ្យបោះឆ្នោតឲ្យរបបប៉ុលពត។

## <u>ហេតុផលដែលកើតឡើងបន្តបន្ទាប់គ្នាក្រោយពីវៀតណាមលុកលុយ</u>

ជោគជ័យរបស់វៀតណាមលុកលុយប្រទេសខ្មែរ មានការគាំទ្រអំពីសហភាពសូវៀត ដែលបណ្តាលឲ្យមានហេតុផលកើតឡើងបន្តបន្ទាប់គ្នានៅក្នុងជំបន់ ប្រទេសសាធារណៈចិនប្រជាមានិត ចាប់វាយលុកជំបន់ខាងជើងរបស់ប្រទេសយួនដើម្បីជាទណ្ឌកម្មដែលយួនវាយប្រទេសខ្មែរ រួចហើយដកថយវិញ (ទាំងសងខាងទាមទារថាមានជ័យជំនះ–ប៉ុន្តែតាមការពិតដែលពុកដឹង គឺចិនវាយមិនចុះ យួនក្រោយពីឈ្នះចំបាំងនៅយួនខាងត្បូង បានជន្លៀសគ្រឿងសឹក ទំនើបៗដែលទុកលះបង់ដោយទ័ពសហរដ្ឋអាមេរិកក្រោយពីដកថយ យកទៅដាក់ប្រឈមមុខទល់ដែនចិន–យួនខាងជើងរៀបចំចាំទ័ពចិនហើយស្រេច។ តាម នូវយ៉ាក់ថែម

ទស្សនាវដ្ដីឆ្នាំ១៩៧៩ ចុះចំណងជើងថា "ពីណាដាក់ទណ្ឌកម្មពីណា" គឺមាន
រូបថតទ័ពចិនស្លាប់គរជើងពេល វាយលុកយួនខាងជើង ដោយត្រូវឡើង
កាត់ភ្នំផង ដោយយួនមានសម្ភារៈបាមពលខ្លាំងជាង និង ថ្មីកខាងផ្លូវសឹក
ជាងផង)។ ប្រទេសចិន សហរដ្ឋអាមេរិក និង ប្រទេស **ASEAN**
**(Association of Southeast Asian Nations -** មានប្រទេសដូចជា
ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សាំងគ្គាពួរ ថៃឡង់ ប្រ៊ុយណៃ ភូមា
ប្រទេសខ្មែរ លាវ និង វៀតណាម**)** ប្រទេសទាំងនេះលើកលែងតែ
ប្រទេសវៀតណាមបានផានាគាំទ្រឲ្យបង្កើតរដ្ឋាភិបាលក្រៅប្រទេស ហៅថា
រដ្ឋាភិបាលបង្រួបបង្រួមប្រជាធិបតេយ្យកម្ពុជា **Coalition Government of Democratic Kampuchea** ដែលមាន ខ្មែរក្រហម ខ្មែរសាធារណៈរដ្ឋ
**KPNLF (Khmer People's National Liberation Front -**
ដឹកនាំដោយ សុន សាន និង ឧត្ដមសេនីយមកពីរបបសាធារណៈរដ្ឋ
លន់ណុលខ្លះដូចជា ដៀនដែល**)** ហើយនិងកងទ័ពរាជានិយម **ANS**
**(Armee Nationale Sihanoukiste)**។

នៅដំបន់ខាងកើតនិងកណ្ដាលត្រូវយួនកាន់កាប់ពេញទីជាមួយកងទ័ពលក់
ខ្លួនហ៊ុនសែន ហើយនៅខាងលិចមានសមរភូមិនៅធ្វើឡើងរហូតដល់ឆ្នាំ
១៩៨០ឡើង ហើយផងដែរមានវាយគ្រាប់មីុនផ្ទុះរាប់លានកាត់ជនបទ
មាត់ញក។ កងទ័ពខ្មែរក្រហមនៅតែជាមេដឹកនាំធំចំណោមកងទ័ពបះបោរ
ប្រឆាំងនិងយួននិងពួកដៃជើង។ កងទ័ព រដ្ឋាភិបាលបង្រួបបង្រួម
ប្រជាធិបតេយ្យកម្ពុជាមានបានទទួលជំនួយ និង យោធាសម្ភារៈពីប្រទេស
ចិន អង់គ្លេស និង សហរដ្ឋអាមេរិក ហើយទទួលជំនួយស៊ើបការ
អំពីកងទ័ពប្រទេសថៃ។

នៅឆ្នាំ១៩៧៩ ពួកខ្មែរក្រហមចង់លាងខ្លួន លាក់ពុតរបបខ្លួន ដូរឈ្មោះ
ពីកុម្មុយនីស្ត បង្កើត គណៈបក្ស ចលនាបង្រួបបង្រួមស្នេហាជាតិកម្ពុជា

**Patriotic and Democratic Front of the Great National Union of Kampuchea** ។ នៅឆ្នាំ១៩៨១ ខ្មែរក្រហមប្រកាសជាផ្លូវការទម្លាក់ទ្រឹស្តីកុម្មុយនីស្ត យក ចលនាស្នេហាជាតិប្រឆាំងនិងយួនជាមនោគតិ។ ប៉ុន្តែអ្នកប្រវត្តិសាស្ត្រ ខេវិន រ៉ូវលី សរសេរថា "គណៈបក្សខ្មែរក្រហមតែងតែយកស្នេហាជាតិ ជាធំតាំងពីពេលកើតមក មិនដែលនិយាយអំពីបដិវត្តន៏ទេ" (កំណាត់អ្នកនិពន្ធៈ បានសេចក្តីថាឆ្កែកន្ទុយខ្សៀនមិនងាយនិងរលារិញ)។ ថ្វីបើប៉ុលពតផ្ទេរដំណែងឲ្យទៅខៀវសំផនឆ្នាំ១៩៨៥ ប៉ុលពតនៅតែជាអ្នកដែលមានឥទ្ធិពលនិងសក្មភាពដឹកនាំ ឃោសនាពន្យល់ ដល់កងទ័ពខ្មែរក្រហម។ អ្នកយកការសាពត៌មាន នេតថាយើរ ដែលបានចំណាយពេលជាច្រើនសង្កេតប៉ុលពត សរសេរថា ថ្វីបើអង្គការទូទៅក្នុងលោកចោទប្រកាន់ប៉ុលពតជាមេសម្លាប់រង្គាល ប្រជាជនដែលនៅក្រោមប៉ុលពតឃើញដូចជាស្រឡាញ់គោរពប៉ុលពតដោយស្មោះស្ម័គ្រ។

ពេលដែលវៀតណាមស្នើរនិងដកថយពីប្រទេសខ្មែរ បើគេដកហូតរបបប៉ុលពតចេញពីក្រុមចរចារ ចលនារដ្ឋាភិបាលរួបរួម ព្រមជាមួយនិងប្រទេស **ASEAN** ចិន និង សហរដ្ឋអាមេរិក មិនព្រម។ ទោះបីដូច្នេះក្តី នៅឆ្នាំ១៩៨៥ វៀតណាមប្រកាសនិងដកថយនៅឆ្នាំ១៩៩០។ ប៉ុន្តែនៅឆ្នាំ១៩៨៩ វៀតណាមដកទ័ពថយ ក្រោយពីរដ្ឋាភិបាលតុក្កតា ហ៊ុនសែនបានកើនមាំទាំ មានកម្លាំងការពារខ្លួនឯងបានខាងផ្នែកយោធា។

ក្រោយពីជម្លោះមិនដោះស្រាយបានរវាង១០ឆ្នាំ រដ្ឋាភិបាលតុក្កតាយួន និងរដ្ឋាភិបាលខ្មែរចំរុះក្រៅប្រទេស ស៊ីញ៉េសិទ្ធិសញ្ញានៅឆ្នាំ១៩៩១ ឲ្យដាក់អាវុធចុះ និង បង្កើតការបោះឆ្នោត។ ប៉ុន្តែនៅឆ្នាំ១៩៩២ ខ្មែរក្រហមមិនព្រមចូលបោះឆ្នោត ហើយចាប់បន្តវាយសឹក ហើយទាត់ចោលមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។ ខ្មែរក្រហមរត់ចូលព្រៃម្តងទៀត ម្តងនេះវាយច្បាំងទល់និង រដ្ឋាភិបាលតុក្កតាយួនដឹកនាំដោយហ៊ុនសែន

កងទ័ពសាធារណៈមិនមែនកុម្មុយនីស្ត និង កងទ័ពហែរហាមរាជា (ដែលមានអម្ចាស់ទ្រង់ រណ្ណារិទ្ធ ជាព្រះរាជបុត្ររបស់សម្ដេចនរោត្តមស៊ីហនុ)។ នៅខែកក្កដាឆ្នាំ១៩៩៤ ខ្មែរក្រហមបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នរួបរួមនិងស្រោចស្រង់ជាតិកម្ពុជា។

នៅឆ្នាំ១៩៩៦ មានកងពលពាក់កណ្ដាលទ័ពខ្មែរក្រហមក្បត់រត់ចេញ១យ៉ាងធំ (ប្រហែល ៤,០០០នាក់រត់ចេញ)។ នៅឆ្នាំ១៩៩៧ មានការជម្លោះ១រវាង រដ្ឋាភិបាលតុក្កតាយួន និង កងពលទ្រង់ រណ្ណារិទ្ធ ដែលបណ្ដាលឲ្យ ទ្រង់រណ្ណារិទ្ធ ជជីករកជំនួយគាំទ្រពីខ្មែរក្រហម ប៉ុន្តែព្រះអង្គប្រកែក មិនព្រមធ្វើការជាមួយប៉ុលពតផ្ទាល់។ ដោយសារហេតុនេះមានជម្លោះបង្ហូរឈាម១ក្នុងចំណោមមេដឹកនាំខ្មែរក្រហមជាចុងបញ្ចប់ ប៉ុលពត ត្រូវគេចាប់ដាក់ឃុំឃាំងដោយមេកងខ្មែរក្រហម។ នៅខែមេសាឆ្នាំ១៩៩៨ ប៉ុលពតស្លាប់បាត់បង់ជីវិត។ ខៀវសំផនចុះចាញ់នៅខែធ្នូរ។

នៅថ្ងៃទី២៩ខែធ្នូរ ឆ្នាំ១៩៩៨ អ្នកដឹកនាំខ្មែរក្រហមដែលនៅសល់ ប្រកាសសុំទោសអំពីការសម្លាប់រង្គាលនៅឆ្នាំ១៩៧០ឡើង។ មកដល់ឆ្នាំ១៩៩៩ ភាគច្រើននៃអ្នកដឹកនាំខ្មែរក្រហមចុះចាញ់ឬចាប់បាន។ នៅខែធ្នូរឆ្នាំ១៩៩ មេទ័ពចុងក្រោយ តាម៉ុក **<u>Ta Mok</u>** និងមេឯទៀតៗចុះចាញ់ ហើយរបបខ្មែរក្រហមក៏រលត់បាត់នៅពេលនោះ។ មេដឹកនាំខ្លះនៅរស់នៅ បប៉ៃលិន ខ្លះនៅរស់លាក់ខ្លួននៅភ្នំពេញ។

## <u>សភាវិសាមញ្ញនៃតុលាការកាត់សេចក្ដីនៅប្រទេសខ្មែរ Extraordinary Chambers in the Courts of Cambodia (ECCC)</u>

សភាវិសាមញ្ញនៃតុលាការកាត់សេចក្ដីប្រទេសកម្ពុជា **ECCC** បង្កើតឡើងជាតុលាការខ្មែរដែលមានជំនួយពីអន្តរជាតិ កាត់សេចក្ដីដល់អ្នកដឹកនាំខ្មែរក្រហមទៅលើបទឧក្រិដ្ឋសម្លាប់រង្គាលដល់ប្រជាជនខ្មែរពេលកាន់ដំណែង ។ តុលាការបានកាត់សេចក្ដី ៤ខ ពីឆ្នាំ២០០៧មក។ ភារៈកិច្ចរបស់ **ECCC** គឺការឈោងដៃទៅកាន់ឲ្យបានដល់ប្រជាជនក្នុងប្រទេសនិងបរទេស ដែលមានការកាត់សេចក្ដីជាសាធារណៈ មានពួកអ្នករៀនសង្កេតការរូបភាពជាទូរទស្សន៍ មានសាលាបង្ហាញពន្យល់ និងរូបភាពដាក់តាំងក្នុងអិនធើរណិត ទុកឲ្យមើលនិងអាន។

ពេលកាត់សេចក្ដី កាំងកែកអ៊ីវ (មិត្ត ឌុច) ចាងហ្វាងមន្ទីរគុកដែលធ្វើទារុណកម្មនិងសម្លាប់មនុស្ស ១៦,០០០ នាក់ រាប់ទាំង កូនក្មេង និង ស្ត្រី នៅថ្ងៃទី២៧ខែវិច្ឆការឆ្នាំ២០០៩ ធ្វើឲ្យតុលាការ ភ្ញាក់ផ្អើលដោយ កាំងកែកអ៊ីវ ចាប់ផ្ដើម សុំអភ័យទោស អំពីអំពើរបស់ខ្លួន ហើយសុំឲ្យតុលាការលើកលែងទោសខ្លួន។ អ្នកអវការរបស់កាំងកែកអ៊ីវមានជាតិជាខ្មែរឈ្មោះកសាវុធ **Kar Savuth** ធ្វើឲ្យតុលាការរឹតតែភ្ញាក់ផ្អើលថែម ដោយសុំឲ្យតុលាការទាត់ចោលខនេះ សូម្បីអ្នកអវការរបស់កាំងកែកអ៊ីវជាតិបារាំងក៏មិនហ៊ានបើកមាត់សុំដូចនេះដែរ។ នៅថ្ងៃទី២៦ខែកក្កដាឆ្នាំ២០១០ កាំងកែកអ៊ីវ ត្រូវតុលាការកាត់សេចក្ដីឲ្យជាប់គុក៣០ឆ្នាំ។ មានមនុស្សជាច្រើនយល់ថាការកាត់សេចក្ដីនេះមិនសមហេតុសមផល ទណ្ឌកម្មតិចពេក។ អ្នកអវការ ធែរីសេង **Theary Seng** តវ៉ាដោយឈឺចិត្តថា: "យើងខ្ញុំសង្ឃឹមថា តុលាការនេះ មានយុត្តិធម៌ បើមនុស្សម្នាក់សម្លាប់មនុស្ស ១៤,០០០នាក់ ហើយជាប់គុកតែ១៩ឆ្នាំ –១១ម៉ោងក្នុងការយកជីវិតមនុស្សម្នាក់ – តើមានន័យដូចម្ដេច? គឺជាការគួរឲ្យអស់សំណើច"។ បើតាមការស្មានពីពោះវៀនពោះតាំងរបស់ខ្ញុំ ការកាត់សេចក្ដីនេះ ធ្វើឲ្យរឹតតែអាក្រក់

ដល់ស្ថានការប្រទេសខ្មែរ គឺគ្មានការទុកចិត្តទាល់តែសោះដល់មនុស្សលោក ហើយធ្វើឲ្យគេគិតថាមាននយោបាយចូលលាយឡំជាមួយនេះ"។

ឌុច តវ៉ាទៅតុលាការជាន់លើអំពីការកាត់សេចក្តីនេះ ប៉ុន្តែល្បិចនេះជាន់កខ្លួនឯង។ នៅខែកុម្ភៈឆ្នាំ២០១២ លោកចៅក្រម គង់ស្រ៊ឹម ទាត់ចោលការតវ៉ាកាត់សេចក្តីថា ឌុចប្រាកដជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋដ៏ធំក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ត្រូវតែមានទណ្ឌកម្មឲ្យខ្ពស់បំផុត។ លោកចៅក្រម កាត់សេចក្តីឲ្យឌុចជាប់គុក១ជីវិត។

# ជំពូក ទី៨

# ប្រទេសខ្មែរឆ្នាំ១៩៧៩-សម័យតឡូច (ហ៊ុនសែន - គណៈបក្សប្រជាជនខ្មែរ-រដ្ឋាភិបាលតុក្កតាយួន)

ប្រទេសវៀតណាមចូលលុកលុយប្រទេសកម្ពុជាឆ្នាំ១៩៧៩ កំចាត់ចោលរបប ប៉ុលពត រួចហើយដាក់តាំងរបបថ្មីដែលមាន ហ៊ុនសែន ជាអ្នកដឹកនាំ គឺជារដ្ឋាភិបាលតុក្កតារបស់យួនដែលពិភពលោកសព្វថ្ងៃស្គាល់មកដល់ថ្ងៃនេះ។ ដូចជាប្រទេសវៀតណាមជំនាន់ថ្មី ប្រទេសខ្មែរនៅជាប្រទេសកុម្មុយនីស្ត លាក់មុខដូរផ្លាកដាក់រាជាណាចក្រនិយម អនុវត្តន៏អនុញ្ញាតិជំនួញពាណិជកម្មតាមបស្ចឹមប្រទេស (ដូចប្រទេសកុម្មុយនីស្តឯទៀតក្នុងលោក សហភាពសូវៀត ចិន យួន និង ប្រទេសខ្មែរ)។ ហ៊ុនសែន ជាបុគ្គលដែលមានអំណាចនិងឥទ្ធិពល ខ្លាំងជាងគេក្នុងផ្លូវនយោបាយនៃប្រទេសកម្ពុជា ធ្វើឃាតដល់អ្នកធ្វើនយោបាយប្រឆាំង ឬកំញើញឲ្យរត់ចោលប្រទេស និរទេសខ្លួនទៅបរទេស ភាគច្រើនរត់ទៅនៅប្រទេសបារាំង។ ឧទាហរណ៏មានថ្មីៗនេះស្រាប់ សំរង្សី (កូនរបស់ សំសារីអតីតមេខ្មែរអ៊ីសារ៉ាក់ប្រឆាំងនិងរបបដើមរបស់សម្តេចនរោត្តមសីហានុ) ជាអ្នកដឹក នាំគណៈបក្សនយោបាយសំរង្សី ប្រឆាំងនិង គណៈបក្សហ៊ុនសែនប្រជាជនកម្ពុជា **Cambodian People's Party (CPP party)** និង សុនសាន ហើយនិងកូនៗ សុនស៊ូប៉ែ និង សុនមូនារ របស់គណៈបក្សប្រជាជនខ្មែររណ្តោះជាតិ **Khmer People's National Liberation Front (KPNLF) party**

អ្នកទាំងនេះត្រូវរត់ចោលប្រទេសរត់ទៅនៅជ្រកកោនឯប្រទេសក្រៅ។ ហ៊ុនសែន ជាមេដឹកនាំសកម្មរបស់ប្រទេសខ្មែរដែលបានកាន់អំណាច យូរជាងមេដឹកនាំឯទៀតៗក្នុងប្រទេស ៣៤ឆ្នាំ (ពីឆ្នាំ១៩៧៩ ដល់សម័យ ឥឡូវ ២០១៣-នៅរាប់ទៅមុខទៀត) យូរជាងសម្តេចនរោត្តមសីហនុ (១៩៥៣-១៩៧០)។ នៅខែមករាឆ្នាំ២០១៣ ប្រធាធិបតី បារ៉ាក់អូបាម៉ា របស់សហរដ្ឋអាមេរិក បានទៅធ្វើទស្សនៈកិច្ចនៅប្រទេសអាស៊ី ហើយបានធ្វើការឈប់នៅប្រទេសខ្មែរ។ លោកប្រធានាធិបតី ស្នើរឲ្យហ៊ុនសែន បន្ធូររឿងមនុស្សធម៏ បើប្រទេសខ្មែរ នៅតែចង់បាន ជំនួយអំពីប្រទេសសហរដ្ឋថែម ហើយច្រើនតទៅទៀត ហ៊ុនសែនត្រូវតែ អនុញ្ញាតិឲ្យមានគណៈបក្ស ប្រជាធិបតេយ្យបោះឆ្នោត ប្រគួតប្រជែង ក្នុងប្រទេស។ យើងទាំងឡាយ និងរង់ចាំនៅមើលបើកភ្នែកដល់អនាគត។

ហ៊ុនសែន (កើតនៅថ្ងៃទី៥ខែសីហាឆ្នាំ១៩៥២) ជានាយករដ្ឋមន្ត្រី ប្រទេសខ្មែរ មេដឹកនាំគណៈបក្សប្រជាជន ដែលកាន់កាប់ប្រទេសខ្មែរតាំង ពីយួនរំលំរបបប៉ុលពតឆ្នាំ១៩៧៩។ ចាប់តាំងពីពេលអនុញ្ញាតិឲ្យមាន គណៈបក្សប្រជាធិបតេយ្យឈរឈ្មោះ ឆ្នាំ១៩៩៣ មានតែគណៈបក្សពីរ ដែលកាន់ដំណែង គណៈបក្សប្រជាជន **CPP** និងគណៈបក្សរាជានិយម ប្រជាជាតិរួមសំរាប់ ឯករាជ្យ អាជ្ញាកណ្តាល សន្តិភាព និង សង្គមនិយម **FUNCINPEC** ដែលមានឈ្មោះអំពីអក្សរបារាំងថា ***Front Uni National pour un Cambodge Indépendant, Neutre, Pacifique, et Coopératif*** *ឬជាភាសាអង់គ្លេសថា* **"National United Front for an Independent, Neutral, Peaceful, and Cooperative Cambodia."**

## ***ចលនាអាជីពនយោបាយរបស់ ហ៊ុនសែន***

ហ៊ុនសែន ធ្លាប់បានកាន់អំណាចជាមួយខ្មែរក្រហម កាន់កាប់មេទ័ពកងពល តូចដំបន់ខាងកើតប្រទេសឲ្យរដ្ឋាភិបាលខ្មែរក្រហម ប្រជាធិបតេយ្យកម្ពុជា **Democratic Kampuchea** (ឈ្មោះដែលរដ្ឋាភិបាលខ្មែរក្រហមហៅប្រទេសខ្មែរ)។ នៅឆ្នាំ១៩៧៧ ពេលដែលរបបខ្មែរក្រហមធ្វើការសម្លាប់សំអាតផ្ទៃក្នុង ហ៊ុនសែននិងមេកងកងពលតូចរត់ទៅជ្រកកោននៅស្រុកយួន។ ហ៊ុនសែន ត្រូវបានឡើងជាមេដឹកនាំកងទ័ពបះបោរដែលយួនរៀបចំរដ្ឋាភិបាលឲ្យមានស្រេច មុននិងវាយលុកលុយយកប្រទេសខ្មែរ។ ក្រោយពីយួនកំចាត់របបខ្មែរក្រហម ហ៊ុនសែន ត្រូវយួនចាត់ តាំងឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់រដ្ឋាភិបាលតុក្កតាដែលយួនបង្កើតឡើង ហៅរដ្ឋាភិបាល ប្រជាជនសាធារណៈកម្ពុជា/រដ្ឋកម្ពុជា **<u>People's Republic of Kampuchea/State of Cambodia</u>** **(PRK/SOC)** នៅឆ្នាំ១៩៧៩ ហើយឆ្នាំ១៩៨៥ ត្រូវបានតាំងជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី រួចហើយជា នាយករដ្ឋមន្ត្រី ក្រោយពីនាយកប្រធាន ចាន់ស៊ី ស្លាប់ ឆ្នាំ១៩៩០ (គឺមានចន្លោះមិនតាំង ពីឆ្នាំ១៩៨៦ ដល់១៩៨៧)។ ក្នុងមុខដំណែងជារដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ុនសែន មានមុខងារសំខាន់ណាស់ក្នុងការជជែករកសន្តិភាពឲ្យប្រទេសខ្មែរនៅ ប៉ារីស។ ពេលនោះសម្តេចនរោត្តមស៊ីហនុ ហៅ ហ៊ុនសែន ថា "អាភ្នែក១កញ្ជះបាវព្រាវយួន"។

នៅឆ្នាំ១៩៨៧ អង្គការលើកលែងទោសអន្តរជាតិ ចោទរដ្ឋាភិបាល ហ៊ុនសែន ថាមានធ្វើទារុណកម្មដល់មនុស្សរាប់ពាន់ដែលជាអ្នកទោស

នយោបាយ ដោយប្រើ "ខ្មែរភ្លើងឆក់ ដែកដុត និង ថង់ផ្លាស្ទីកបញ្ច្រកឲ្យដាច់ដង្ហើម"។

នៅចប់ឆ្នាំ១៩៨៩ សង្គ្រាមត្រជាក់រវាងបស្ចឹមប្រទេស (សហរដ្ឋអាមេរិក) និង បូព៌ាប្រទេស (សហភាពសូវៀត) ត្រូវចប់។ ប្រទេសសហភាពសូវៀតឈប់គាំទ្រប្រទេសវៀតណាមជាថវិការ ជាលទ្ធផលវៀតណាមដកទ័ពចេញពីប្រទេសខ្មែរ។

ការដកថយរបស់វៀតណាមនេះ ធ្វើឲ្យមានការលំបាកខ្លាំងដល់ហ៊ុនសែនជានាយករដ្ឋមន្ត្រីប្រទេសខ្មែរ។ កងទ័ពខ្មែរក្រហមមិនទាន់រលាយ ហើយកំញើញរដ្ឋាភិបាលជានិច្ច។

នៅឆ្នាំ១៩៩១ អង្គការសហប្រជាជាតិ ប្រទេសកម្ពុជា និង គណៈបក្សដែលមានទាក់ទងនិងប្រទេសខ្មែរ មានសេចក្តីសំរេចចិត្តថានិងបញ្ឈប់ជម្លោះនៅប្រទេសខ្មែរ គេបង្កើតអង្គការ អ៊ុនតាក់ **UNTAC (United Nations Transitional Authority)** និង **SNC (Supreme National Council)** ដែលមានសមាជិកមកពីគ្រប់ផ្នែកគ្រប់គណៈបក្សក្នុងប្រទេសកម្ពុជា។ ការព្រមព្រាងនៅ ប៉ារីស ដែលមានអង្គការសហប្រជាជាតិជាអ្នកចាត់ចែង បង្កើតឲ្យមានការប្រគួតប្រជែងគណៈបក្សនយោបាយ១យ៉ាងធំនៅ ប្រទេសកម្ពុជា ដែលគេមិនដែលឃើញក្នុងកំឡុង៤០ឆ្នាំ។

នៅខែឧសភាឆ្នាំ១៩៩៣ អង្គការ **UNTAC** រៀបចំការបោះឆ្នោត១ឲ្យរើសរដ្ឋសភាជាតិ ដើម្បីដូររដ្ឋាភិបាលទាហានរបស់ហ៊ុនសែន។ ប្រជារាស្ត្រខ្មែរបោះឆ្នោតចង់បានរបបរាជានិយម គណៈបក្ស **FUNCINPEC** ឈ្នះ ប៉ុន្តែហ៊ុនសែន មិនព្រមលាលែងដំណែង។ សំណាងដែរ មានការព្រមព្រាងមួយកើតឡើង គឺបង្កើតរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រី២ នាយករដ្ឋ

មន្ត្រីទី១មកអំពី FUNCINPEC ដែលមាន ទ្រង់ រណ្ណារិទ្ធ នាយករដ្ឋមន្ត្រីទី២ គឺហ៊ុនសែន។

ឈ្មោះដូរដល់ប្រទេសខ្មែរមានឡើងនៅឆ្នាំ១៩៩៣ប្រទេសខ្មែរក្លាយទៅជារាជាណាចក្រហើយសម្ដេចនរោត្តមស៊ីហានុបានឡើងសោយរាជ្យជារាជាម្ដងទៀត ក្រោយពីរដ្ឋធម្មនុញ្ញដែលដូរទៅជារបបរាជាធិតេយ្យ។ ក្រោយពីការដូរនេះ អង្គការសហប្រជាជាតិ មិនទទួលស្គាល់របបខ្មែរក្រហម Democratic Kampuchea (DK) ទៀតទេ។ ខ្មែរក្រហម DK ក៏បាត់កៅអីនៅអង្គការសហប្រជាជាតិពីថ្ងៃនោះមក។

ហ៊ុនសែនមានចិត្តក្លាហានឥតខ្មាស់ឥតកោតញញើត ពេលដែល អង្គការសហប្រជា ជាតិរៀបចំត្រួតត្រាបោះឆ្នោតឲ្យមានយុត្តិធម៌ ពេលខ្លួនឯងចាញ់ឆ្នោតមិនព្រមឲ្យអ្នកឈ្នះៗ ទទូចឲ្យខ្លួននៅតែធ្វើ នាយករដ្ឋមន្ត្រី-ចែកហើយនៅជា ប្រធានគណៈបក្ស CPP ដដែល។ ពីឆ្នាំ១៩៩៣ ដល់ ១៩៩៨ ហ៊ុនសែន ធ្វើជានាយករដ្ឋមន្ត្រី-ចែកដណ្ដើម អំពី អម្ចាស់ នរោត្តម រណ្ណារិទ្ធ។ នៅឆ្នាំ ១៩៩៧ មានការមិនស្របគ្នា១។ ទ្រង់ រណ្ណារិទ្ធ FUNCINPEC ជជីករក ជំនួយ ពីបក្សពួកខ្មែរក្រហម ដែលនៅតែស្អប់ខ្ពើមរបបលក់ខ្លួនឲ្យយួនរបស់ហ៊ុនសែន ចង់ស្រូបយកខ្មែរក្រហមចូលជាមួយជួយការពារ។

ជាចម្លើយ ហ៊ុនសែន ធ្វើរដ្ឋប្រហារឆ្នាំ១៩៩៧មួយ 1997 Cambodian Coup ប្ដូរ ទ្រង់ រណ្ណារិទ្ធ ដាក់ អ៊ុងហួត ជារដ្ឋមន្ត្រីទី១ ហើយខ្លួនឯងជារដ្ឋមន្ត្រីទី២ រហូតដល់ គណៈបក្ស CPP មានជ័យជំនះបោះឆ្នោតឆ្នាំ១៩៩៨ ហើយខ្លួនឯងឡើងកាន់ជា នាយករដ្ឋមន្ត្រីតែម្នាក់ឯង។ នៅពេលឆ្នាំនេះពួកសាពត៌មាន ចុះផ្សាយថា ហ៊ុនសែន ជាមនុស្សមានអំណាចឥទ្ធិពលលើសគេនៅស្រុកខ្មែរ ហ៊ុនសែនខ្លួនឯងឆ្លើយថាមិនទាន់ទេ រួចហើយនៅខែ

កក្កដាឆ្នាំ១៩៩៧ ចាប់សម្លាប់បោសសំអាតកងទ័ពដែលនាំចូលដោយទ្រង់រណ្ណារិទ្ធ ដែលបានមកនៅទីក្រុងភ្នំពេញ។

នៅក្នុងសំបុត្រចើកចំហរ អង្គការលើកលែងទោសអន្តរជាតិ ចោទប្រកាន់រដ្ឋាភិបាលហ៊ុនសែនដែល ធ្វើឃាតដល់រដ្ឋមន្ត្រី គណៈបក្ស **FUNCINPEC** "ចោទពីបទធ្វើឃោសនាចាប់ចង និង កំញើញដល់គណៈបក្សនយោបាយដែលប្រគួតប្រជែង "ជាមួយគណៈបក្សខ្លួន។

ការបោះឆ្នោតនៅខែកក្កដាឆ្នាំ២០០៣ គណៈបក្សហ៊ុនសែន **CPP** ឈ្នះឆ្នោតជាភាគច្រើននៅរដ្ឋសភា ដោយចាញ់ឆ្នោតខ្លះទៅ គណៈបក្ស **FUNCINPEC** និងគណៈបក្ស សំរង្ស៊ី **Sam Rainsy Party**។ ប៉ុន្តែគណៈបក្ស **CPP** មិនបានឈ្នះឆ្នោត២ភាគ៣ ដែលតម្រូវដោយរដ្ឋធម្មនុញ្ញឲ្យតែងតាំងរដ្ឋាភិបាលតែម្នាក់ឯងបាន។ ដើម្បីឲ្យដោះស្រាយបានចំពោះការទាល់ច្រកនេះ ចលនាបង្រួបបង្រួម **CPP-FUNCINPEC** បង្កើតឡើងពេល ពាក់កណ្តាលឆ្នាំ២០០៤ គឺ ទ្រង់រណ្ណារិទ្ធ កាន់ជាប្រធានរដ្ឋសភា ហើយ ហ៊ុនសែនកាន់ជានាយករដ្ឋមន្ត្រីតែម្នាក់ឯងគត់។ ហ៊ុនសែនឈ្នះជានិច្ច។

## *ការពុករលួយក្នុងរបប*

រដ្ឋាភិបាលហ៊ុនសែនមានការធានាខុសត្រូវ១ក្នុងការលក់ដី ឲ្យទៅអ្នករកស៊ីបរទេស នៅឆ្នាំ២០០៧-២០០៨ ដែលជាលទ្ធផលមានការបណ្តេញចេញពីលំនៅដល់មនុស្សរាប់ពាន់នាក់។

ក្នុងសេចក្តីរាយការណ៏ឆ្នាំ២០០៩ របស់ គ្លូប្បាលវីតណែសស្ស ហ៊ុនសែនមានទាក់ទងនិងការពុករលួយលក់អណ្តូងប្រេងកាត និង អណ្តូងរ៉ែ ដែលជារបស់រដ្ឋ (Global Witness គឺជាអង្គការអន្តរជាតិ **NGO** "Non-governmental organizations" មិនទាក់ទងនិង រដ្ឋាភិបាលណា១ បង្កើតឡើងនៅឆ្នាំ១៩៩៣ ធ្វើការរកហេតុផលក្នុងការ ចំរាញ់និងជំរិតយកផលពីជម្លោះអ្វី១ ពីការក្រលំបាក ដោយធ្វើអំពើពុក រលួយ និង រំលោភសទ្ធិមនុស្សក្នុងសកលលោក។ អង្គការនេះមានប៉ុយរូ នៅទីក្រុង ឡុង និង វ៉ាស្ទីងតុនឌីស៊ី)។ អង្គការនេះចោទថាហ៊ុនសែននិង បក្សពួក ដឹកនាំការចរចារជាសម្ងាត់ជា១ក្រុមហ៊ុនបរទេស យកប្រាក់ជាមុន ដើម្បីឲ្យមានសិទ្ធិនិងជីករកធនធានក្នុងដីរដ្ឋ។

នៅឆ្នាំ២០១២ រដ្ឋមន្ត្រីរបស់ហ៊ុនសែន ចាប់ចងនាងស្រីគ្មានទោសពៃ២នាក់ ឈ្មោះ យមបូផា និង ទឹមសាក់មូនី ដែលតវ៉ាប្រឆាំងជំទាស់ការរឹបអូស យកទឹកដីនៅបឹងកក់ជាមួយអ្នកតវ៉ាឯទៀត។ នាងស្រីទាំ២ត្រូវរដ្ឋចោទអំពី រឿងដ៏ទៃក្រៅពីតវ៉ា។

សាពត៌មាន នូវយ៉កថៃម ចុះផ្សាយដូចតទៅ: រដ្ឋាភិបាលហ៊ុនសែន មានឈ្មោះល្បី ខាងពុករលួយ សាហាវមិនយោគយល់ដល់អ្នក នយោបាយផ្សេងៗ និង ចាប់លេបយកដីធ្លីគេឯងឥតប្រណី។ មានរឿងដែលទើបកើតឡើងថ្មីៗនេះ គេធ្វើឃាតអ្នកបរិស្ថានវិទូ (environmentalist) ឈ្មោះជុតវុទ្ធី និង ចាប់ដាក់គុកស្ត្រី១៣នាក់ ដែលតវ៉ាប្រឆាំងនិងការលេបយកដីធ្លីនៅរដ្ឋធានីភ្នំពេញ។

......ហ៊ុនសែនជាអតីតកងឈ្លបខ្មែរក្រហមជាមនុស្សឆ្លាតកន្ទុយខ្មៀន ក្បត់ពីរបបដើម ឡើងកាន់អំណាចបានរយៈ៣៨ឆ្នាំមកហើយ។ អ្នកបស្នឹមប្រទេស ទិទៀនរដ្ឋាភិបាលហ៊ុនសែនអំពីអំពើអមនុស្សធម៏ៈ អ្នកប្រឆាំងតវ៉ា និងអ្នកទិទៀន ត្រូវបាញ់សម្លាប់ អ្នកដែលមានគំនិតខ្ពស់ប្រឆាំង ត្រូវចោទដោយមួលបង្កាច់ដាក់ទោសធ្ងន់ៗ និងបណ្ដេញឲ្យរត់ចោលស្រុក។ នេះជាជំហានដែលហ៊ុនសែនដើរ បង្កើតវប្បធម៏ថ្មីឲ្យសង្គមខ្មែរ ក្នុងរបៀបជាអ្នកក្ដាប់អំណាច។

ដើម្បីលើកដំកើងកិត្តិនាមខ្លួនផ្ទាល់ ហ៊ុនសែន ចាប់តម្លើងឲ្យសក្តិធំៗដល់អ្នកជើងនិយាយកំប្លែងជានាយទាហាន ជាអង្គរក្សរបស់ខ្លួនឲ្យនិយាយរឿងសើចល្អៗអំពីហ៊ុនសែននិងគណៈបក្ស។ សឹងគ្រប់តែសាលារៀនថ្មីៗ ស្ពាន ផ្លូវថ្នល់ដែលទើបនិងសង់ឬជួសជុលត្រូវដាក់ឈ្មោះជាហ៊ុនសែន ឬប៊ុនរានី។ ប៊ុនរានី ជា ភរិយារបស់ហ៊ុនសែន។

ហ៊ុនសែននិងញាតិមិត្តតម្រូវឲ្យមានឈ្មោះហៅជាឋានៈសម្តេច ដូរឈ្មោះទៅជាកំណើតពាក្យសំស្រ្កឹត។ ហ៊ុនសែនឥឡូវមានឈ្មោះជាសម្តេចឯក្កោមហាសេនាបតីតេជោ មានន័យជា ស្តេចល្បីល្បាញជាមហាជនមានបរមីជាអ្នកការពារ ជាអ្នកជើងឯកចំបាំងដ៏ឆ្នើម។ ឬហៅថា តេជោ ជាពាក្យខ្លី។

សេចក្តីរាយការណ៏ បរិយាយយ៉ាងក្បោះក្បាយអំពីការកាប់ព្រៃឈើរបស់ក្រុមហ៊ុនខុសច្បាប់ –ហៅ ក្រុមហ៊ុនសេងគៀង ដែលទទួលបញ្ជាពីហ៊ុនសែន រដ្ឋមន្ត្រីកសិកម្ម រដ្ឋមន្ត្រីនេសាទនិងព្រៃឈើ ចាន់សារុន និងនាយកទូរទៅនៃការកាប់ព្រៃឈើឈ្មោះ ទីសុខុម។

អ្នកទាំងនេះនៃអង្គការនេះជាកម្លាំងបើកបរពីក្រោយការកាប់ព្រៃឈើរង្កាល

ដោយខុសច្បាប់នៅដំបន់ខាងត្បូង-ខាងកើត (អាគ្នេយ៍)នៃប្រទេសខ្មែរ ហៅថា ព្រៃលង់។ នៅក្រោមអំណាចរដ្ឋាភិបាលត្រួតត្រាមើលដាំ-លក់ចេញចំការកៅស៊ូ មានការលក់ព្រៃឈើកាប់ខុសច្បាប់ដែលមាន ប្រាក់ចូល ១៣លានដុល្លាក្នុង១ឆ្នាំ។ មានការខាតបង់ដល់រាប់រយឬពាន់ គ្រួសារខ្មែរដែលរស់នៅដំបន់នេះរកស៊ីរស់នៅដោយដើមត្រពាំងបាយជូរ។ សេចក្តីរាយការណ៏ក៏មានបង្ហាញអំពីអំណាចរបស់អង្គការខុសច្បាប់នេះ មិនតែមិនបង់ពន្ធដល់រដ្ឋការ មានការជំរត់មនុស្ស សូកប៉ាន់ និង សម្លាប់មនុស្សទៀតផង។

ការកាប់ព្រៃឈើខុសច្បាប់ទាំងនេះមិនត្រឹមតែបំពេញហោប៉ៅអ្នកមេធំៗទេ ក៏ជាថវិការចិញ្ចឹមទ័ពផ្ទាល់ខ្លួនរបស់ហ៊ុនសែន កងពលតូចលេខ៧០ដែលមានពល ៦០០០នាក់។ កងពលនេះមានសកម្មភាពទូរទៅក្នុងប្រទេស រត់ពន្ធ លក់ព្រៃឈើ ផ្តល់ម្ហូបចំណី ដល់មហាសេដ្ឋីៗ ដែលមានប្រាក់ចូល ពី ២លានដុល្លា ទៅ ២.៧៥លានដុល្លាក្នុង១ឆ្នាំ។ ១ភាគធំនៃប្រាក់ចំណូលនេះចូលទៅដៃលោកមេបញ្ជាការអង្គរក្សការពារ របស់នាយករដ្ឋមន្ត្រីហ៊ុនសែន គឺលោក ផ្កាយ២ ហ៊ីងប៊ុនហ៊ាង។

ថ្វីបើមានភស្តុតាង អំពើខុសច្បាប់និងអមនុស្សធម៏ ដោយកងទ័ព រដ្ឋាភិបាលខ្មែរ ប្រទេសបរទេសជាពិសេសសហរដ្ឋអាមេរិកនៅតែឲ្យជំនួយកងទ័ពដល់រដ្ឋាភិបាលហ៊ុនសែន។

"បើប្រទេសបរទេសដែលជាអ្នកឲ្យជំនួយដល់ប្រទេសខ្មែរ ចង់ឲ្យធនធានប្រទេសខ្មែរបានលទ្ធផលដល់ប្រជាជនខ្មែរ គេត្រូវតែឃ្លាំមើលការពារ កុំឲ្យអង្គការដូចជាក្រុមហ៊ុន សេងគៀង និង កងពលតូចលេខ៧០

ចាត់ការដូចសព្វថ្ងៃ" អះអាងអ្នករាយការណ៍ ឋេលរ័។ "យ៉ាងតិចណាស់ គេត្រូវតែតភ្ជាប់ជំនួយទាំងឡាយដែលមិនជាជំនួយមនុស្សធម៌ទៅនិង សកម្មភាពរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ។ គេអាចទទូចសុំឲ្យ រដ្ឋាភិបាលបោះឆ្នោតច្បាប់ប្រឆាំងនិងអំពើពុករលួយឲ្យចេញរួច ដែល រដ្ឋាភិបាលសព្វថ្ងៃ ពន្យាពេលអស់រយៈជាច្រើន១០-២០ ឆ្នាំមកហើយ - ច្បាប់នេះត្រូវតែចេញភ្លាមៗនេះ"។

"នៅក្នុងពេលមិនយូរឆ្នាំនេះ ប្រទេសខ្មែរនិងកើតឡើងជាប្រទេសដែល ផលិតផលប្រេងកាត" និយាយបន្ថែមលោក ឋេលរ័។ "គឺមិនទាន់យឺតទេ ដែលប្រទេសឲ្យជំនួយ ទទូចឲ្យរដ្ឋាភិបាល ធ្វើគម្រោងការជាមុន រៀបចំគ្រឹស្តចាត់ការស្អាតស្អំ សំរាប់ប្រទេសជាតិ។ បើមិនដូច្នេះទេ ប្រាក់ រាប់កោដិមកអំពីប្រេងកាត និង ហូរចូលហោប៉ៅ អ្នកដឹកនាំពុករលួយ និងបក្សពួកគេ"។

## ប្រវត្តិសាស្ត្រគណៈបក្ស

---

**<u>អង្គការដែលមានពីមុនៗ(គណៈបក្សជា១ខ្មែរក្រហម ដូរឈ្មោះ-មនុស្ស១៩៧៩)</u>**

ដើមកំណើតគណៈបក្ស ប្រជាជនបដិវត្តន៏កម្ពុជា **<u>Kampuchean People's Revolutionary Party</u> (KPRP)** បង្កើតឡើងនៅពេលរបប អាណានិគម បារាំង ខែកញ្ញាឆ្នាំ១៩៥១ ពេលដែល ហូជីមិញ លប់ឈ្មោះអង្គការ គណៈបក្សកុម្មុយនីស្តឥណ្ឌូចិន **Indochinese Communist Party (ICP)** ដែលគាត់បង្កើតពីឆ្នាំ១៩៣០ ហើយបង្កើតជាថ្មី គណៈបក្ស៣ប្រទេស យួន ខ្មែរ និង លាវ មុនពីប្រទេសទាំង៣

បានឯករាជ្យពីបារាំងៈ គណៈបក្សខ្មែរ **KPRP** គណៈបក្សយួន **<u>Vietnam Workers' Party</u>** និងគណៈបក្សលាវ **<u>Lao Itsala</u>** ។

ឈ្មោះរបស់គណៈបក្សខ្មែរដូរទៅ **WPK <u>Workers' Party of Kampuchea</u>** នៅឆ្នាំ១៩៦០ រួចហើយដូរទៅ **KCP <u>Kampuchean (or Khmer) Communist Party</u>** នៅឆ្នាំ១៩៦៦។

នាយកលេខាធិការរបស់គណៈបក្សពីឆ្នាំ១៩៧៩ ដល់ ថ្ងៃទី៥ខែធ្នូឆ្នាំ១៩៨១ គឺ ប៉ែនសូវ៉ាន់។ គណៈបក្ស **KPRP** ពីដើមជា ម៉ាកស៊ីស្ត-ឡេនីននីស្ត ប៉ុន្តែមានការប្តូររូបរាងនៅពាក់កណ្តាលឆ្នាំ១៩៨០ឡើងក្រោមការដឹកនាំរបស់ ហេងសំរិន។ នៅឆ្នាំ១៩៩០ឡើង **KPRP** ជាផ្លូវការទម្លាក់ចោលមនោគមវិជ្ជា ម៉ាកស៊ីស្ត-ឡេនីននីស្ត ដូរឈ្មោះជាផ្លូវការ គណៈបក្សប្រជាជនកម្ពុជា **<u>Cambodian People's Party</u> CPP**។ អ្វីៗដែលមានមកពីគណៈបក្ស **KPRP** ជំនាន់មុននៅ ដដែល។ គណៈបក្សមានសមាជិក៣៤នាក់ ជាអ្នកកណ្តាលគណៈកម្មការប្រតិបត្តិ ដែលគេហៅថា អ្នកកាន់កាប់ការិយាល័យនយោបាយចំរុះ។ សម័យឥឡូវនេះគណៈបក្សមានសិទ្ធិឈ្នះជាភាគច្រើននៅ រដ្ឋសភា និង ព្រឹទ្ធសភា ប៉ុន្តែចែកអំណាចជា១ គណៈបក្សរាជានិយម **FUNCINPEC**។

## <u>គណៈបក្សសភាលើកទី៣ៈ អ្នកដឹកនាំ ប៉ែនសូវ៉ាន់ (១៩៧៩-១៩៨១)</u>

គណៈកម្មការជាតិដឹកនាំដោយ ប៉ែនសូវ៉ាន់ និង រស់សាម៉ៃ បាន តែងតាំងឡើងដោយសភាគណៈបក្ស។ អង្គការចាត់ទុកខ្លួនឯងជាអ្នកតពូជពង្សអំពីគណៈបក្សដើម **KPRP** ដែល កើតនៅឆ្នាំ១៩៥១ (ហើយក្រោយមក

ដូរទៅ CPK) ចាប់រាប់ការជំនុំនេះជា "សភាលើកទី៣" ទាត់ចោលមិនទទួលស្គាល់សភាមុនដូចជា សភាឆ្នាំ ១៩៦៣, ១៩៧៥ និង សភាឆ្នាំ១៩៧៨។ គណៈបក្ស ប្រកាសថា ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ១៩៥១ ជាថ្ងៃកើតឡើង។

## គណៈបក្សសភាលើកទី៤: ការដូរឧបាយយុទ្ធសាស្ត្រ (១៩៨១)

នៅក្នុងនយោបាយរាយការណ៍របស់ ប៉ែនសូវ៉ាន់ ទៅគណៈបក្សសភាលើកទី៤ រៀបចំនៅថ្ងៃទី២៦-២៩ខែឧសភាឆ្នាំ១៩៨១ គេបានធ្វើជន្លាសខ្លួនឲ្យឆ្ងាយពី KPRP អំពីប៉ុលពត CPK ហើយចោទ CPK ជាអ្នកក្បត់ដល់គណៈបក្ស និង ប្រទេសជាតិ។

សភាដែលមានប្រតិភូអ្នកដំណាង ១៦២នាក់ បោះឆ្នោតរើសគណៈបក្សកម្មការកណ្តាល ២១នាក់ អ្នកទាំងនេះបោះឆ្នោតរើស ប៉ែនសូវ៉ាន់ ជានាយកលេខាធិការ និង សមាជិក ៧នាក់ ជាអ្នកផ្ទៃក្នុងៗរង្វង់សំរាប់ការិយាល័យនយោបាយ។

## ហេងសំរិន មេដឹកនាំ

គណៈបក្ស KPRP និយម-យួនមិនដូរឥរិយាបថសោះ ប៉ុន្តែ ហេងសំរិនស្រាប់តែ ប្តូរ ប៉ែនសូវ៉ាន់ ជាអ្នកដឹកនាំគណៈបក្ស នៅថ្ងៃ៤ខែធ្នូឆ្នាំ១៩៨១។ ប៉ែនសូវ៉ាន់ ត្រូវគេរាយការណ៍ថានិង "ឲ្យទៅសំរាកយ៉ាងយូរ" ត្រូវបណ្តើរដោយទាហានយួន ជិះកប៉ាល់ហោះទៅហាណូយ។ អ្នកសង្កេតការណ៍ ជឿជាក់ថា យួនសម្លាប់ ពីព្រោះប៉ែនសូវ៉ាន់មិនគិតដល់ប្រយោជន៏យួនជាធំ។

## គណៈបក្សសភាលើកទី៥: ហេងសំរិនមេដឹកនាំ (១៩៨១–និន្យូច)

គណៈបក្សរៀចំសភាសមាជលើកទី៥ពីថ្ងៃទី១៣ខែតុលាដល់ថ្ងៃទី១៦ឆ្នាំ១៩៨៥ ដេម្បីរំលឹកពី៥ឆ្នាំកន្លងនិងរៀបចំផែនការសំរាប់ថ្ងៃមុខ។ មានសមាជិកចូលរួមថ្មីជាច្រើនឡើងដល់ទៅ ៧,៥០០ នាក់ (៤,០០០នាក់ទើបតែចូល ក្នុងឆ្នាំ១៩៨៥តែ១ឆ្នាំ)។ គណៈបក្សមានមនុស្ស ៣៧,០០០ នាក់ក្នុងអាងក្រុម ដែលអាចរើសយកឲ្យធ្វើជាសមាជិកពេញទីបាន។ នៅពាក់កណ្តាលឆ្នាំ១៩៨១ មានសមាជិកជាស្នូលតែ ៤,០០០នាក់។ បើតាមសេចក្តីរាយការណ៏របស់នាយកលេខាធិការ ហេងសំរិន **KPRP** មានគណៈកម្មការដំបន់២២ ដែលមានសាខាតៗទៅទៀត មានរង្វង់ មានក្រុមតូចៗនៅក្នុងភ្នាក់ងាររដ្ឋាភិបាល មានទ័ពកាន់អាវុធ អ្នកកាន់សន្តិសុខផ្ទៃក្នុង អ្នកកែណ្ឌប្រជាជន មានសហគ្រាស មានរោងចក្រ និងដីស្រែចំការ។



## គណៈបក្សប្រជាជន ផ្លាកឈ្មោះឆ្នោតឆ្នាំ២០០៨

សេចក្តីរាយការណ៏របស់ហេងសំរិនក៏បានធ្វើការសង្កត់ទៅលើកិច្ចការ

បរទេសដែរ។ គេស្នើរឲ្យប្រទេសខ្មែរធ្វើការទាក់ទងជិតដិតថែមទៀត ជាមួយ វៀតណាម។ ហេងសំរិនចង់និយាយអំពីការអនុញ្ញាតិឲ្យចូល មកតាំងទីលំ នៅៗលើទឹកដីខ្មែររបស់ប្រជាជនយួនដែលគេប្រកាសថាមាន ៦០,០០០ នាក់។ ប៉ុន្តែបើតាមពិតតាមការរាយការណ៏របស់រដ្ឋភិបាល **The Coalition Government of Democratic Kampuchea CGDK** (រដ្ឋាភិបាលចំរុះ ដែលមានខ្មែរក្រហម, សុនសាន **KPNLF** និង **FUNCIPEC**) សរសេរថាមាន ប្រជាជនយួន ៧០០,០០០ នាក់ចូលមកនៅ ឆ្នាំ១៩៨២។ យើងត្រូវគិតមើលតើឥឡូវមានយួនប៉ុន្មាន លាននាក់ មករស់នៅ ៣១ឆ្នាំក្រោយមកៗដល់សម័យនេះ (២០១៣)។

សមាជិកគណៈកម្មការចំរុះ (ឆ្នាំ១៩៩០) មាន: ហេងសំរិន (នាយកលេខាធិការ), ជាស៊ីម, ហ៊ុនសែន, ជាសុទ្ធ, ម៉ាតលី, ទាបាញ់, ម៉ែនសំអាន, ងួនញៀល, សខេង, ប៊ូថាំង, នីប៉េណា, សៃជុំ និងសមាជិកឆ្លាស ស៊ិងសុង, ស៊ីមកា, ប៉ុលសារឿន។

សមាជិកលេខាធិការ (ឆ្នាំ១៩៩០) មាន: ហេងសំរិន, សៃភុថាំង, ប៊ូថាំង, ម៉ែនសំអាន, សខេង។

## កំណើតគណៈបក្ស ប្រជាជនខ្មែរ (ឆ្នាំ១៩៩១)

នៅឆ្នាំ១៩៩១ គណៈបក្សបានដូរឈ្មោះទៅ គណៈបក្សប្រជាជនខ្មែរ **Cambodian People's Party (CPP)** ពេលដែលអង្គការសហប្រជាជាតិ រៀបចំការព្រមព្រាងសន្តិភាពនៅប្រទេសកម្ពុជា។ ហ៊ុនសែនបានបន្តការ ជោគជ័យឈ្នះឆ្នោតតាំងពីពេលនោះមក។ គេឈ្នះកៅអី៦៤ ក្នុងកៅអី១២៣ នៅពេលបោះឆ្នោតរដ្ឋសភាឆ្នាំ១៩៩៨ ឈ្នះ៧៣កៅអីឆ្នាំ២០០៣

ឈ្នះ៩០កៅអីឆ្នាំ២០០៨ គឺជាការឈ្នះប្រជាប្រិយ៏១យ៉ាងធំ ៥៨% នៅរដ្ឋសភា។ ហើយឈ្នះព្រឹទ្ធសភាឆ្នាំ២០០៦។

សមាជិកធំៗសព្វថ្ងៃមាន:

- ជាស៊ីម **Chea Sim** នាយក
- ហេងសំរិន **Heng Samrin** នាយកជាកិត្តិយស
- ហ៊ុនសែន **Hun Sen** នាយករង
- ហ៊ណាំហុង **Hor Namhong** សមាជិកគណៈកម្មការជាអចិន្ត្រៃយ៏

អ្វីៗបាននឹងនរហើយឥឡូវនេះនៅប្រទេសខ្មែរ (ចំនួនប្រជាជនបានឡើងមកវិញដល់ ១៤.៨ លាននាក់ ដែលបានចុះជំនាន់ សម្លាប់រង្គាល ប៉ុលពតពី៦លាននាក់ដល់ទៅ៨លាននាក់ - ២.២លាននាក់ត្រូវគេសម្លាប់) ដោយហេតុម្យ៉ាងមានការឧបត្ថម្ភ ជំនួយ អំពីប្រទេសក្រៅ។ ដោយសារការចាប់អារម្មណ៏របស់ពិភពលោកចុះថយអំពីរឿងខ្មែរ ជំនួយដល់ប្រទេសខ្មែរក៏ចុះអន់ដែរ នេះធ្វើឲ្យការសង្ឃឹមដល់សេដ្ឋកិច្ចនិងប្រជាធិបតេយ្យ ដុះឡើង ក៏រលត់ទៅដែរ។

តាំងពីឆ្នាំ១៩៩០ ប្រទេសកម្ពុជា ចាប់ផ្តើមលូតលាស់ឡើងវិញ ខាងចំនួនប្រជាជន និង សេដ្ឋកិច្ច អំពីរបបខ្មែរក្រហម ថ្វីបើនៅមានសំណាកស្លាកស្នាមខូចខាតក្នុងមនោគតិខ្លះ ក្នុងគ្រួសារនិងសង្គម១ទៅ១។ គួរឲ្យកត់សំគាល់ជាតម្លៃ១ ប្រជាជនខ្មែរក្មេងៗក្នុងឆ្នាំ២០០៣ មាន៣ភាគ៤នៅក្មេងពេក ហើយមិនទាំងចាំរបបសាហាវខ្មែរក្រហមផង។

ប្រជាជនក្មេងៗជំនាន់នេះស្គាល់ខ្មែរក្រហមតាមតែពាក្យនិយាយអំពីឪពុក-ម្តាយ ឬ មនុស្សចាស់ៗ។ មានកំហុស១ក៏ដោយសាររដ្ឋាភិបាលមិនតម្រូវឲ្យសាលា-គ្រូបង្រៀនអប់រំ អំពីអំពើសាហាវយង់ឃ្នងរបស់របបខ្មែរក្រហម។ ប៉ុន្តែឆ្នាំ២០០៩ ក្រសួងអប់រំជាតិប្រទេសខ្មែរចាប់ផ្តើមបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅសាលាវិទ្យាល័យ។

# ជំពូក ទី៩

# សេចក្ដីសង្ខេប

**ចាប់តាំងពី** សតវត្សទី១ ដល់ សតវត្សទី១២ ប្រទេសខ្មែរដំបូងមាន ឈ្មោះថា ហ្វូណន់ រួចហើយ ខ្មែរ រួចហើយ កម្ពុជា។ ប្រទេសខ្មែររាជាណាចក្រ បានឡើងជាធរាបដល់សតវត្សទី១២ ដែលពិភពលោកស្គាល់ជា សម័យអង្គរ ពេលនោះ អង្គរវត្ត ចាប់កសាងឡើង។ ក្នុងពេលនោះនៅភូមិភាគអាស៊ីអាគ្នេយ៍មានតែប្រទេស៣គត់ គឺ ភូមា (មន), ហ្វូណន់ (ខ្មែរ) និង ចំប៉ា (ចាម)។

-ចាប់តាំងពីសតវត្សទី១៣ឡើង រាជាណាចក្រខ្មែរចាប់ចុះថយ ដោយសារមានសង្គ្រាមទន្ទ្រានមកពីប្រទេសជិតខាង ចាម (ក្រោយមកជាវៀតណាម) អំពីខាងកើត និង ថៃ (ថៃឡង់) អំពីខាងលិច។

ប្រទេសបារាំងមកដល់ប្រទេសអាស៊ីភាគអាគ្នេយ៍ឆ្នាំ១៧៨៩ ហៅដំបន់នេះថា ឥណ្ឌូ-ចិន។ ព្រះរាជាខ្មែរ ព្រះនរោត្តម សុំបារាំងឲ្យជួយការពារប្រទេសអំពីការឈ្លានពានរបស់ប្រទេសជិតខាង ដូច្នេះហើយ អានានិគមស្ថិតក្រោមអាណាព្យាបាលបារាំងក៏កើតមានឡើង។

-ពីឆ្នាំ១៩៥៣-១៩៧០ ប្រទេសកម្ពុជាបានទទួលឯករាជ្យអំពីប្រទេសបារាំង ហើយសម្ដេចព្រះនរោត្តមស៊ីហនុ បានបង្កើតគណៈបក្សនយោបាយ ដែលឈ្នះលប់លើគណៈបក្សនយោបាយឯទៀតៗអស់រយៈ១៧ឆ្នាំ ហៅថា គណៈបក្សនយោបាយ សង្គមរាស្ត្រនិយម។

-របបរាជាណាចក្រត្រូវរំលាយចោលដោយរបបសាធារណៈរដ្ឋក្នុងឆ្នាំ១៩៧០-១៩៧៥ ដោយមានរដ្ឋប្រហារ១ធ្វើឡើងដោយ ឧត្តមសេនីយ លន់ណុល ដែលមានសម្ព័ន្ធមិត្តនិងប្រទេសសហរដ្ឋអាមេរិក បន្តសង្គ្រាមប្រឆាំងខ្មែរក្រហម និង កុម្មុយនីស្តយួនខាងជើង រួមជាមួយយួនខាងត្បូង។

-កងទ័ពខ្មែរក្រហមឈ្នះសង្គ្រាម ត្រួតត្រាប្រទេស ឆ្នាំ១៩៧៥-១៩៧៩ ក្រោយពីកងទ័ពសហរដ្ឋអាមេរិកដកថយអំពីយួនខាងត្បូង និងខ្មែរ។ របប ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរអស់ ២.២លាននាក់ ក្នុងរយៈពេល៥ឆ្នាំ ក្នុងចំណោមប្រជាជន ៦លាននាក់ (គឺ១នាក់ត្រូវសម្លាប់ក្នុងមនុស្ស៣នាក់)។

-ឆ្នាំ១៩៧៩-មកដល់ឥឡូវ ២០១៣: កងទ័ពប្រទេសវៀតណាមលុកលុយប្រទេសកម្ពុជាឆ្នាំ១៩៧៩ បណ្តេញរបបខ្មែរក្រហមចេញពីដំណែង ហើយដាក់តាំងរបបអាយ៉ងតុក្កតា ដែលមាន ហ៊ុនសែន ជាមេ ហៅថា គណៈបក្ស ប្រជាជនបដិវត្តន៏កម្ពុជា **PRPK <u>People's Revolutionary Party of Kampuchea</u> (គណៈបក្សដែលបង្កើត ដោយហូជីមិញ ដែលមានខ្មែរក្រហមនិងហ៊ុនសែនក្នុងនោះ ហើយក្រោយមកមានឈ្មោះជា គណៈបក្សប្រជាជនខ្មែរ <u>Cambodian People's Party CPP</u> ក្រោមការដឹកនាំរបស់ហ៊ុនសែន)។ របបនេះបានកាន់កាប់ប្រទេសខ្មែរតាំងពីឆ្នាំ១៩៧៩ មកដល់សម័យឥឡូវនេះ ២០១៣ (នៅរាប់បន្តទៅទៀត) គឺជាគណៈបក្សដែលកាន់អំណាចយូរជាងគេក្នុងប្រទេសខ្មែរ។**

# សេចក្តីសង្ខេបពី
# គណៈបក្សនយោបាយនៃប្រទេសកម្ពុជាៈ

-ពីសតវត្សទី១ ដល់ សតវត្សទី១៨: រាជាណាចក្រកម្ពុជា។

-ពេលចុងសតវត្សទី១៨ (ឆ្នាំ១៧៨៩) ប្រទេសអាស៊ីភាគអាគ្នេយ៏ (លាវ យួន និង ខ្មែរ) ស្ថិតនៅក្រោមអាណាព្យាបាលអានានិគមបារាំង លើកលែងតែប្រទេសថៃ ពេលនោះនៅជាសម្ព័ន្ធមិត្តរបស់ប្រទេសអង់គ្លេស។ បារាំងត្រួតត្រាប្រទេសខ្មែររហូតដល់ឆ្នាំ១៩៥៣ ប្រទេសខ្មែរបានទទួលឯករាជ្យអំពីប្រទេសបារាំង។

-នៅឆ្នាំ១៩៣០ ហូជីមិញបង្កើតគណៈបក្សកុម្មុយនីស្តឥណ្ឌូចិន <u>**Indochina Communist Party (ICP)**</u> និងគណៈបក្សកុម្មុយនីស្តក្នុងប្រទេសខ្មែរ (មានខ្មែរវៀតមិញ) និងនៅប្រទេសលាវ ធ្វើសង្គ្រាមនិងបារាំងទាមទារឯករាជ្យ។ គណៈបក្សកុម្មុយនីស្តខ្មែរដូរឈ្មោះទៅ ប្រជាជនបដិវត្តន៏កម្ពុជា <u>**Kampuchea (or Khmer) People's Revolutionary Party (KPRP)**</u>។ គណៈបក្ស KPRP នៅសភាសមាជលើកទី២ឆ្នាំ១៩៦០ មាន សាឡុតស (ក្រោយមកដូរទៅ ប៉ុលពត) ហ៊ូនឹម ហ៊ូយន់ អៀងសារី និង ខៀវសំផនដែលជាមេដឹកនាំខ្មែរក្រហម។ គេបានដឹងដែរថា ហ៊ុនសែន និង បក្សពួកគណៈបក្ស សព្វថ្ងៃ CPP មានហេងសំរិន ជាស៊ីម ហ៊ាណាំហុងក៏ធ្លាប់ជាសមាជិករបស់ KPRP ជាមួយមេខ្មែរក្រហមដែរ។ វាខុសគ្នាត្រង់ថាខ្មែរក្រហម ចិន-និយម ឯគណៈបក្ស CPP យួន-និយម លក់ខ្លួនជាខ្ញុំកញ្ជះយួន។

-នៅឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមស៊ីហានុចុះចាកព្រះរាជបល្ល័ង្គ ប្រគល់រាជ្យទៅព្រះបិតា នរោត្តមសុរាមរិទ្ធ ចូលកាន់ធ្វើនយោបាយដែល មានការបោះឆ្នោតជាប្រជាធិបតេយ្យ។ ព្រះអង្គបង្កើតគណៈបក្ស នយោបាយឲ្យឈ្មោះថា សង្គមរាស្ត្រនិយម **<u>the Sangkum Reastr Niyum (Popular Socialist Community)</u>** ឈ្មោះហៅដោយខ្លី សង្គម ថ្មីបើមានឈ្មោះដូច្នេះ សមាជិកភាគច្រើនមកពីខាងស្តាំ (បស្ចឹមប្រទេស-និយម) ដែលប្រឆាំងនិងកុម្មុយនីស្ត។ នៅខែកញ្ញាឆ្នាំ១៩៥៥ គណៈបក្សសម្តេចឈ្នះ គណៈបក្សប្រជាធិនតេយ្យឯទៀតដូច គណៈបក្សខ្មែរឯករាជ្យ **<u>Khmer Independence Party</u>** របស់ សឺងង៉ុកថាញ់ និង សំសារី (គណៈបក្សខាងស្តាំ) និង គណៈបក្សកុម្មុយនីស្តខ្មែរក្រហម (គណៈបក្ស ចិន-និយម) **<u>KPRP</u>** ដែលមានសមាជិកខ្លះរបស់គណៈបក្សសម័យឥឡូវដែរ (គណៈបក្ស យួន-និយម) **<u>CPP</u>**។ សម្តេចស៊ីហានុ កាន់កាប់ប្រទេសកម្ពុជា បំបាត់ចោលអស់ គណៈបក្សប្រឆាំងប្រជែងឯទៀត ដោយចាប់ដាក់គុកឬសម្លាប់ចោល អស់រយៈពេល ១៧ឆ្នាំ (១៩៥៣-១៩៧០)។

-នៅឆ្នាំ១៩៧០-១៩៧៥ មានរដ្ឋប្រហារ១ធ្វើឡើងដោយ ឧត្តមសេនីយ លន់ណុល និង អម្ចាស់ សិរិម៉ាតាក់ បង្កើតជាសាធារណៈរដ្ឋ មានសម្ព័ន្ធមិត្តនិងប្រទេសសហរដ្ឋអាមេរិកនិងយួនខាងត្បូងធ្វើសង្គ្រាម ប្រឆាំងនិងយួនខាងជើង ចិន សហភាពសូវៀត និងអ្នកដណ្តើមអំណាច ផ្ទាល់ ខ្មែរក្រហម។ របបនេះធ្លាក់នៅថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ ពេលដែលប្រធានាធិបតីសហរដ្ឋអាមេរិក ហេរ្យ៉ាល់ហ្វដ និង រដ្ឋសភា និង ព្រឹទ្ធសភា សំរេចចិត្តដកថយកងទ័ពអាមេរិកាំងចេញពីប្រទេស អាស៊ីអាគ្នេយ៍។ ឧត្តមសេនីយលន់ណុល រត់និរទេសខ្លួនទៅរដ្ឋហាវ៉ៃ

ហើយត្រូវស្លាប់នៅថ្ងៃក្រោយមក។ មេៗឧត្តមសេនីយអំពីសាធារណៈរដ្ឋខ្លះរត់និរទេសទៅប្រទេសថៃថ្ងៃក្រោយមកចូលរួមនិងចលនាបង្រួបបង្រួម ហៅថា **FUNCINPEC** របស់ទ្រង់ នរោត្តមរណ្ណារិទ្ធ ដែលជាបុត្ររបស់សម្តេចព្រះនរោត្តមស៊ីហនុ បំរុងនិងចូលមកប្រទេសខ្មែរវិញប្រគួតប្រជែងនិងរបបលក់ខ្លួនឲ្យយួន ហ៊ុនសែន។

-នៅឆ្នាំ១៩៧៥-១៩៧៩: របបជំនាន់ខ្មែរក្រហមដែលមានឈ្មោះចាស់ **The Kampuchea (or Khmer) People's Revolutionary Party (KPRP)**។ គណៈបក្ស **KPRP** សភាសមាជលើទី៣ ដូរឈ្មោះទៅជា ប្រជាធិបតេយ្យកម្ពុជា **Democratic Kampuchea (DK)** កាន់កាប់ប្រទេសកម្ពុជាពីខែមេសាឆ្នាំ១៩៧៥ដល់ខែមករាឆ្នាំ១៩៧៩។ របបត្រូវវាយលុកទម្លាក់ចោលដោយទ័ពយួនដែលមានពួកក្បត់ជាតិខ្មែរពីក្រោយខ្នង។ អ្នកដឹកនាំខ្មែរក្រហមនិងកងទ័ពសែសសល់រត់ទៅនៅៗ បប៉ៃលិន ជាប់ព្រំប្រទល់ប្រទេសថៃ (ដែលមានត្បូងនិងពេជជីកបានដាក់លក់ទៅក្រៅប្រទេស)។ កងទ័ពខ្មែរក្រហមក៏បានចូលដៃជាមួយកងទ័ព **FUNCINPEC** វាយប្រឆាំងនិងទ័ពយួនដែលត្រួតត្រាប្រទេសខ្មែរដែលមានរដ្ឋាភិបាល តុក្កតាយួន ហ៊ុនសែនកាន់កាប់។

-ឆ្នាំ១៩៧៩-មកដល់សម័យឥឡូវ ២០១៣ (នៅមានរាប់តទៅទៀត): កងទ័ពយៀកណាមវាយលុកលុយប្រទេសខ្មែរឆ្នាំ១៩៧៩ កំចាត់របបខ្មែរក្រហម ហើយដាក់តាំងរដ្ឋាភិបាលតុក្កតា ហ៊ុនសែន បង្កើតជាគណៈបក្ស ប្រជាជនកម្ពុជា **Cambodian People's Parnty CPP** ។ គណៈបក្ស **CPP** នៅមានឧត្តមសេនីយជាតិយួនបង្កប់នៅក្នុងកងទ័ពជួយមើលការខុសត្រូវមកដល់សព្វថ្ងៃ ថ្វីបើកងទ័ពយួនដកថយឆ្នាំ១៩៨៩។ នៅឆ្នាំ១៩៨៣ (មានការបោះឆ្នោតរវាង៥ឆ្នាំម្តង) ក្រោមការឧបត្ថម្ភរបស់

អង្គការសហប្រជាជាតិ សង្គ្រាមផ្ទៃក្នុងត្រូវឈប់ ការបោះឆ្នោតទូរទៅចាប់ផ្តើម។ ដោយការភ្ញាក់ផ្អើលរបស់គណៈបក្ស CPP គណៈបក្សទ្រង់រណ្ណារិទ្ធ FUNCINPEC ឈ្នះឆ្នោត ប៉ុន្តែហ៊ុនសែន ជាអ្នកមានអំណាច មានកងទ័ព ប្រកែកមិនព្រមចុះចាញ់ អនុញ្ញាតិឲ្យទ្រង់រណ្ណារិទ្ធឡើងធ្វើជានាយករដ្ឋាភិបាល។ អង្គការសហប្រជាជាតិចរចារឲ្យមាននាយករដ្ឋមន្ត្រី២។ នេះគឺជាការនិយាយកំប្លែង១ តើក្នុងប្រវិត្តិសាស្ត្រពិភពលោកមានប្រទេសណាមាននាយករដ្ឋមន្ត្រី២ទេ ក្នុងការបោះឆ្នោត១ក្នុងប្រទេសតែ១គត់? នៅឆ្នាំ១៩៩៧ បើតាមគណៈបក្ស CPP គេធ្វើរដ្ឋប្រហារ១ទម្លាក់នាយករដ្ឋមន្ត្រីទី១ ទ្រង់រណ្ណារិទ្ធ ដាក់ជំនួសដំណាងពី FUNCINPEC អ៊ុងហួត ដែលជាអ្នក ហ៊ុនសែន-និយម។ នៅឆ្នាំ១៩៩៨បោះឆ្នោត គណៈបក្ស CPP ឈ្នះឆ្នោត ពាក្យចាមអារ៉ាមក្នុងអិនធើរណិតមានគ្រប់ទិស បំបាត់ការរាប់សន្លឹកឆ្នោត ប្តូរប្រអប់សន្លឹកបោះឆ្នោត។ ថ្វីបើដូច្នេះ ហ៊ុនសែន ឡើងជានាយករដ្ឋមន្ត្រីតែម្នាក់ឯង។ នៅឆ្នាំ២០០៣បោះឆ្នោត គណៈបក្ស CPP មិនឈ្នះឆ្នោតជាភាគច្រើន គណៈបក្ស FUNCINPEC, គណៈបក្ស សំរង្ស៊ី (សំរង្ស៊ីជាកូនរបស់ សំសារីដែលជាមេដឹកនាំខ្មែរសេរីជាមួយសឺងង៉ុកថាញ់ គណៈបក្សបស្ចឹមប្រទេស-និយម ប្រឆាំងនិងសម្តេចស៊ីហានុជំនាន់ដើមក្នុងឆ្នាំ១៩៦០ឡើង), និងគណៈបក្ស KPNLF (Khmer People's National Liberation Front) ដែលមានសុនសានជាអ្នកដឹកនាំ ឈ្នះចែកសន្លឹកឆ្នោតរវាងគណៈបក្សទាំង៣។ នេះបង្ខំ ហ៊ុនសែន ឲ្យចរចារឲ្យ រណ្ណារិទ្ធ ធ្វើជាមេរដ្ឋសភា ហើយហ៊ុនសែនខ្លួនឯងឡើងធ្វើជានាយករដ្ឋមន្ត្រី បង្កើតរដ្ឋាភិបាលតែម្នាក់ឯង។ ហ៊ុនសែនឈ្នះជានិច្ច។ នៅពេលសម័យឥឡូវនេះ គ្មានគណៈបក្សណាប្រឆាំងនិងគណៈបក្ស

ហ៊ុនសែនទៀតទេ គណៈបក្សទាំងអស់ត្រូវកំចាត់ចោលប្រទេស។ គណៈបក្ស **CPP** ជាគណៈបក្សតែ១គត់ក្នុងប្រទេសកម្ពុជាសព្វថ្ងៃ។

**កូនឃើញស្រាប់ នយោបាយបំបាត់មិនចេះចប់ ពីព្រោះឈ្នះ គឺជារង្វាន់ជាទីចុងក្រោយ។ នៅខែមករាឆ្នាំ២០១៣ ប្រធាធិបតី បារ៉ាក់អូបាម៉ា របស់សហរដ្ឋអាមេរិក បានទៅធ្វើទស្សនៈកិច្ចនៅប្រទេសអាស៊ី ហើយបានធ្វើការឈប់នៅប្រទេសខ្មែរ។ លោកប្រធានាធិបតី ស្នើរឲ្យហ៊ុនសែន បន្ធូររឿងមនុស្សធម៌ បើប្រទេសខ្មែរ នៅតែចង់បាន ជំនួយអំពីប្រទេសសហរដ្ឋថែម ហើយច្រើនតទៅទៀត ហ៊ុនសែនត្រូវតែ អនុញ្ញាតិឲ្យមានគណៈបក្ស ប្រជាធិបតេយ្យបោះឆ្នោត ប្រគួតប្រជែង ក្នុងប្រទេស។ យើងទាំងឡាយ និងរង់ចាំនៅមើលបើកភ្នែកដល់អនាគត។**

សេចក្តីការពិត ដែលមានសរសេរក្នុងសៀវភៅនេះ បើសៀវភៅនេះ និងត្រូវបានបោះពុម្ពផ្សាយ ប្រហែលមិនអាចឲ្យ ពុក-ម្តាយ បើនិយាយឲ្យ ដល់ គឺ គ្រួសារយើង អាចសុំច្បាប់ទៅលេងឬដាក់ជើងក្នុង ប្រទេសខ្មែរ ជាម្តងទៀត។ នយោបាយនៅប្រទេសកម្ពុជា នៅជាអាថ៌កំបាំង អ្នកណា ដែលហ៊ាននិយាយការពិត មិនអាចនិងរស់មានជីវិតបានយូរ។

# ជំពូក ទី១០

# ឯកសារយោង

**ដោយមាន** និយាយនៅផ្នែកបុព្វកថា ការចងក្រងនិពន្ធនេះ មិនអាចធ្វើបានបើគ្មាន បច្ចេកវិទ្យាថ្មីៗ សំខាន់បំផុត អិនធើរណិត និង ការរាវរក គូហ្គល និង ពាក្យអ្នក ប្រវត្តិសាស្ត្រដ៏ឆ្នើមៗ។ ឯកសារយោង មានដូចតទៅ:


**1)http://www.historyworld.net/wrldhis/PlainTextHistories.asp?groupid=2603&HistoryID=ac37&gtrack=pthc**
**2) http://www.asianinfo.org/asianinfo/cambodia/pro-history.htm**
**3)http://en.wikipedia.org/wiki/Kingdom_of_Cambodia_(1953%E2%80%931970)**
**4) http://en.wikipedia.org/wiki/Cambodia**
**5) http://en.wikipedia.org/wiki/Khmer_Rouge**
**6) http://en.wikipedia.org/wiki/Cambodian_People's_Party**
**7) http://www.illegal-logging.info/item_single.php?it_id=2140&it=news**
**8) https://maps.google.com/maps?hl=en&q=cambodia+map&ie=UTF-8&hq=&hnear=0x310787bfd4dc3743:0xe4b7bfe089f41253,Cambodia&gl=us&ei=V16CUcWRMMeu4AOetYGwCQ&sqi=2&ved=0CDAQ8gEwAA**